ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-2012, 15:49
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការ
# សវនាការផ្ទាល់មាត់លើឯកសារនានា
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី១៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វេង ហ៊ាត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក សំ សុគង់

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍

*(Ms.Phillipine SUTZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក វេង ហ៊ត់ | ខ្មែរ |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន! សូមជម្រាបសួរលោក លោកស្រីចៅក្រម!

យើងខ្ញុំសូមការបំភ្លឺ ហើយខ្ញុំយោងទៅរកទំនាក់ទំនងអ៊ីម៉ែលមកពីមន្ត្រីច្បាប់ជាន់ខ្ពស់អំពីភាពដែលអាចបង្ហាញខ្លួនរបស់ប្រធាន ឌី.ស៊ី.ខេម នៅថ្ងៃចន្ទ។ អ៊ីចឹង សូមឲ្យៗអង្គជំនុំជម្រះសម្រេចឲ្យបានសម្រេចថា តើបុគ្គលណាឲ្យពិតប្រាកដដែលនឹងត្រូវបង្ហាញខ្លួននៅក្នុងថ្ងៃចន្ទនោះ ដើម្បីឲ្យយើងខ្ញុំបានត្រៀមឆ្លើយតបទៅនឹងសវនាការថ្ងៃនោះ។ សូមអរគុណ។

[០៩:០៦:០១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវការសួរបញ្ជាក់អំពីបញ្ហានេះពីសំណាក់មេធាវី នួន ជា ហើយអង្គជំនុំជម្រះនឹងឆ្លើយតបទៅនឹងចម្លើយនេះនៅក្នុងពេលឆាប់ៗខាងមុខនេះ។

កាលពីម្សិលមិញ អង្គជំនុំជម្រះបានស្តាប់នូវសេចក្តីជំទាស់ទៅនឹងឯកសារឧបសម្ព័ន្ធA2 ដោយមេធាវីការពារក្តីទាំងបីក្រុមរួចហើយ។ ហើយនៅព្រឹកនេះ អង្គជំនុំជម្រះនឹងស្តាប់ការអំណះអំណាងតបរបស់ភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយជាបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញាមានរយៈពេល ៤៥នាទី ដើម្បីលើកឡើងអំពីអំណះអំណាងតបរបស់ខ្លួន។

សូមអញ្ជើញ!

[០៩:០៧:២៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម!

កាលពីម្សិលមិញនេះ យើងបានស្តាប់ការជំទាស់របស់ខាងមេធាវីការពារក្តី គឺខាងមេធាវីការពារក្តី នួន ជា ហើយនិង អៀង សារី គឺថាមានលក្ខណៈទូទៅ ហើយនិងទូលំទូលាយពេក។ ដូច្នេះ យើងបានស្តាប់មតិជំទាស់ទាំងអស់នេះតាំងពីថ្ងៃចន្ទមក ហើយយើងបានគិតថាខាងមេធាវីការពារក្តីគាត់មានការយល់ច្រឡំទៅលើលក្ខណៈវិនិច្ឆ័យ ដែលត្រូវអនុវត្តនៅក្នុងតុលាការនេះ។ ម៉្យាងទៀត នៅក្នុងអនុស្សរណៈ E159 នៅកថាខណ្ឌ៦ របស់អង្គជំនុំជម្រះបានបញ្ជាក់ថា នៅក្នុងសវនាការនេះ បញ្ហាយថាភាពនឹងត្រូវកម្រិតត្រឹមតែឯកសារ ឬក៏ប្រភេទឯកសារដែលថាខាងមេធាវីការពារក្តីគិតថាវាគ្មានភាពអាចជឿជាក់បានយោងទៅតាមវិធាន៨៧(៣)។

[០៩:០៨:៣១]

ហើយដូច្នេះ គឺថា គឺមិនចាំបាច់តម្រូវឲ្យមានឯកសារច្បាប់ដើមទេ។ ហើយខាងមេធាវីការពារក្តីខាងមេធាវី អៀង សារី គាត់បានបញ្ជាក់ថា គឺថាខាងសហព្រះរាជអាជ្ញាដែលត្រូវបង្ហាញនូវយថាភាពភាពពាក់ព័ន្ធ ឬភាពគួរឲ្យជឿជាក់បាននៅឯកសារ ដោយបង្ហាញអំពីអ្នកដែលទទួលខុសត្រូវនូវខ្លឹមសារនៃឯកសារទាំងអស់នេះ។ ហើយដូច្នេះ នៅពេលធ្វើនេះគឺថា ខាងមេធាវីការពារក្តី គឺគាត់បាន*ភូពីផាស*នូវឯកសារ។ ហើយកាលពីម្សិលមិញនោះ គឺមេធាវី កាណាវាស បាននិយាយថាគាត់បានជំទាស់ទៅលើឯកសារបី-- ពាក់ព័ន្ធទៅនឹងឯកសារទាំង៨៦ នេះ។

[០៩:០៩:១៩]

ដូច្នេះ ខាងមេធាវី នួន ជា និង អៀង សារី ដែលត្រូវតែលើកឡើងនូវការបញ្ជាក់ដែលមានតម្លៃហើយនិងច្បាស់លាស់ ដើម្បីឲ្យសើរើទៅលើយថាភាពបឋមនៃឯកសារដែលបានដាក់ជូនអង្គជំនុំជម្រះ ប៉ុន្តែខាងគាត់ គឺមិនបានធ្វើបែបនេះ។ ហើយចំណែកខាង ខៀវ សំផន វិញ គឺអង្គជំនុំជម្រះនឹងវាយតម្លៃទៅលើការជំទាស់ដែលបានលើកឡើងកាលពីម្សិលមិញនេះ ហើយការជំទាស់នេះ គឺមិនមែនជាជំទាស់ថ្មីទេ ហើយគឺបានលើកឡើងកាលពីមុនរួចមកហើយ។ ហើយអង្គជំនុំជម្រះក៏បានហាមឃាត់រួចមកហើយនូវការជំទាស់បែបនេះ។

ទោះជាយ៉ាងណាក៏ដោយគឺថា ការជំទាស់នេះ គឺមិនពាក់ព័ន្ធទៅនឹងសំខាន់ទេ-- បញ្ហាសំខាន់ទេដូចជាការរៀបចំបណ្តាញខាងរក្សាឯកសារនេះជាដើម។ ដូច្នេះយើងគិតមើលថា តើយើងមានតម្រុយ

ច្បាស់លាស់ណាខ្លះ ដើម្បីដោះស្រាយនូវបញ្ហាទាំងអស់នេះ។

[០៩:១០:១៧]

ក្នុងចំណោមឯកសារ៨៦ ទាំងអស់នេះ គឺ៥៤ គឺជាឯកសារនៃទស្សនាវដ្តីទង់បដិវត្ត ឬក៏ទស្សនាវដ្តីយុវជន យុវនារីបដិវត្ត។ ហើយបន្ថែមទៅលើ៥៤ នេះ គឺមានឯកសារបីទៀតដែលជាឯកសារថ្មីនៃលេខទស្សនាវដ្តីចាស់-- ទស្សនាវដ្តីទង់បដិវត្តចាស់ដែលបោះនៅមុនខែមេសា ឆ្នាំ១៩៧៥។ គឺឯកសារ D306/1.200 ហើយនិងឯកសារ D306/7.133 និង D266/7/3.36។ ដូចខាងមេធាវី ខៀវ សំផន បានលើកឡើងម្សិលមិញ គឺបន្ថែមទៅនឹងឯកសារបន្ថែមពីរទៀត គឺទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជន ហើយសរុបទៅ គឺមានឯកសារទាំងអស់៥៩ ដែលយើងនឹងពិនិត្យមើលឲ្យបានច្បាស់លាស់។

មានឯកសារ១៦ ផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធ២ របស់បក្ស ហើយមានខ្លឹមសារប្រែប្រួល ហើយនៅក្នុងនោះក៏មានលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា លក្ខន្តិកៈនៃសម្ព័ន្ធយុវជនបដិវត្តន៍កុម្មុយនីស្តកម្ពុជា ហើយនិងមានឯកសារពាក់ព័ន្ធទៅនឹងការបង្កើតសហករណ៍ ហើយនិងផែនការ៤ឆ្នាំ ដើម្បីកសាងសង្គមនិយមនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយគឺគ្របដណ្តប់ទៅលើឆ្នាំ៧៧ ដល់ ឆ្នាំ៨០។

ក្នុងចំណោមឯកសារទាំងអស់នេះ ក៏មានឯកសារប្រាំបី ដែលចាត់ទុកថាជាសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងសេចក្តីសម្រេចរបស់គណៈមជ្ឈិមពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន គឺចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦ ហើយនិងសេចក្តីណែនាំរបស់មន្ទីរ៨៧០ គឺឯកសារ ES6.6 ហើយនិងឯកសារទីមួយទៀត ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលខាងមេធាវីការពារក្តីលើកឡើង គឺឯកសារ D200.2.12។ ហើយនេះគឺ ជាឯកសារដដែលដែរ ដែលមាននៅក្នុង ES6.6 ដែលបានបង្ហាញដោយសាក្សី នៅពេលដែលធ្វើការស្តាប់ចម្លើយរបស់គាត់។

[០៩:១២:៥២]

ហើយជាចុងក្រោយមុននឹងផ្តល់វេទិកាទៅឲ្យសហការីរបស់ខ្ញុំ គឺយើងនិយាយអំពីភាពពាក់ព័ន្ធហើយនិងទំនាក់ទំនងនៃឯកសារទាំងអស់នេះទៅនឹងសំណុំរឿងដំណាក់កាលទីមួយនេះ។ ឯកសារទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជានេះ គឺពាក់ព័ន្ធទៅនឹងជំពូកមួយនៃដីកាដំណោះស្រាយដែលជាកម្មវត្ថុនៃការជំនុំជម្រះក្តី គឺជាប្រវត្តិសាស្ត្រនៃបក្ស រចនាសម្ព័ន្ធរដ្ឋបាលមជ្ឈិម គឺបក្ស ឬក៏គណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍ រចនាសម្ព័ន្ធមូលដ្ឋាន ការទំនាក់ទំនងរបស់របប រចនាសម្ព័ន្ធឃោធារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយតួនាទីរបស់ជនជាប់ចោទ ហើយនិងឯកសារមួយចំនួនពាក់ព័ន្ធទៅនឹងការ

ជម្លៀសប្រជាជនដោយបង្ខំ។

[០៩:១៣:៤៨]

ដូច្នេះឯកសារទាំងអស់នេះ គឺមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសំណុំរឿង គឺជាឯកសារនៅសម័យនោះ ហើយនិងជាឯកសាររបស់បក្សផងដែរ។ ដូច្នេះយើងអាចកំណត់នូវចំណុចដែលពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធទី២ របស់យើងខ្ញុំ គឺនៅក្នុងឯកសារ-- គឺនៅក្នុងកូឡោនមួយដែលបញ្ជាក់ថា "ដីកាដំណោះស្រាយ"។ ដូច្នេះ ខ្ញុំផ្តល់វេទិកានេះជូនទៅដល់សហការីរបស់ខ្ញុំ ដើម្បីបង្ហាញអំពីលក្ខណៈសំខាន់ផ្ទៃក្នុងនៃឯកសារទាំងអស់នេះ។

**លោក វេង ហ៊ត់៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពអង្គជំនុំជម្រះទាំងមូល។ ខ្ញុំនឹងធ្វើការឆ្លើយតបទាក់ទងទៅនឹងមេធាវីការពារក្តីរបស់លោកការពារក្តី នួន ជា, អៀង សារី និង ខៀវ សំផន។ ដូចលោកមេធាវីការពារ ខៀវ សំផន បានលើកឡើងហើយថា ការិយាល័យសហព្រះរាជអាជ្ញា បានបង្ហាញនូវឯកសារស្តីពីទង់បដិវត្ត២៤។ ខ្ញុំទទួលស្គាល់ថា បង្ហាញអ៊ីចឹងមែន គឺមាន២៤។ នៅក្នុង នោះ លោកមេធាវី ខៀវ សំផន ក៏បានលើកផងដែរថា ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត២៨ គឺត្រឹម ត្រូវហើយព្រោះយើងបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធ២។

ឥឡូវនេះ ខ្ញុំសូមលើកទាក់ទងជាមួយនឹងទង់បដិវត្ត វាមានបែងចែកជាពីរ គឺទង់បដិវត្តមួយគឺទង់ទស្សនាវដ្តីយុវជនបដិវត្តមួយ ហើយដំបូងនេះ ខ្ញុំបង្ហាញទង់បដិវត្ត។ នៅក្នុងទង់បដិវត្តនេះ គឺមានចំនួន២៤ ដែលយើងលើកយកមកបង្ហាញ ហើយការចាប់ផ្តើមដែលយើងរកឃើញទង់បដិវត្តដំបូងនោះ គឺបានចេញផ្សាយនៅខែសីហា ឆ្នាំ១៩៧៥ ហើយចុងក្រោយនោះ យើងរកឃើញថា នៅខែកញ្ញា ឆ្នាំ១៩៧៨។ ក្នុងការបោះពុម្ពផ្សាយទង់បដិវត្តនេះ យើងឃើញថា នៅក្នុងយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះ។

ដើម្បីបង្ហាញឯកសារនេះ ជូនអង្គសវនាការឲ្យបានឃើញច្បាស់នោះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានដើម្បីបង្ហាញស្លាយ។

[០៩:១៦:៤០]

**ប្រធានអង្គជំនុំ៖**

អង្គជម្រះអនុញ្ញាត។ អញ្ជើញ!

**លោក វេង ហ៊ាត់៖**

ឯកសារ D243/2.1.6 ចុះខែសីហា ឆ្នាំ១៩៧៦ និងក្របមុខ ERN ជាភាសាខ្មែរ 00063273។ ERN ជាបារាំង 00538986។ ERN ជាភាសាអង់គ្លេស 00486742។ ខ្ញុំសូមជម្រាបអង្គសវនាការថា នៅក្នុងឯកសារទាំងនេះ គឺគេបង្កើតឯកសារឡើង មិនមែន *អេហ្វ័រ*(A4) ទេ វារាងតូចល្មម ដែលយើងអាចមើលបានជាកូនសៀវភៅ ហើយវាមានសងខាង មិនមែនមួយខាងទេ សៀវភៅហ្នឹង។

*(ការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍)*

[០៩:១៩:០៣]

លេខ១ ខ្ញុំសូមពន្យល់ទៅដល់អង្គសវនាការ និងក្រុមរបស់លោកការពារជនជាប់ចោទទាំងបីក្រុម។ សញ្ញាលេខ១ គឺទង់ទាំងអស់នេះ ដែលយើងមើលឃើញ គឺមិនមែនពណ៌ស-- មិនមែនពណ៌អីអ៊ីចឹងទេគឺវាពណ៌ក្រហមទាំងប្រាំតែម្ដង ពណ៌ក្រហមទាំងអស់ចំណុចលេខមួយហ្នឹង។ ហើយ នួន ជា ហ្នឹងគាត់បានគិតថា ក្រោយថ្ងៃ១៧ មេសា ៧៥ មានទង់មួយប៉ុណ្ណោះ ដែលបានបង្ហាញនៅលើក្របមុខ។ មិនមែនទង់មួយទេ គាត់យល់ច្រឡំកាលបរិច្ឆេទ នៃការទង់មួយ ប៉ុន្តែគាត់និយាយត្រូវថា មានការប្រែប្រួល គឺប្រែប្រួលនៅខែកញ្ញា ឆ្នាំ១៩៧៧ នោះទេ ដែលមានទង់មួយពណ៌ក្រហមហ្នឹង។ អ៊ីចឹងនៅក្នុងចន្លោះហ្នឹងពីថ្ងៃ១៧ មេសា ៧៥ រហូតមកដល់ខែកញ្ញា ឆ្នាំ១៩៧៧ នេះ គឺទង់ហ្នឹងវាមានប្រាំពណ៌ក្រហម។ ហើយបន្ទាប់មក គឺបានគេដូរទង់ហ្នឹងទៅជាទង់មួយវិញ។ អ៊ីចឹង ខ្ញុំគិតថា គាត់និយាយថា ការប្រែប្រួលទង់នេះ គឺត្រូវ ក៏ប៉ុន្តែពេលវេលានោះវាខុសបន្តិច។

ខ្ញុំនឹងពន្យល់ចំណុចទីពីរទៀត ស្លាយទីពីរមក។ នៅក្រោមទង់បដិវត្ត ពីលើទង់ប្រាំហ្នឹងវាមានលេខក្រោម គឺជាឈ្មោះនៃការបោះពុម្ពផ្សាយទង់បដិវត្ត ឈ្មោះនេះមិនដែលផ្លាស់ប្តូរទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក៏ប៉ុន្តែ នួន ជា ហ្នឹងគាត់ថា មិនមែនទង់បដិវត្តទេ ប្រហែលជាគាត់គិតថា ទង់ក្រហម។ ត្រូវហើយ ពីព្រោះពណ៌វានៅហ្នឹងក្រហម បាទ។

[០៩:២១:០៩]

តាមចំណេះដឹងរបស់ខ្ញុំ គេគ្មានការបោះពុម្ពផ្សាយដែលមានចំណងជើងថា “ទង់ក្រហម” ទេ។ យើងមើលអត់មានការទង់ក្រហម គឺទង់បដិវត្តហ្នឹងតែម្ដង។

ចំពោះយើងមើលទៅដល់ចំណុចទីបី វិញ។ ចំណុចទីបី ឥឡូវនេះ-- ចាំចំណុចទីបីតាមក្រោយប៉ុន្តែខ្ញុំត្រូវទៅ ពីព្រោះពេលវេលារាងមិនចាំខ្ញុំទេ។ នៅក្នុងចំណុចទីបី ច្បាប់ចេញផ្សាយមានលេខបង្ហាញ

នៅខាងក្រោមនៃទំព័រក្របមុខ នៅក្នុងប្រអប់។ នៅក្នុងប្រអប់នៃការចេញផ្សាយទាំងនេះ មានលេខផ្សាយ គឺឆ្លើយតបទៅនឹងខែឆ្នាំ ដែលវាបានបោះផ្សាយ។ ឧទាហរណ៍ច្បាប់ចេញផ្សាយលេខមួយ គេបោះពុម្ព គេថានៅក្នុងខែមករា។ ប្រសិនបើច្បាប់ចេញផ្សាយលេខប្រាំបីនោះ គឺខែសីហានេះឯង។

[០៩:២២:៤១]

អ៊ីចឹងយើងមើលទៅឃើញថា វាស៊ីគ្នាហើយ។ ចុះបើលេខផ្សាយពិសេស? លេខផ្សាយពិសេសអត់មានលេខទេ គេដាក់ថាលេខពិសេសនៅលើក្របទំព័រមុខ។

ឥឡូវចូលដល់លេខបួន។ លេខបួននេះជាការស្រួលចំណាំទេ គឺសំដៅទៅលើខែ និងឆ្នាំទេ។

ចូលដល់លេខប្រាំតែម្តងទៅ។ នៅពេលណាបោះពុម្ពផ្សាយនេះ ចំណង ឬក៏មាតិកាលើសពីមួយលិបិក្រម គេហៅថា "អក្សរ"ហ្នឹង គឺមានប្រអប់មួយនៅក្នុងសន្លឹកទីពីរ។ នេះបង្ហាញនេះគឺនៅក្នុងសន្លឹកទីពីរហើយ មិនមែនសន្លឹកទីមួយទេនៃទង់បដិវត្ត។ ទង់បដិវត្តមានទង់-- នៅក្នុងចំណោមទង់បដិវត្តទាំង ២៤ ដែលមានចំណងជើងតែមួយ គឺគ្មានលិបិក្រមទេ។ ចំណងជើងនីមួយៗ គឺសុន្ទរកថាវែង និងសំខាន់ដែលតំណាងឲ្យបក្ស។

[០៩:២៣:៥៣]

ចូលចំណុចទីប្រាំមួយទៅ!

ខ្ញុំសូមអានបន្ត ចំណុចទីប្រាំមួយនៅលើទំព័រនេះ គឺយើងថា ជានិច្ចកាល គឺមានពណ៌ក្រហមមួយជានិច្ច និងពាក្យថា "ទង់បដិវត្ត" នៅចន្លោះកណ្តាលនៃទង់នេះ។ ចំណែកលោក នួន ជា គាត់និយាយថា ទង់ក្រហមៗ គាត់និយាយហ្នឹង គឺត្រឹមត្រូវហើយ ពីព្រោះពណ៌របស់ទង់ហ្នឹង គឺក្រហម។ ក៏ប៉ុន្តែសរសេរនៅក្នុងខ្លឹមសារហ្នឹង គឺថាទង់បដិវត្តដដែលទេ។

ចូលដល់ចំណុចទីប្រាំពីរ។ នៅក្បែរនេះដែរយើងឃើញមានពាក្យថា ទស្សនាវដ្តីផ្ទៃក្នុងបក្ស ដែលតែងតែមាននៅលើជ្រុងខាងស្តាំ។ នៅលើជ្រុងខាងស្តាំនេះ ហើយបញ្ជាក់យ៉ាងច្បាស់អំពីប្រភព និងអ្នកបង្កើតទស្សនាវដ្តីនេះ គឺជាអ្នកបោះពុម្ពផ្លូវការរបស់ ប.ក.ក ខ្លួនឯង ព្រមទាំងបញ្ជាក់បុគ្គលទស្សនាវដ្តីនេះ គឺសមាជិកបក្ស។

ចូលដល់ទីប្រាំបីមក!

លេខរៀងទីប្រាំបី ពាក្យថា "ចេញផ្សាយរៀងរាល់ខែ" តែងតែមាននៅពីក្រោមពាក្យទស្សនាវដ្តីផ្ទៃក្នុងបក្ស ដូចជាយើងបានឃើញស្រាប់។ ទង់បដិវត្តបោះពុម្ពរៀងរាល់ខែ ក្នុងទង់បដិវត្ត២៤ នៅក្នុង

ឧបសម្ព័ន្ធ២នេះ គឺមានលេខ ជាលេខធម្មតា ដែលចេញផ្សាយក្នុងមួយខែ ចំណែកឯមួយលេខទៀតចេញផ្សាយពីរខែម្តង និងមានលេខពិសេសចំនួនប្រាំបួនលេខ ដែលខ្លះចេញផ្សាយមួយខែម្តង និងខ្លះចេញផ្សាយពីរខែម្តង។

[០៩:២៦:០០]

សូមចូលទៅដល់លេខប្រាំបួន។ លេខប្រាំបួនៗ នេះយើងឃើញថា មានបញ្ជាក់ពីលេខដែលចេញផ្សាយថ្ងៃខែឆ្នាំជានិច្ច គឺមាននៅលើទំព័រទីពីរ លើលិបិក្រម។ យើងពិនិត្យលើទំព័រនៅក្នុងនីមួយៗនៃទង់បដិវត្តនេះយើងនឹងឃើញ។

ចូលដល់លេខដប់មក! គឺជាចំណងជើង និងអត្ថបទគោល វាយអក្សរផ្តង់ធំៗ និងបោះពុម្ពនេះមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការបោះពុម្ពផ្សាយទង់បដិវត្តផ្សេងទៀត។ ចំណងជើងនេះ ឆ្លើយតបទៅនឹងអ្វីដែល នួន ជា បានឆ្លើយកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ថា បន្ទាប់ពីឆ្នាំ៧៥មក ការបោះពុម្ពផ្សាយលែងសរសេរជាដៃហើយ ប៉ុន្តែវាយជាមួយនឹងពុម្ពអក្សរ។

លេខ១១ យើងឃើញរូបញញួរ ក្នុងនោះមានកណ្តៀវ និមិត្តសញ្ញាឲ្យបក្សកុម្មុយនីស្តកម្ពុជា ដែលអាចរកឃើញគ្រប់ចំណងជើងធំៗនៃផ្នែកនីមួយៗនៅក្នុងទង់បដិវត្ត។

[០៩:២៧:១៣]

លេខ១២ នៅគ្រប់លេខទាំងអស់នៃទង់បដិវត្ត មានបញ្ចូលរូបកម្មករធ្វើការនៅវាលស្រែ តាមរោងចក្រ និងតាមកន្លែងការងារផ្សេងៗ ពីមួយទៅពីរសន្លឹក ក្នុងនោះគឺមានបញ្ចូលរូបថតមួយសន្លឹកនៅលើទំព័រចុងក្រោយគេ។

បង្ហាញលេខ១៣មក! នៅលើលេខរៀងទី១៣នេះ គឺទំព័រចុងក្រោយជាធម្មតាមានរូបទង់មួយ និងញញួរមួយជាមួយនឹងកណ្តៀវ ហើយនិងមានអក្សរ "ទង់បដិវត្ត" នៅលើនៅក្នុងទង់នេះ អត់មានរង្វង់មូលហ៊ុមព័ទ្ធទេ វាខុសពីទង់យុវជន យុវនារី។

[០៩:២៨:០៨]

ឥឡូវនេះ ខ្ញុំសូមការអនុញ្ញាតពន្យល់ទាក់ទងជាមួយនឹងទស្សនាវដ្តីយុវជន និងយុវនារីលើចំណុចទីពីរ។ ការបោះពុម្ពផ្សាយរបស់ទស្សនាវដ្តីយុវជន យុវនារីបដិវត្ត គឺមាន២៨ច្បាប់។ ដូច្នេះ លោកមេធាវី ខៀវ សំផន គាត់និយាយថា ២៨ច្បាប់ គឺទទួលស្គាល់ហើយ គឺអ៊ីចឹងមែនហើយ យើងរកឃើញនៅក្នុងហ្នឹង ដែលមាននៅក្នុងសំណុំរឿង។ លេខបោះពុម្ពផ្សាយលើកដំបូង កាលបរិច្ឆេទដែលយើងរកឃើញគឺ

នៅខែសីហា, កញ្ញា ឆ្នាំ១៩៧៤។ ហើយលេខដែលបោះពុម្ពចុងក្រោយ គឺដែលយើងរកឃើញនោះ គឺនៅខែវិច្ឆិកា ឆ្នាំ១៩៧៨។

[០៩:២៩:០០]

និយាយជាទូទៅ លក្ខណៈខាងក្រៅរបស់ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត គឺស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងទស្សនាវដ្ដីទង់បដិវត្ត ប៉ុន្តែខ្ញុំសូមបង្ហាញចំណុចមួយចំនួននៅក្នុង *ផៅវ័រភ័ញ* គឺនៅក្នុងស្លាយ។ សូម-- ឯកសារលេខD243/2.1.25 សីហា ឆ្នាំ១៩៧៦។ លេខERNខ្មែរ 00064154 ERN ជាភាសាបារាំង 00593843 ERN ជាភាសាអង់គ្លេស 00539849។ លក្ខណៈផ្ទៃក្នុងនៃទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តឃើញថា តាំងពីយើងរកឃើញនៅក្នុងខែសីហា កញ្ញា ឆ្នាំ១៩៧៤ រហូតទៅដល់ខែវិច្ឆិកា ឆ្នាំ១៩៧៨ កាលបោះពុម្ពហ្នឹង អត់មានប្រែប្រួលទេនៅក្នុងហ្នឹង។ ឥឡូវយើងចាប់ផ្ដើមមើលក្របមុខរបស់ទង់យុវជន និងយុវនារីបដិវត្ត។

ខ្ញុំសូមបង្ហាញលេខ១ គឺមានរូបទង់ពីរនៅក្របមុខនៃទស្សនាវដ្ដីនីមួយៗ ក្នុងចំណោមទស្សនាវដ្ដីយុវជន និងយុវនារីចំនួន២៨ច្បាប់ គឺគេប្រើតែទង់ពីរដូច្នេះឯង។ ចំណុចទីពីរ ឈ្មោះថាទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តមិនដែលផ្លាស់ប្ដូរទេ តាំងពីឆ្នាំ៧៤ ដល់៧៨ ឈ្មោះនេះនៅលើក្របមុខទំព័រទីពីរ និងទំព័រចុងក្រោយ។

លេខ៣ៗ ជាធម្មតាគឺមានលេខ លេខពិសេសមិនមានលេខទេសម្រាប់ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត។ លេខ៤ ដែលបង្ហាញនេះ គឺយើងឃើញថាមានសញ្ញាថ្ងៃខែឆ្នាំ លោតទៅលេខប្រាំតែម្ដងទៅ។ នៅទំព័រទីពីរ ទស្សនាវដ្ដីយុវជន និងយុវនារីតែងតែបង្ហាញនៅទំព័រទីពីរ។ ជាថ្មីម្ដងទៀត នៅលើកាច់ជ្រុងខាងឆ្វេងនេះ មានឈ្មោះនៃការបោះពុម្ពផ្សាយ។ លេខ៦ នៅលើផ្នែកលើកាច់ជ្រុងខាងស្ដាំមានអក្សរថា “អង្គការឃោសនាអប់រំរបស់ស.យុវកក” បានប្រើដោយបញ្ជាក់ថា មានតែសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ ដែលបានទទួលការបោះពុម្ពផ្សាយនេះ។ ហើយចំណុចនេះ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងអង្គសវនាការលើកមុន លោក ឡុង នរិន្ទ គាត់និយាយហើយ គាត់ថាចំពោះទង់-- ទង់យុវជន និងយុវនារីបដិវត្តនោះ គាត់បានឃើញមែនហើយ។ លេខ៧--

[០៩:៣២:២៦]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ ផ្អាកបន្តិច លោកតំណាងសហព្រះរាជអាជ្ញាជាតិ។

បាទ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

បើយើងមានការបកប្រែជាភាសាបារាំងតាំងពីរបីមកហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ លោកព្រះរាជអាជ្ញារងផ្អាកបន្តិចសិន ហើយក្រុមមន្ត្រីច្បាប់សម្របសម្រួលលើបញ្ហាបកប្រែភាសាជាបន្ទាន់!

[០៩:៣២:៥៤]

*(មានបញ្ហាបច្ចេកទេសខាងបកប្រែភាសាបារាំង)*

[០៩:៣៥:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អាចដំណើរការវិញបានហើយ តាមរបាយការណ៍របស់មន្ត្រីគ្រប់គ្រងតុលាការ។

សូមអញ្ជើញសហព្រះរាជអាជ្ញារងជាតិបន្ត!

**លោក វេង ហ៊ត់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរថា តើខ្ញុំគួរតែផ្ដើមពីយុវជន យុវនារីបដិវត្តជាថ្មីម្ដងទៀតឬក៏ចំណុចណាមួយបាទ?

**ប្រធានអង្គជំនុំ៖**

ផ្ដើមសាឡើងវិញទៅជាការល្អ ពីព្រោះមានការបាត់-- មិនបានបកប្រែពីរបីនាទីហ្នឹងដូចជាប្រហែលជាត្រូវចាប់ផ្ដើមហើយ។ ចាប់ផ្ដើមពីដំបូងណ៎ា! ពីៗទង់យុវជន និងយុវនារីបដិវត្ត។

**លោក វេង ហ៊ត់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងចាប់ផ្ដើមពន្យល់កិច្ចការនេះជូនអង្គសវនាការ និងមេធាវីការពារក្ដីស្ដាប់ជាបន្ត។

[០៩:៣៦:៤១]

អំពីទង់ទស្សនាវដ្ដីយុវជន និងយុវនារី ការបោះពុម្ពផ្សាយរបស់ទស្សនាវដ្ដីទង់យុវជន និងយុវនារីគឺមានចំនួន២៨ច្បាប់ ដែលមានក្នុងនោះគឺឯកសាររបស់ព្រះរាជអាជ្ញា។ លេខដែលបោះពុម្ពផ្សាយលើកដំបូង នៅកាលបរិច្ឆេទខែសីហា និងខែកញ្ញា ឆ្នាំ៧៤ ហើយលេខដែលបោះពុម្ពចុងក្រោយ គឺយើងរក

ឃើញនៅខែវិច្ឆិកា ឆ្នាំ៧៨។

ចំណុចទីមួយក្របមុខ គឺមានរូបទង់ពីរ នៅក្របនៃទស្សនាវដ្ដីនីមួយៗ ក្នុងចំណោមទស្សនាវដ្ដីយុវជន និងយុវនារីទាំង២៨ច្បាប់នេះ។

លេខពីរ ឈ្មោះថាទង់ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត មិនដែលបានផ្លាស់ប្ដូរទេ ពីឆ្នាំ៧៤ ដល់ឆ្នាំ៧៨ ឈ្មោះនេះនៅលើក្របមុខទំព័រទីពីរ នៃទំព័រចុងក្រោយ។

លេខរៀងទីបី ជាធម្មតា គឺមានលេខ លេខពិសេសមិនមានលេខទេសម្រាប់ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត។

លេខបួន ដែលបង្ហាញនេះគឺយើងឃើញថា មានបញ្ជាក់ថ្ងៃ-- មានបញ្ជាក់តែខែនិងឆ្នាំ។

នៅទំព័រទីពីរទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តតែងតែបង្ហាញជាថ្មីម្ដងទៀតនៅលើកាច់ជ្រុងខាងឆ្វេងមានឈ្មោះនៃការបោះពុម្ពផ្សាយលេខ៦ នៅផ្នែកលើកាច់ជ្រុងខាងស្ដាំមានអក្សរថា "ឃោសការអប់រំរបស់ ស.វ.ក" បានប្រើដោយបញ្ជាក់ថា មានតែសមាជិកយុវជនបក្សកុម្មុយនីស្ដកម្ពុជាទេដែលបានទទួលការបោះពុម្ពផ្សាយនេះ។

[០៩:៣៨:៣០]

ហើយនៅក្នុងនេះដែរ លោកឡុង នរិន្ទបានប្រាប់ទៅដល់អង្គសវនាការថា ទង់ទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តនេះ គឺគាត់បានឃើញហើយ គាត់បានឃើញមែន។

លេខប្រាំពីរ ស្រដៀងគ្នាទៅនឹងទស្សនាវដ្ដីទង់បដិវត្តដែរ ទស្សនាវដ្ដីយុវជន និងយុវនារីបោះពុម្ពផ្សាយជារៀងរាល់ខែដែរ។ ប៉ុន្តែមានការបោះពុម្ពផ្សាយចំនួន ២២លេខ ដែលបានបោះពុម្ពផ្សាយមួយខែម្ដង ហើយ ប្រាំមួយលេខ បានចេញផ្សាយពីរខែម្ដង។

លេខប្រាំបី លេខ និងខែ នៃការផ្សាយត្រូវបញ្ជាក់ម្ដងទៀតនៅក្នុងទំព័រទីពីរនេះ។

លេខប្រាំបួន មាតិកា ឬលិបិក្រមត្រូវដាក់ក្នុងស៊ុម។

ទំព័រខាងក្នុងនៃកូនសៀវភៅ និងទំព័រចុងក្រោយលេខដប់ ស្រដៀងគ្នាទៅនឹងទស្សនាវដ្ដីបដិវត្ត គឺយើងពិនិត្យឃើញថា មានញញួរ កណ្ដៀវ ដែលជានិមិត្តរូបនៃបក្សកុម្មុយនីស្ដ ត្រូវបានបង្ហាញចំណងជើងនៃជំពូកនីមួយៗ។

លេខ១១ ទស្សនាវដ្ដីយុវជន និងយុវនារី តែងតែបញ្ចប់ដោយកំណាព្យ ដែលជាការបង្ហាញពីភាពរុងរឿងរបស់បក្សរបស់យុវជន ការបង្កបង្កើនផលស្រូវ និងការប្រមាថពួកសត្រូវផ្សេងៗ។

លេខ១២ មានរូបថតចំនួនប្រាំរបស់ពួកកម្មករ និងកសិករ នៅកន្លែងធ្វើការត្រូវបានបង្ហាញនៅទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តនីមួយៗ។

លេខ១៣ នៅទំព័រចុងក្រោយគឺខុសគ្នាពីទំព័រចុងក្រោយនៃទស្សនាវដ្ដីបដិវត្ត។ ដូចខ្ញុំបានបង្ហាញហើយថា នៅក្នុងទស្សនាវដ្ដីបដិវត្តគឺមិនមានស៊ុមហ៊ុមព័ទ្ធយុវជន និងយុវនារីទេ។ ក៏ប៉ុន្តែនៅក្នុងទស្សនាវដ្ដីយុវជននេះ គឺមានរង្វង់ពីរខាងក្នុងមួយ ខាងក្រៅមួយ ហ៊ុមព័ទ្ធនូវឈ្មោះយុវជន និងយុវនារី ហើយសញ្ញានោះ គឺមានកណ្ដៀវ និងញញួរស្រដៀងគ្នាទៅនឹងទស្សនាវដ្ដីទង់បដិវត្ត ទស្សនាវដ្ដីយុវជន និងយុវនារីមានលក្ខណៈខាងក្នុងដែលដូចគ្នា និងស៊ីសង្វាក់គ្នា ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

[០៩:៤១:២៣]

គោលបំណងនៅក្នុងទស្សនាវដ្ដីនេះ គឺដើម្បីអប់រំ និងបញ្ចុះបញ្ចូលសមាជិកយុវជននៅក្នុងបក្ស។ ប្រធានបទនៅក្នុងទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជន និងយុវនារី គឺជាវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជា គោលនយោបាយ សេដ្ឋកិច្ច សន្តិសុខ សកម្មភាពយោធា។

ទស្សនាវដ្ដីយុវជន និងយុវនារីតែងតែផ្ដោតទៅលើប្រធានបទដែលសាមញ្ញជាង ដូចជាការបង្កបង្កើនផល ភាពរឹងមាំ និងសុភមង្គលសមាជិកបក្សដែលយុវជន និងវិន័យ។ កំណាព្យ និងពាក្យស្លោកមានគោលបំណងក្នុងការចំអែចំអន់យុវជន យុវនារី។

តទៅនេះ ខ្ញុំសូមបង្ហាញពាក្យប្លែកៗ នៅក្នុងទស្សនាវដ្ដីទង់បដិវត្ត ហើយជាមួយនិងទស្សនាវដ្ដីទង់យុវជន និងយុវនារី។ ពាក្យប្លែកៗនោះគឺមានប្រើប្រាស់នៅក្នុងទស្សនាវដ្ដីទង់បដិវត្ត គឺមានទំនាក់ទំនងជាមួយនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្ត និងការធ្វើឲ្យនឹកឃើញ ដូចជា៖ វណ្ណៈ សត្រូវ ការបង្កបង្កើនផលស្រូវ វិន័យ ឬសមូហនីយកម្ម។ ពាក្យដែលប្រើញឹកញាប់ដូចជា៖ ចក្រពត្តិ សក្តិភូមិ មូលធននិយម តស៊ូវណ្ណៈ កម្ទេច បំបាត់ខ្មាំង មហាលោតផ្លោះ មហាអស្ចារ្យ លុបបំបាត់ទ្រព្យស្ទួនតួគិញ សេ.អ៊ី.អា ទិគៀន និងស្វ័យទិគៀន ស្រូវបីតោនក្នុងមួយហិចតា ឬពួកអាក្បត់។

[០៩:៤៣:៤៧]

លោកប្រធាននៅពេលនេះ ខ្ញុំជូនទៅសហការីរបស់ខ្ញុំដើម្បីបន្តកិច្ច។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ, សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយលឿនបន្តិចព្រោះបញ្ហាបច្ចេកទេសដែលកើតមានឡើងអម្បាញ់មិញនេះ។ ខ្ញុំសូមឃោគយល់អំពីខ្ញុំ ពីព្រោះពេលវេលានៅសល់តិច។ ខ្ញុំបង្ហាញពីតម្រុយខាងក្រៅទាក់ទងទៅនឹងទង់បដិវត្ត ហើយនិងទង់យុវជន យុវនារីនេះ លើមូលដ្ឋាន ការផ្ដល់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះ សាក្សី TC-338 ហើយនិង P065 ទង់បដិវត្តទាំងអស់នេះ គឺថា ត្រូវបានផ្សាយដោយក្រសួងឃោសនាការ ហើយនិងរោងពុម្ពផ្សេងៗ ដែលមានការិយាល័យ K25, K26 ហើយនិង K27។ សាក្សី TC-338 បានធ្វើការនៅក្នុងការិយាល័យទាំងបីនេះ ហើយបានប្រកាសដូចតទៅនេះ៖ នៅ ក២៥ ការងារគឺថាធ្វើការបោះពុម្ពទស្សនាវដ្ដីបដិវត្ត ហើយនិងទស្សនាវដ្ដីយុវជនបដិវត្ត។ K26 គឺបោះពុម្ពកាសែត K27 គឺបោះពុម្ពទស្សនាវដ្ដីនេះ។ គឺជាសក្ខីកម្ម 201/10 ហើយ P65 បានបញ្ជាក់ថា នេះជាទស្សនាវដ្ដី គឺជាឯកសារ D234 បានស្ដាប់សាក្សីផ្សេងទៀតផងដែរ។ បានរៀបរាប់អំពីអត្ថិភាព ហើយនិងខ្លឹមសារនៃទស្សនាវដ្ដីទាំងអស់នេះ ដែលនិយាយចេញពីកម្មាភិបាលបក្ស មានសាក្សីមាន ឌុច ទៅទៀតដែលយើងបានស្ដាប់ផងដែរ។ គឺថា TCW-797 នៅក្នុងសក្ខីកម្មរបស់គាត់ 232 TCW-126 TCW-110 ហើយ TCW-504 សក្ខីកម្ម--

**អ្នកបកប្រែ៖**

លោកប្រធាន គាត់និយាយលឿនពេក ខ្ញុំកត់លេខឯកសារអត់ទាន់ទេលោកប្រធាន។

[០៩:៤៦:៥១]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

*(គ្មានការបកប្រែ)*

សេចក្ដីប្រកាសរបស់ជនជាប់ចោទ នួន ជា តាំងពីដើមសវនាការមកនោះ បញ្ជាក់ថាពិតជាមានទស្សនាវដ្ដីដែលហៅឈ្មោះថា "ទង់បដិវត្ត" ដែលបោះពុម្ពផ្សាយតាំងពីមានកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ រហូតដល់ការផ្ដួលរលំនៃរបបនេះ ទោះបីជាមានការផ្លាស់ប្ដូរឈ្មោះ ឬក៏ក្របនៅឆ្នាំ១៩៧៥ ក៏ដោយចុះ។

នៅពេលដែល នួន ជា បានសួរចម្លើយអំពីខ្លឹមសារនៃទង់បដិវត្តដោយចៅក្រម ខាតវ៉ាយថ៍ គាត់ពុំបានលើការជំទាស់អ្វីឡើយ ហើយក៏មិនបាននិយាយឲ្យសុំផ្ញើឯកសារដើមឲ្យគាត់នោះទេ គាត់បានទាមទារឲ្យផ្ញើឯកសារដើមនេះ នៅពេលដែលសហព្រះរាជអាជ្ញាសួរទៅគាត់តែប៉ុណ្ណោះ។

នៅថ្ងៃទី១៥ ធ្នូ ឆ្នាំ២០១១ គាត់បានលើកឡើងថា គឺគណៈអចិន្ត្រៃយ៍ដែលទទួលបន្ទុកខាងបោះពុម្ពទង់បដិវត្ត។ ហើយជាពិសេស គឺលេខាបក្សនិងខ្លួនខ្ញុំផ្ទាល់តែម្តង គឺយើងជាអ្នកដែលសរសេរខ្លឹមសារនៃទង់បដិវត្តទាំងអស់នេះ។ ជាការពិតណាស់ដោយសារតែមាន ស៊ី.ឌី.ខេម (ស៊ីក) ដែលសហព្រះរាជអាជ្ញា អាចធ្វើការស៊ើបអង្កេតបឋម ហើយនិងសហចៅក្រមស៊ើបអង្កេតហ្នឹងបានទទួលឯកសារទាំងអស់នេះ។ ហើយយើងបានទទួលទង់បដិវត្តទាំងអស់នេះពី ស៊ី.ឌី.ខេម លើកលែងតែមានបួនឯកសារតែប៉ុណ្ណោះ ដែលយើងបានទទួលពីខាងទួលស្លែង ហើយឯកសារផ្សេងទៀតយើងបានទទួលពីប្រភពផ្សេងទៀត។

[០៩:៤៨:៤៣]

ប្រធាន ស៊ី.ឌី.ខេម បានធ្វើការកំណត់ទង់បដិវត្តពីរ គឺថា IS11.10 ហើយនិង IS11.11 គាត់បាននិយាយពិភាក្សាអំពីស្ថានភាពដែល របៀបដែល ស៊ី.ឌី.ខេម ដែលប្រមូលបានឯកសារដើមទាំងអស់នេះ TCW-110 123/3 ដែលចុះខែកក្កដា ឆ្នាំ១៩៩៧។ សាក្សីទាំងអស់នេះ ក៏បានបញ្ជាក់ផងដែរថា ទង់បដិវត្តនេះត្រូវបានសរសេរដោយគណៈមជ្ឈិម គឺមាន ប៉ុល ពត, អៀង សារី គឺអ្វីដែលលោក នួន ជា បានលើកឡើងផងដែរ។

[០៩:៤៩:៤២]

វាមិនមែនជាការធម្មតាទេដែលថា ទង់បដិវត្តចំនួនប្រាំមួយច្បាប់ ហើយនិងពីរច្បាប់នៃទង់យុវជនយុវនារីនេះ ត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង០០២នេះ។ ទោះបីជាយើងដឹងថា ភាគីខាងការពារក្តីមិនបានចូលរួមទៅក្នុងសំណុំរឿង០០១ក៏ដោយ ក៏មិនមែនមានន័យថា អង្គជំនុំជម្រះមិនបានពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង០០១ ឬគាត់មិនបានដកចេញនូវធាតុផ្សំទាំងឡាយណា ដែលថាខ្លួនយល់ឃើញថា ខ្លួនមិនអាចទទួលយកបាននោះដែរ។

ទាក់ទងទៅនឹងឧទាហរណ៍-- ខ្លឹមសារនៃទង់បដិវត្តទាំងអស់នេះ ខ្ញុំនឹងនិយាយត្រលប់មកវិញនៅពេលក្រោយ។ ភាគីការពារក្តីរបស់លោក ខៀវ សំផន បានលើកឡើងកាលពីម្សិលមិញថា ទាក់ទងទៅនឹងការសង្ខេបនេះគឺថា សូមឲ្យអ្នកនិពន្ធហ្នឹងត្រូវបានស្តាប់យកចម្លើយ គឺថាអ្នកនិពន្ធឈ្មោះ ដែលឈ្មោះរហស្សនាមគឺថា P037 នៅក្នុងបញ្ជីអ្នកជំនាញរបស់សហព្រះរាជអាជ្ញា។ ហើយគឺថា E9/4.2 យើងគិតថា ភស្តុតាងទាំងអស់ដែលទទួលបាននៅក្នុងសំណុំរឿង០០១ នេះ គឺថាអាចស៊ីសង្វាក់ជាមួយនឹងខ្លឹមសារនៃការសង្ខេបទាំងអស់នេះ។

ទាក់ទងទៅនឹងការបោះពុម្ពផ្សាយផ្សេងៗទៀតរបស់បក្សកុម្មុយនីស្តដែលស្ថិតនៅក្នុងឧបសម្ព័ន្ធ២នេះ ខ្ញុំមានពាក្យសម្តីពីរបីម៉ាត់តែប៉ុណ្ណោះ គឺថាមានចំនួន១៩ ហើយការបោះពុម្ពផ្សាយទាំងអស់នេះ គឺថាបង្ហាញនូវតម្រុយ និងកាលបរិច្ឆេទដែលស៊ីគ្នាទៅនឹងសម័យហ្នឹង ហើយនិមិត្តរូបដូចមានកណ្តៀវ ហើយនិងញញួរនៅទំព័រដំបូងទំព័រចុងក្រោយ និងក្នុងអត្ថបទផងដែរ។

[០៩:៥១:៥០]

ហើយភាសាហ្នឹងក៏វាដូចគ្នាដែរ គឺថាបោះពុម្ពផ្សាយនៅសម័យនុ៎ង ហើយវាស៊ីនឹងមនោគមវិជ្ជានៃសម័យនុ៎ង។ ហើយការយើងអានឯកសារហ្នឹងទៅ គឺថាយើងយល់ថាគឺជាការផ្សព្វផ្សាយទៅដល់ក្នុងជួរបក្ស នៅក្នុងជួរនយោបាយដូចជា លក្ខន្តិកៈ ឬក៏ផែនការ។ ឧទាហរណ៍ដូចជា៖ ផែនការបួនឆ្នាំជាដើម។ គោលបំណងគឺថាគឺធ្វើយ៉ាងណា ដើម្បីគ្រប់គ្រងសារទាំអស់ដែលធ្វើដោយបក្សផ្ទាល់។ ទាក់ទងទៅនឹងការបោះពុម្ពផ្សេងទៀត ខ្ញុំសូមយោងទៅនឹងកថាខណ្ឌ៤៩ និង៥០ ឯកសារ E ដែលមានព័ត៌មានលម្អិតនៅក្នុងឯកសារនេះ។ ទាក់ទងទៅនឹងសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាថាមានឯកសារមួយចំនួន មានសំណៅពីរនៃ*ដកខ្សែម៉ង់* នៃឯកសារពីរដែលថាបានលើកឡើង-- វាអាចថាជាឯកសាររបស់គណៈមជ្ឈិម ឬក៏របស់ការិយាល័យ៨៧០។ សេចក្តីណែនាំនេះ គឺថានិយាយអំពីការកម្ទេចខ្មាំង ប្រយុទ្ធជាមួយខ្មាំងយួន ក្នុងអព្ភន្តរហើយនិងជារបាយការណ៍ដែលគេធ្វើទៅដល់មជ្ឈិមបក្ស។

[០៩:៥៣:២១]

អ៊ីចឹងការប្រើពាក្យពេចន៍គេប្រើនោះ គឺថាយើងមានភាពស៊ីសង្វាក់ដែលមិនអាចឲ្យយើងធ្វើសង្ស័យថា ឯកសារទាំងអស់នេះមិនមានភាពគួរឲ្យទុកចិត្តបាន ពីព្រោះថាសាក្សីទាំងអស់មាន ក៏បានលើកឡើងដែរថា ឯកសារ៤៤ E158។ ហើយសេចក្តីណែនាំរបស់បក្សផ្សេងទៀតរបស់បក្សនោះក៏បានបញ្ចូលនៅក្នុងសំណុំរឿង០០១ ផងដែរ។

ផ្នែកទីពីរ នៃការថ្លែងការណ៍របស់ខ្ញុំទាក់ទងទៅនឹងឧទាហរណ៍ដែលបង្ហាញពីការស៊ីសង្វាក់ភាពស៊ីសង្វាក់នៃឯកសារដែលនៅក្នុងឧបសម្ព័ន្ធ២នេះ។ ខ្លឹមសារនៃឯកសារទាំងអស់នេះ គឺថាត្រូវបញ្ជាក់ដោយប្រភពឯកសារផ្សេងទៀត ហើយឯកសារ-- ប្រភពទាំងអស់នេះ គឺថានិយាយអំពីព្រឹត្តការណ៍ពីព័ត៌មាន អ្វីដែលកើតឡើងក្នុងសម័យនោះដែរ។ ដូច្នេះ-- ហើយឯកសារទាំងអស់នេះសុទ្ធតែ គួរឲ្យជឿជាក់បាននៅក្នុងបរិបទសម័យនោះ។

[០៩:៥៤:៣៧]

អ៊ីចឹងខ្ញុំសូមលើកយកឧទាហរណ៍បីមកជម្រាបជូន៖ ឧទាហរណ៍ទាក់ទងទៅនឹងឧបសម្ព័ន្ធ២ និង៣ មានកំណត់ហេតុរបស់គណៈអចន្ត្រៃយ៍នៃពាយព្យ គឺឯកសារ IS13.1។ ខ្ញុំនឹងផ្ទៀប ប្រៀបធៀប ឯកសារនេះទៅនឹងការបោះពុម្ពផ្សាយ របស់បក្សដែលមានចំណងជើងថា "ការពិនិត្យ ហើយនិងការគ្រប់គ្រង និងការបង្កើតនយោបាយ ហើយនិងការផលិតសេដ្ឋកិច្ច ហើយនិងការកំណត់វិស័យផ្សេងៗដែលត្រូវអភិវឌ្ឍន៍" ជាឯកសារដែលនៅឆ្នាំ៧៥ គឺថា D365/7.1.157។ គណៈអចិន្ត្រៃយ៍បានគូសបញ្ជាក់ នៅពេលដែលខ្លួនទៅធ្វើទស្សនកិច្ចនៅភូមិភាគពាយព្យថា "យើងពុំមានកម្លាំងពលកម្មគ្រប់គ្រាន់ទេ។ ដូច្នេះ ដើម្បីបង្កើនផលិតកម្ម ទោះបីជាយើងបន្ថែមបីបួនម៉ឺននាក់ក៏មិនគ្រប់ដែរ។ ឥឡូវនេះ យើងមានកម្លាំងមួយលាននាក់ ក៏ប៉ុន្តែយើងមិនបានផលិតបាន៥០ភាគរយផង។ អ៊ីចឹងត្រូវតែបន្ថែម ដល់បួនប្រាំសែននាក់ទៀតនោះបានទៅរួច"។

[០៩:៥៦:០៩]

នៅក្នុងឯកសារដែលខ្ញុំបានលើកឡើងនោះ ដែលចុះនៅថ្ងៃទី-- ខែកញ្ញា ឆ្នាំ១៩៧៥ យើងឃើញតួលេខហ្នឹង ដែលគណៈមជ្ឈិមបានលើកឡើងដែរ។ អ៊ីចឹងបានន័យថា ប្រភពទាំងពីរនេះស៊ីសង្វាក់គ្នា។ នៅក្នុងឯកសារហ្នឹងមានលើកឡើងដូចតទៅនេះ "យើងត្រូវតែបែងចែកប្រជាជនទៅតាមតម្រូវការនៃផលិតកម្ម ត្រូវរៀបចំធ្វើយ៉ាងណាដើម្បីឲ្យឆ្លើយតបនឹងតម្រូវការបាន។ យើងត្រូវធ្វើការបែងចែកឲ្យមានតុល្យភាព កុំឲ្យវាផ្អៀងទៅម្ខាងណាមួយ។ នៅក្នុងភូមិភាគនិរតី គឺថាត្រូវបន្ថែមប្រាំសែននាក់កម្លាំងពលកម្មប្រាំសែននាក់ទៀត"។ លេខ *នុយមីរ៉ូ* ERN ភាសាបារាំងគឺថា 00543760-- អង់គ្លេស 005523594 ជាភាសាខ្មែរ 0007296 យើងឃើញថា មានប្រភពព័ត៌មានផ្សេងគ្នា ដែលថា ស៊ីសង្វាក់គ្នា អ៊ីចឹងធ្វើឲ្យឯកសារទាំងពីរនេះគួរឲ្យទុកចិត្តបាន។ ខ្ញុំគិតថា នៅក្រុមភាគីការពារក្ដីនៅក្នុងឯកសារ E131/1 នៅក្នុង *អាន់និច* ឧបសម្ព័ន្ធ២ ឯកសារដែលចុះខែកញ្ញា ឆ្នាំ១៩៧៥ ដែលទាក់ទងទៅនឹងសាក្សីទីមួយហ្នឹង។

[០៩:៥៨:០៤]

ឧទាហរណ៍ទីពីររបស់ខ្ញុំ ទាក់ទងទៅនឹងសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា លើសេចក្ដីសម្រេចរបស់មជ្ឈិមបក្ស គឺថាឯកសារ E3/12, IS6.3 ចុះថ្ងៃទី៣១ មីនា ឆ្នាំ១៩៧៦ គឺនៅទំព័រនេះមួយ គេនិយាយអំពីគឺថា ការជ្រើសរើសស្រុកគំរូមួយ ដើម្បីបង្កើនទិន្នផលបីតោនក្នុងមួយហិចតា ដើម្បីជ្រោងទង់បដិវត្ត។ ដូច្នេះវាបញ្ជាក់អំពីសេចក្ដីសម្រេចរបស់គណៈមជ្ឈិមសម្រាប់ឆ្នាំ១៩៧៦ គឺឯកសារ

ចុះថ្ងៃទី៦ មិថុនា ឆ្នាំ១៩៧៧ D2-15.4 គឺថា ទង់ក្រហមកិត្តិយសដែលចុះឆ្នាំទី៧៦ នេះត្រូវបានប្រគល់ជូនទៅស្រុកចំនួនបី គឺស្រុកត្រាំកក់មួយ ឈ្មោះទង់នេះបានផ្លាស់ប្តូរបន្តិច ប៉ុន្តែគោលការណ៍មិនខុសពីសេចក្តីសម្រេចចុះខែមីនា ឆ្នាំ១៩៧៦ នោះទេ។

[០៩:៥៩:៣៨]

នួន ជា ខ្លួនឯងក៏ស្គាល់ថា ទង់បក្សក្រហមនេះត្រូវបានផ្តល់ចេញពីបក្សទៅដល់ស្រុកភូមិណាដែលមានកម្លាំងផលិតខ្ពស់ជាងគេ។ ឯកសារ 3/2 សេចក្តីសម្រេចរបស់គណៈមជ្ឈិមបានកំណត់ឲ្យមានថ្ងៃរំឭកព្រឹត្តិការណ៍សំខាន់ៗ ឧទាហរណ៍ដូចជា នៅឆ្នាំខួបកំណើតកងទ័ពបដិវត្តន៍ ឬក៏ខួបរដ្ឋធម្មនុញ្ញ។ អ៊ីចឹង រាល់កាលបរិច្ឆេទទាំងអស់នេះ សុទ្ធតែស៊ីសង្វាក់គ្នា ឬគាំទ្រទៅដល់សេចក្តីប្រកាស ឬក៏សក្ខីកម្ម ឬក៏សៀវភៅថ្មីៗ ដែលសរសេរដោយលោក ខៀវ សំផន ឬក៏នៅក្នុងការបោះពុម្ពផ្សាយផ្សេងៗទៀតនៃទង់បដិវត្ត ឬក៏យុវជន យុវនារីបដិវត្ត។ អ៊ីចឹង នៅក្នុងសេចក្តីសម្រេចរបស់មជ្ឈិមបក្សដដែល គឺថា E3/12 ទាក់ទងទៅនឹងការរៀបចំការិយាល័យរដ្ឋ ឧទាហរណ៍តួនាទីរបស់សមមិត្តនួន ឬក៏គណៈមជ្ឈិម សមមិត្ត ហែម-- ខៀវ សំផន, សមមិត្ត វ៉ាន់-- អៀង សារី ដែលជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងកិច្ចការបរទេស។

[១០:០១:២៣]

សេចក្តីសម្រេចរបស់មជ្ឈិមបក្សនេះ គឺថាត្រូវគាំទ្រដោយសក្ខីកម្មជាច្រើន។ ដូច្នេះមានឯកសារមួយនៅក្នុងឧបសម្ព័ន្ធទី៣ ដែលជាសេចក្តីសង្ខេបរបស់កិច្ចប្រជុំមួយ ដែលមានចំណងជើងថា “ឯកសារស្តីអំពីមហាសន្និបាតនៃសភាតំណាងប្រជាជនកម្ពុជា” ដែលចុះនៅថ្ងៃទី១១ ខែមេសា ឆ្នាំ៧៦ IS13.13 ហើយ-- គឺថាមានបញ្ចូលឈ្មោះជាច្រើននៅក្នុងឯកសារនេះផងដែរ។ ដូច្នេះ គឺថាឯកសារទាំងអស់នេះវាស៊ីសង្វាក់គ្នាគាំទ្រដល់គ្នាទៅវិញទៅមក គឺបង្ហាញថា នួន ជា ជាអ្នកសរសេរ ហើយក្នុងឋានៈខ្លួនជាប្រធានសភាតំណាងប្រជាជនកម្ពុជា គឺថាមានឯកសារ IS13.13 នៅ--។ សេចក្តីប្រកាសសារព័ត៌មាននេះបានប្រកាសផ្សាយតាមវិទ្យុសុទ្ធសាធតែម្តង ហើយនៅក្នុងវិទ្យុ អេហ្វ.បេ.អ៊ី.អេស មាននិយាយថា ហ៊ូ នឹម ជាអ្នកតំណាងឲ្យសភាតំណាងប្រជាជនកម្ពុជា ឯកសារ D62 ចុះឆ្នាំ១៩៧៦។

[១០:០៣:១៨]

លេខឯកសារ IS13.7 ហើយនិង IS13.8 ដែលនិយាយអំពីការបោះឆ្នោតដែលនឹងមកដល់នៅខែមីនា ឆ្នាំ១៩៧៦ ហើយនិងផែនការឃោសនាពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយនៃការបោះឆ្នោតនេះ។

ដូច្នេះយើងបានឃើញហើយថា ឯកសារជាច្រើន គឺថាបានបញ្ជាក់អំពីភាពអាចយកជឿជាក់បាន ហើយ និងយថាភាពនៃឯកសារដែលបានបង្ហាញជូនលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំនឹងបញ្ចប់ដោយឆាប់រហ័ស ដោយលើកនូវឧទាហរណ៍ទីបី។ នៅក្នុងឯកសារ-- នៅក្នុងលេខពីរ និងលេខបី នៅក្នុងឆ្នាំ ៧៦ របស់ទស្សនាវដ្តីទង់បដិវត្ត គឺលេខ D243/2.1.3 គឺឯកសារនេះមានចំណងជើងថា "មានការទុកចិត្ត ហើយនិងការអនុវត្តនូវគោលនយោបាយ ដែលតំណាងឲ្យយុទ្ធសាស្ត្រថ្មីរបស់បក្សកុម្មុយនីស្តកម្ពុជា"។ ហើយជជែកអំពីចំណុចពិសេស ដែលពាក់ព័ន្ធទៅនឹងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា។ ហើយលក្ខន្តិកៈនេះ មានលេខ D246/3.1 ហើយនៅដំបូងនៅក្នុងលក្ខន្តិកៈនេះ គឺក្នុងកថាខណ្ឌទីបី គឺមានអត្ថបទមួយ ដែលលើកឡើងទាំងស្រុង ដែលហើយដែលត្រូវទស្សនាវដ្តីនោះ គឺបានលើកឡើងទាំងស្រុងម្តង គឺវាអត្ថបទនេះ វាពន្យល់អំពីទិសដៅនៃសមាជិករបស់បក្ស។

ប្រសិនបើឯកសារទាំងពីរនេះ មិនមានភាពអាចទុកចិត្តបាននោះ គឺគេមិនអាចសំអាងយោងទៅលើឯកសារទាំងស្រុងនោះមកចុះផ្សាយនោះទេ វាមិនសមហេតុផលនោះទេ។ ហើយឯកសារលក្ខន្តិកៈ ឬក៏ទស្សនាវដ្តីនេះ គឺជាឯកសារផ្លូវការរបស់បក្ស ហើយគឺសម្រាប់តែសមាជិកបក្សតែប៉ុណ្ណោះ។

ដូច្នេះ វាជាការស្រមើស្រមៃទេដែលគិតថាឯកសារនេះ មិនមានតម្រុយជាក់លាក់ច្បាស់លាស់ដែលអាចទុកចិត្តបាននោះ។ ដូច្នេះ ជាការសន្និដ្ឋានទៅលើឧបសម្ព័ន្ធ២នេះ គឺយើងសង្កេតឃើញថា វាមានលក្ខខណ្ឌពាក់ព័ន្ធច្បាស់លាស់ ហើយមិនមានភាពជឿជាក់ ដើម្បីអាចឲ្យឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ២ នេះ គឺថាអាចត្រូវបានវិនិច្ឆ័យថាអាចទទួលយកបានដោយអង្គជំនុំជម្រះ។

[១០:០៥:៥៥]

ឯកសារដែលដាក់ជូនអង្គជំនុំជម្រះ គឺថាមិនត្រូវថាវាយតម្លៃដាច់ដោយឡែកពីគ្នាទេ គឺត្រូវតែវាយតម្លៃឲ្យមានពាក់ព័ន្ធគ្នាជាមួយនឹងភស្តុតាងផ្សេងទៀត ដែលធ្វើឡើង ដូចជាមានសក្ខីកម្មជាដើម។ ដូច្នេះ តម្លៃជាភស្តុតាងដែលនឹងផ្តល់ឲ្យឧបសម្ព័ន្ធនេះ គឺថានឹងត្រូវសម្រេចដោយតុលាការនៅពេលដែលភស្តុតាងទាំងអស់ត្រូវបានជជែកពិភាក្សា ហើយនិងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយនិងមានសាក្សី អ្នកជំនាញ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានស្តាប់ចម្លើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា។ ជាបន្តអង្គជំនុំជម្រះប្រគល់វេទិកាទៅសហមេធាវីនាំមុខ តំណាង

ដើមបណ្តឹងរដ្ឋប្បវេណីដែលមានមេធាវីទទួលសិទ្ធិកាលពីម្សិលមិញ។

លោក វ៉ែន ពៅ! ឡើងមកធ្វើការអំណះអំណាងតបទៅនឹងការជំទាស់របស់មេធាវីការពារក្តី ហើយមេធាវីនាំមុខមានរយៈពេល១៥នាទីក្នុងការធ្វើអំណះអំណាងតបនេះ។

សូមអញ្ជើញ!

**លោក វ៉ែន ពៅ៖**

បាទសូមអរគុណលោកប្រធាន។ ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ និងសូមថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ និងសូមគោរពអង្គសវនាការទាំងមូល។

ពាក់ព័ន្ធទៅនឹងប្រធានបទ ដែលយើងនឹងលើកឡើងចំពោះភាគីខាងខ្ញុំនៅពេលនេះ ក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបាទសូមគាំទ្រទាំងស្រុងចំពោះទឡ្ហីករណ៍ ក៏ដូចជាអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលបានលើកឡើងកន្លងមកនេះ។ ប៉ុន្តែខ្ញុំមានការអង្កេតមួយចំនួនពាក់ព័ន្ធទៅនឹងអត្ថបទបោះពុម្ពផ្សាយ និងសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមាននៅក្នុងឧបសម្ព័ន្ធ២ នេះ។

[១០:០៧:៥២]

ចំពោះអត្ថបទបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលយើងបានដឹងហើយដែលហៅថាទស្សនាវដ្តីទង់បដិវត្ត ក៏ដូចជាទស្សនាវដ្តីយុវជន និងយុវនារីបដិវត្ត ដែលឯកសារនេះត្រូវបានបោះពុម្ពផ្សាយ និងធ្វើឡើងតាំងតែពីមុនឆ្នាំ១៩៧៥ ហើយបានបន្តធ្វើជាហូរហែរហូតដល់ខែវិច្ឆិកា ឆ្នាំ៧៨ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងដូច្នោះមែន។

ឯកសារបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាំងនេះ គឺជាឯកសារផ្លូវការ ជាសារមួយដ៏សំខាន់ដែលនិយាយអំពីគោលនយោបាយមាគ៌ាបក្ស ព័ត៌មានផ្សេងៗពាក់ព័ន្ធទៅនឹងសកម្មភាពរបស់បក្ស សកម្មភាពកងទ័ព សកម្មភាពបង្កបង្កើនផល និងមានរូបថតមួយចំនួនដែលដាក់ក្នុងទស្សនាវដ្តីទាំងពីរ គឺមានដែលសហព្រះរាជអាជ្ញាបានបង្ហាញហើយ គឺមានរូបថតកម្មករ កសិករ ហើយនៅក្នុងខ្លឹមសារនៃទស្សនាវដ្តីទាំងពីរនេះផងដែរ ក៏បាននិយាយអំពីផែនការការពារ និងផែនការកម្ទេចខ្មាំង និងការពង្រឹងបក្សទាំងមូល។

[១០:០៩:០៣]

អត្ថបទបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីទាំងពីរនេះផងដែរ ក៏ជាព័ត៌មាន ហើយក៏ជាសារមួយដ៏

សំខាន់ដែលបានឲ្យដល់កម្មាភិបាលគ្រប់ជាន់ថ្នាក់នៅក្នុងរបបខ្មែរក្រហមទាំងមូលផងដែរ។ ហើយឯកសារទាំងនេះក៏មានចែកផ្សព្វផ្សាយដល់កម្មាភិបាលនៅគ្រប់ជាន់ថ្នាក់នៅតាមសហករណ៍នានា តាមគណៈភូមិ គណៈស្រុក គណៈតំបន់ ឬក៏ភូមិភាគ បានអាន ឬក៏បានដឹងឯកសារនេះផងដែរ។ ជាក់ស្ដែងកាលពីសវនាការសប្ដាហ៍មុន ថ្ងៃទី១០ ខែមករា ឆ្នាំ២០១២កន្លងមកនេះ សូម្បីតែជនជាប់ចោទ នួន ជា ផ្ទាល់ក៏គាត់បានទទួលស្គាល់ និងបានបញ្ជាក់ផងដែរថាបក្សកុម្មុយនីស្តកម្ពុជាពិតជាបានបោះពុម្ពផ្សាយទស្សនាវដ្ដីទង់បដិវត្តនេះតាំងតែពីមុនឆ្នាំ១៩៧៥មក ដែលមាននៅក្នុងលេខឯកសារគឺ E1/24.1 ហើយ ERN ជាភាសាខ្មែរលេខ 00766622 ERN ជាភាសាអង់គ្លេស 00767605 និងERN ជាភាសាបារាំង 00767490 ហើយឯកសារនេះផងដែរ ជនជាប់ចោទ នួន ជា ក៏បានបញ្ជាក់ផងដែរថាបានបោះពុម្ពផ្សាយនៅពេលដែលបន្ទាប់ពីជ័យជម្នះ ១៧ មេសា មក ក្រោយពេលស្វែងរកអ្នកដែលមានសមត្ថភាព ឬក៏ជំនាញខាងបោះពុម្ពផ្សាយ គឺនៅក្នុង ERN ជាភាសាខ្មែរ 00766626 ERNជាភាសាអង់គ្លេស 00767611 និងERNជាភាសាបារាំង 00767495។

ហេតុដូច្នេះ ឯកសារបោះពុម្ពផ្សាយទស្សនាវដ្ដីទាំងពីរនេះ ពិតជាបានបោះពុម្ព និងធ្វើឡើងត្រឹមត្រូវមែនហើយមានយថាភាព។ ឯកសារនេះ អាចទទួលយកបាន គួរទុកចិត្តបាន និងមានភាពពាក់ព័ន្ធ ហើយពិសេសមានប្រភពនៃឯកសារច្បាស់លាស់ ម្យ៉ាងវិញទៀត ខ្លឹមសារទាំងមូលនៃអត្ថបទបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីទាំងពីរនេះ ពាក់ព័ន្ធគ្នាទៅនឹងដីកាដំណោះស្រាយយ៉ាងច្បាស់។ ចំណែកសេចក្ដីណែនាំផ្សេងៗរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមាននៅក្នុងឧបសម្ព័ន្ធ២ នេះ ទាំងអស់គឺជាសេចក្ដីណែនាំលាយលក្ខណ៍អក្សរដែលមាននៅក្នុងឧបសម្ព័ន្ធនេះ គឺចេញមកពីមន្ទីរ ឬការិយាល័យ៨៧០ ដែលជាស្ថាប័នកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា គឺបានន័យថា សំដៅលើគណៈមជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍ ដែលបានចេញសេចក្ដីណែនាំនេះ មានអានុភាពអនុវត្តទូទាំងប្រទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។

[១០:១១:៥៨]

សេចក្ដីណែនាំនេះទៀតសោត មានអានុភាពអនុវត្តខ្លាំងក្លាណាស់ដល់គ្រប់អ្នកថ្នាក់ក្រោមត្រូវតែគោរព និងអនុវត្តតាមជាដាច់ខាត។

ហេតុដូច្នេះហើយ ខ្ញុំយល់ឃើញថាសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជានេះ ពិតជាមានតម្លៃអាចស៊ីសង្វាក់គ្នា មានភាពជឿជាក់ទុកចិត្តបាន អាចទទួលយកបាន និងពាក់ព័ន្ធ ហើយជាឯកសារ

ដែលមានប្រភពច្បាស់លាស់។ ខ្ញុំសូមឆ្លើយតបតែនឹងមួយទៀត ចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារដែលបាន-- ដែលតែងតែលើកឡើងដដែលៗថាដើម្បីឲ្យមានយថាភាពនៃឯកសារ ត្រូវតែពិនិត្យឯកសារច្បាប់ដើមនោះ។ ត្រង់ចំណុចនេះ មិនមានការហាមឃាត់ជាទូទៅណាមួយដែលប្រឆាំងនឹងការទទួលយកឯកសារច្បាប់ចម្លងនោះឡើយ។ លើកលែងតែភាគីដែលជាអ្នកជំទាស់ ត្រូវបង្ហាញភស្តុតាងឲ្យច្បាស់ថា ឯកសារចម្លងនោះត្រូវបានថតចេញពីឯកសារដើម ដែលមិនពិតប្រាកដ ឬក៏ក្លែងក្លាយ។ ម្យ៉ាងវិញទៀត ការអនុវត្តកន្លងមក ចំពោះឯកសារច្បាប់ចម្លងនេះ នៅតុលាការអន្តរជាតិព្រហ្មទណ្ឌមួយចំនួន ក៏គេមានលក្ខណៈទទួលយកឯកសារច្បាប់ចម្លងដែលមានស្ថានភាពប្រហាក់ប្រហែលនឹងស្ថានភាពបច្ចុប្បន្នរបស់តុលាការយើងនេះដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ ខ្ញុំទើបតែរកឃើញនៅក្នុងវេបសាយរបស់ខាងយូណេស្កូ គេមានរូបថតមួយអំពីរូបក្របមុខនៃទង់ទស្សនាវដ្ដីបដិវត្តជាពណ៌ធម្មជាតិ។

តើលោកប្រធានអនុញ្ញាតឲ្យបង្ហាញបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានផ្ដល់ពេលវេលា ហើយនិងជម្រាបជាមុន អំពីការជំទាស់របស់ភាគី ហើយភាគីអាចប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីយកមកធ្វើការបញ្ជាក់អះអាងនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីផានា ឬក៏ប្រឹងប្រែងដើម្បីធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះ មាននូវការជឿទុកចិត្ត ដោយមានការភស្តុតាងគាំទ្រដល់អំណះអំណាងរបស់ខ្លួន។

នេះជាវិធីសាស្ត្រ ឬក៏បច្ចេកទេសក្នុងការតទល់គ្នា ចំពោះភាគី។ ហើយរហូតមកដល់ពេលនេះទើបមកសួរអង្គជំនុំជម្រះទៅវិញ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៦:៤៦]

លោកមានបញ្ហាអីផ្សេងទេ លោកមេធាវីការពារក្ដីខៀវ សំផន? បើចំពោះករណីលើកឡើងអម្បាញ់មិញរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះគិតថាមិនចាំបាច់ទេ។

**លោក គង់ សំអុន៖**

បាទ ខ្ញុំចង់ឆ្លើយតបប៉ុណ្ណេះ បើលោកចៅក្រម លោកប្រធានថាមិនបាច់ទេ ខ្ញុំបាទមិនចាំបាច់ឆ្លើយទេ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបញ្ចប់នូវការធ្វើអំណះអំណាងតប របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះឯកសារឧបសម្ព័ន្ធA2 នេះត្រឹមនេះ ហើយបញ្ហាផ្សេងទៀត គឺត្រូវរៀបចំនូវបច្ចេកទេស និងវិធីសាស្ត្រក្នុងការបង្ហាញឯកសារផ្សេងៗឲ្យបានជាក់ច្បាស់ ហើយត្រៀមលក្ខណៈជាមុន ពីព្រោះអ្វីៗទាំងអស់អង្គជំនុំជម្រះសុទ្ធតែប្រាប់ទៅជូនដំណឹងដល់ភាគីជាមុន អំពីកាលវេលាដែលត្រូវធ្វើការពិភាក្សាដេញដោល ដោយអនុស្សរណៈ ឬក៏ដោយដីកាផ្ទាល់មាត់នាពេលសវនាការ។

ហើយឥឡូវនេះដំណើរការសវនាការ នៅពេលព្រឹកនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៩ ដល់ម៉ោង ១០:៤៨ នាទី)*

[១០:៤៨:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយមុននឹងចាប់បន្តការជំទាស់របស់មេធាវីទាំងបីក្រុមទៅឯកសារឧបសម្ព័ន្ធ T3 អង្គជំនុំជម្រះសូមឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ដែលបានលើកឡើងកាលពីព្រឹកមិញពាក់ព័ន្ធទៅនឹង អ៊ីម៉ែល របស់មន្ត្រីច្បាប់ជាន់ខ្ពស់អំពីបំណងរបស់អង្គជំនុំជម្រះ ក្នុងការស្តាប់សក្ខីកម្មសាក្សីដែលជាមន្ត្រីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

អង្គជំនុំជម្រះ សូមជម្រាបដល់មេធាវីការពារក្តី នួន ជា និងភាគីដទៃទៀតនៃរឿងក្តីនេះ ព្រមទាំងសាធារណជនឲ្យបានជ្រាបថា ដោយមានបញ្ហាចំពោះមុខ និងសំណើរបស់មេធាវីការពារក្តី ភាគីអង្គជំនុំជម្រះនឹងកោះអញ្ជើញសាក្សី TCW-766 មកផ្តល់សក្ខីកម្មនៅថ្ងៃច័ន្ទ ទី២៣ ខែមករា ឆ្នាំ២០១២

គឺដើមសប្តាហ៍ក្រោយនេះ។

[១០:៥០:១៧]

ហើយគោលបំណងនៃការស្តាប់នុ៎ងគឺពាក់ព័ន្ធទៅនឹងបញ្ហាឯកសារនៅមជ្ឈមណ្ឌល-- ដែលមានប្រភពពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចអ្វីដែលភាគីបានលើកឡើងតវ៉ាជំទាស់គ្នានៅក្នុងកិច្ចពិភាក្សាប៉ុន្មានថ្ងៃកន្លងមកនេះ។ ហើយកិច្ច ការស្តាប់ចម្លើយសាក្សីរូបនោះនឹង ដោយចាប់ផ្តើមពីអង្គជំនុំជម្រះសាលាដំបូងមុន ហើយបន្តបន្ទាប់តាមលំដាប់ គឺសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយបន្ទាប់មកគឺមេធាវីការពារក្តីទាំងបីក្រុមដែលតាមលំដាប់ពីមេធាវី នួន ជា អៀង សារី ហើយនិងចុងក្រោយមេធាវី ខៀវ សំផន។ ដូច្នេះសូមភាគី និងម្ចាស់សំណើជ្រាប។

ជាបន្តទៅនេះ យើង-- សូមអញ្ជើញ!

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ប្រហែលជាខ្ញុំសូមឲ្យមានការបញ្ជាក់បន្ថែមទៀត ថាតើនៅពេលណាប្រសិនបើអាច ដែលត្រូវអញ្ជើញលោក យុ ឆាំង នោះ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ សូមជម្រាបថា ដោយសាក្សី W-766 ក៏ជាមន្ត្រីជាន់ខ្ពស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះចំពោះការកោះហៅលោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាមកផ្តល់សក្ខីកម្មនៅពេលណា ឬក៏ធ្វើតាមបែបណានោះ គឺអង្គជំនុំជម្រះនឹងពិនិត្យពិចារណា នឹងជម្រាបដល់ជូនភាគីក្រោយពេលដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សី W-766 រួចហើយ។

[១០:៥២:៣៩]

សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំគ្រាន់តែចង់ជម្រាបជូនអង្គជំនុំជម្រះថាមេធាវី ហ្វីលីពីន នឹងធ្វើការអន្តរាគមន៍នៅក្នុងឧបសម្ព័ន្ធ៣ នេះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះនឹងអនុញ្ញាតតាមការស្នើសុំរបស់សហមេធាវីនាំមុខ ក្នុងការផ្ទេរសិទ្ធិទៅឲ្យមេធាវីការពារក្តី អឺ! មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ជាបន្តយើងធ្វើសវនាការលើការជំទាស់ពាក់ព័ន្ធនឹងឯកសារ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលអង្គជំនុំជម្រះសាលាដំបូងបានមានបំណងដាក់នៅចំពោះមុខខ្លួន នៅថ្ងៃទី-- នៅពេលនេះដែរ យើងនឹងបន្តការស្ដាប់ការជំទាស់ពាក់ព័ន្ធនឹងឯកសារក្នុងឧបសម្ព័ន្ធ៣ និង៤។

[១០:៥៣:៤៥]

ប្រសិនបើអាចធ្វើទៅបានដំបូងនេះនឹងស្ដាប់ការជំទាស់លើឯកសារនៅក្នុងឧបសម្ព័ន្ធA3។ ក្រុមមេធាវីការពារក្ដីទាំងបីក្រុមមានពេលវេលាមួយម៉ោងក្នុងការធ្វើការជំទាស់ ហើយពេលវេលាមួយម៉ោងនេះ គឺមេធាវីអាចបែងចែកដោយខ្លួនឯងនៅក្នុងក្រុមនីមួយៗ-- ទៅឲ្យក្រុមនីមួយដោយខ្លួនឯងក៏បាន។ ហើយប្រសិនបើមេធាវីការពារក្ដីទាំងបីក្រុមគ្មានការបែងចែកទេនោះ មេធាវីការពារក្ដីក្រុមនីមួយៗមានពេលវេលា ២០នាទី នៅក្នុងការឡើងបង្ហាញពីការជំទាស់របស់ខ្លួន។

ជាដំបូងនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្ដី នួន ជា ប្រសិនបើមានការជំទាស់ទៅលើឯកសារឧបសម្ព័ន្ធ A3 នេះ សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

បន្ទាប់ពីការស្ដាប់ការជជែកវែកញែកនូវឧបសម្ព័ន្ធ១ និង២ រួចមក។ ឧបសម្ព័ន្ធ៣ នេះ ខ្លួនខ្ញុំមានខ្លី ហើយនិងសូមបញ្ចាំងស្លាយពីរ។ ក្រោយពីបានពិនិត្យលើឯកសារ A3 ជាភាសាខ្មែរនេះរួចមក ក្រុមយើងខ្ញុំសង្កេតឃើញថា គ្រប់ឯកសារដើមជាភាសាខ្មែរនេះសុទ្ធតែមានសរសេរដោយដៃលើឯកសារ មានន័យថា ចារនៅលើឯកសារនោះ។ ចារ ខ្វៀក អក្សរខ្វៀក ជាពិសេសច្រើនជាអក្សរឡាតាំងផង, ជាភាសាអង់គ្លេស, ភាសាវៀតណាម, ខ្មែរនិងវៀតណាម។ លើសពីនេះក៏មានការលុប និងសរសេរបន្ថែមលើឯកសារទៀតផង។ ការសរសេរបន្ថែមនេះ គឺការសង្ស័យមួយទៅលើភាពពិតប្រាកដនៅលើឯកសារ។ ដូចនេះ យើងៗខ្ញុំចាំបាច់ត្រូវតែរកឲ្យឃើញថា តើការសរសេរបន្ថែមនេះ វាកើតក្រោយមកបន្ទាប់ពីឆ្នាំ ១៩៧៩ ឬក៏ជាភាពដើមរបស់វា។

[១០:៥៦:២៣]

មួយវិញទៀត ឯកសារភាគច្រើនមានគុណភាពអន់ ហើយភាគច្រើន ឬផ្នែកខ្លះរបស់ឯកសារមិនអាចយល់បានទាល់តែសោះ។ ដើម្បីដោះស្រាយបញ្ហានេះបាន យើងខ្ញុំនៅតែរក្សាជំហររបស់យើងខ្ញុំដដែលក្នុងការកោះហៅអ្នកទទួលខុសត្រូវ ឌី.ស៊ី.ខេម ដើម្បីមកបញ្ជាក់ពីការចារ ចំណារនៅលើឯកសារ

ទាំងនុំង បន្ថែម ហើយនិងផ្តល់នូវឯកសារច្បាប់ដើមដល់អង្គជំនុំជម្រះ ដើម្បីពិនិត្យជាយថាភូតរបស់វា។

បើពុំដូចនេះទេ យើងខ្ញុំនៅតែរក្សាជំហរដដែលក្នុងការជំទាស់ទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលដាក់ជូនដោយការិយាល័យសហព្រះរាជអាជ្ញានេះ។

ខ្ញុំគិតថា១ ការអញ្ជើញមកចំពោះមុខតុលាការចំពោះការ-- អ្នកដឹកនាំរបស់ ឌី.ស៊ី.ខេម មិនមានបញ្ហាអ្វីដែលធ្វើឱ្យគាត់មិនអាចមកបាននោះទេ។ ហើយកាន់តែច្បាស់ទៀតនោះ គឺជាការ កាលពីម្សិលមិញគាត់បានបញ្ជាក់នៅក្នុងព្រឹត្តិបត្រព័ត៌មានភ្នំពេញប៉ុស្តិ៍ថា គាត់ចាំស្តាប់បញ្ជាពីតុលាការ ចំពោះវត្តមានរបស់គាត់នៅក្នុងសវនាការនេះ។

តទៅនេះ លោកប្រធាន ខ្ញុំសូមអនុញ្ញាតរាប់ពីឯកសារដែលផ្នែកខ្លះរបស់វាមិនអាចអានយល់បានដូចជា៖ ឯកសារ IS13.4, ឯកសារ 13.5, និង ឯកសារ 13.6 អានេះជាឯកសារមិនច្បាស់ ខ្ញុំ-- បើសិនលោកប្រធានអនុញ្ញាតសូមឱ្យបញ្ចាំងស្លាយនូវឯកសារ IS13.6 ដើម្បីជូនតុលាការមើលបានមើល។

[១០:៥៨:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

*(ការដាក់បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍)*

[១០:៥៩:១៧]

**លោក សុន អរុណ៖**

នៅក្នុងឯកសារនេះតុលាការបានឃើញហើយ ចំណារសរសេរអក្សរភាគច្រើនឡាតាំង ហើយមិនសូវច្បាស់ មិនដឹងថាម៉េច? ហើយមិនដឹងអ្នកណាអ្នកចារនៅលើហ្នឹង ដែលមានគូសរង្វង់មូលក្រហមនេះ។ ហើយមានឯកសារបន្តទៅទៀតគឺ ឯកសារ D251/1, ឯកសារ IS13.8, ឯកសារ D248/6.1.1, ឯកសារ IS13.10, ឯកសារ IS13.11, ឯកសារ D248/6.1.3, ឯកសារ IS13.20, ឯកសារ IS13.21, ឯកសារ IS13.23 និងឯកសារ D248/6.1.18។ ខ្ញុំសូមតុលាការ សូមលោកប្រធានមេត្តាអនុញ្ញាតឱ្យចាក់បញ្ចាំងស្លាយនូវឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

មួយណា១?

**លោក សុន អរុណ៖**

សូមទោសម្តងទៀត! D248/6.1.18។

[១១:០០:៥៩]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត, សូមអញ្ជើញ!

*(ការដាក់បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍)*

**លោក សុន អរុណ៖**

ឯកសារទាំងពីរនេះ ដែលបានបង្ហាញនៅក្នុងស្លាយ តុលាការបានឃើញហើយ មិនច្បាស់លាស់ ហើយមិនមានដឹងថា មានន័យថាយ៉ាងម៉េច? ម្ល៉ោះហើយធ្វើការសន្និដ្ឋានមិនបាន។

មានឯកសារបួនទៀត សូមជម្រាបថាឯកសារ IS13.34, ឯកសារ IS13.39, ឯកសារ IS13.41 និងឯកសារ D366/7.1.340។

[១១:០២:២៦]

លោកប្រធាន ដោយសារតែពេលវេលាមិនអនុញ្ញាតខ្ញុំបាន និយាយបានច្រើន ខ្ញុំសូមបង្ហាញតែឯកសារពីរនេះទេដែលមិនច្បាស់ ហើយធ្វើការសន្និដ្ឋានមិនបាន។ ហេតុនេះ ខ្ញុំបាទជម្រាបតុលាការពេលនេះ កូនក្តីរបស់ខ្ញុំ នួន ជា នៅតែទទូចសុំឲ្យផ្តល់នូវឯកសារដើម ដើម្បីមកផ្ទៀងផ្ទាត់នឹងឯកសារថតចម្លងដែលតុលាការយកមកប្រើប្រាស់សព្វថ្ងៃនេះ ឲ្យទៅជាឯកសារមានយថាភាពពិតប្រាកដអាចទទួលយកបាន។

សូមអរគុណ! ខ្ញុំមាន-- សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណៗ លោកមេធាវី។

[១១:០៣:២៨]

**លោក ម៉ៃខល ផេសមិន៖**

យើងខ្ញុំច្បាស់ថា សហសេវិករបស់ខ្ញុំ សុន អរុណ បានបង្ហាញតែពីរឯកសារនោះទេ ហើយគាត់បានពន្យល់កថាខណ្ឌមួយចំនួននៅនឹងសេចក្តីដកស្រង់ គឺថាមិនអាចអាន។ ជាឧទាហរណ៍ ឯកសារទាំងអស់ដែលបានរាយបញ្ជីតាមលេខដែលបានយើងបានហ្នឹង គឺថាឯកសារខ្លះយើងមិនអាចអានបានទេ

លោកប្រធាន គឺអានមិនដាច់។ ហើយខ្ញុំនឹងជម្រាបជូនដោយសង្ខេប ដូចដែលតុលាការជ្រាបហើយថា យើងបានជំទាស់នៅនឹងឯកសារទាំងឡាយ ដែលចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយប្រកាន់ជំហរនេះ ហើយបញ្ជាក់ម្តងទៀតថា ឯកសារទាំងនោះ គឺមិនត្រូវទទួលយកបានទេ ដរាបណាតែបំពេញទៅតាមលក្ខខណ្ឌដូចយើងខ្ញុំបានស្នើ។ ហើយក៏មិនអាចយើងស្នើ-- មិនអាចចោទសួរបានអំពីការផ្តោះប្តូរ ឬក៏ថាខ្សែចង្វាក់នៃការកាន់កាប់ឯកសារនោះទេនោះ។ នេះហើយជាជំហរដែលខ្ញុំជូនតុលាការជ្រាប។

[១១:០៤:៤៤]

បញ្ហាដែលយើងនឹងត្រូវជួបប្រទះនោះ គឺថាតាមដែលយើងសំណើ គឺថាយើងជាបញ្ហាដែលយើងប្រឈមមុខ គឺថាយើងមិនអាចធ្វើបញ្ជីឯកសារទាំងអស់នោះបានទេ ដែលកើតចេញមក-- ដែលជាឯកសារចេញមកពី ឌី.ស៊ី.ខេម យើងមិនអាចធ្វើបញ្ជីលម្អិត ដែលផ្តល់ឡើងដោយមជ្ឈមណ្ឌលនេះដែលសហព្រះរាជអាជ្ញាគាត់ទទួលបាន ហើយដែលបានប្រើ ដោយសហចៅក្រមស៊ើបអង្កេតផងដែរ។ លុះត្រាតែអង្គជំនុំជម្រះបានចោទសួរទៅមន្ត្រីរបស់មជ្ឈមណ្ឌលនេះ ហើយនិងភាគីដែលបានសួរ ទើបយើងនឹងអាចរកឃើញ។

ឥឡូវនេះខ្ញុំចូលទៅដល់ការតម្កល់ការដាក់ឯកសារ ហើយខ្ញុំបានអានឯកសារដែលដាក់តម្កល់ក្នុងឆ្នាំនេះ គឺថាអាចនឹងពិនិត្យមើលភាពអាចទុកចិត្តបាននូវឯកសារនេះ ហើយគឺយើងមានបញ្ជីមួយប៉ុន្តែបញ្ជីនោះមិនពេញលេញទេ។ ព័ត៌មាននិយាយអំពីឯកសារ ហើយនិងភាពពាក់ព័ន្ធនឹងគឺថា ដែលបំណងនឹងដាក់ជូនតុលាការនោះគឺមិនច្បាស់ ហើយខ្ញុំស្នើដល់តុលាការថា ដើម្បីបង្គាប់ឲ្យព្រះរាជអាជ្ញាធ្វើបញ្ជី ឬក៏បន្ថែមទៅលើបញ្ជីដែលគាត់បានផ្តល់ឲ្យមកតុលាការនោះ ឲ្យកូឡោនពិសេសជាប្រភេទដែលចង្អុលបង្ហាញថា តើឯកសារនោះចេញមកពីមជ្ឈមណ្ឌលឯកសារដែរឬទេ? បើមិនដូច្នេះទេ យើងមិនមានប្រយោជន៍អ្វីនឹងត្រូវស្តាប់សាក្សីលេខ៧៦៦ ទេ នៅថ្ងៃច័ន្ទនោះ។

[១១:០៦:២៧]

ចំពោះចំណុចមួយដែលខ្ញុំបានលើកឡើងនោះ ខ្ញុំពិនិត្យមើលបញ្ជីនៃសាក្សីទាំងឡាយឯកសារ E209/4.3 ហើយខ្ញុំបានរៀបចំទៅនឹងឯកសារដើមដែលបានផ្តល់ឡើងពីមុនហ្នឹងនៅខែមេសា កាលពីឆ្នាំទៅ។ មិនមែនជាបញ្ជីសាក្សីទេ ជាបញ្ជីឯកសារ។ ខ្ញុំបានកត់សម្គាល់ថាឯកសារដើមនៃឯកសារទាំងនេះ ដែលដាក់នៅក្នុង*អេស្រ៊ី* (A3) នោះគឺថាដូចគ្នាប៉ះបិតទៅនឹងបញ្ជីដែលទាក់ទងទៅនឹងផ្នែកមួយនៃ

សវនាការនេះ ដូចដែលសហព្រះរាជអាជ្ញានិយាយ។ ប៉ុន្តែ បើយើងនិយាយមើលឯកសារទាំងនោះវិញ សហព្រះរាជអាជ្ញា ក៏សុំឲ្យតុលាការទទួលស្គាល់ថាវាមានសុពលភាព ហើយខ្ញុំនឹងពិនិត្យមើលបញ្ជីទាំងអស់ គឺថាបញ្ជីថ្មីដែលសហព្រះរាជអាជ្ញាបានស្នើឡើងហ្នឹង ខ្ញុំសូមអាន សុំឲ្យមូលហេតុជាយុត្តិកម្មដែលព្រះរាជអាជ្ញាលើកឡើងហ្នឹង ខ្ញុំនឹងពិនិត្យសេចក្តីយោងទាំងឡាយថាតើការជម្លៀសទីក្រុងភ្នំពេញ ការជម្លៀសទីក្រុង ទីប្រជុំជនផ្សេងៗទៀតនៅក្នុងសម័យកាលនោះ ឬក៏ការប្តូរទីកន្លែងប្រជាជនដែលគ្របដណ្តប់នៅក្នុងដំណាក់កាលទីពីរនៃសវនាការ ដោយបញ្ជូនប្រជាជនទៅភូមិភាគឧត្តរជាដើម។ ហើយខ្ញុំមើលឯកសារហ្នឹង ដែលសហព្រះរាជអាជ្ញាលើកឡើងហ្នឹង ប៉ុន្តែខ្ញុំមិនឃើញថាវាមានការទាក់ទងទេ ដោយសារអង្គហេតុទាំងនោះ ដូចជាលេខ៤៦ (សូមអភ័យទោស) គឺថាមានតែឯកសារពីរដែលទាក់ទង គឺថាឯកសារ៤៦ និងទី១ នៅក្នុងបញ្ជីចុងក្រោយដែលលេខមាន E9/41.3 ហើយដែលនិយាយអំពីការប្តូរទីតាំងប្រជាជនហ្នឹង គឺថាឯកសារហ្នឹង គឺវាមិនទាក់ទងចំពោះផ្នែកទីមួយនេះទេ។ ឯកសារផ្សេងទៀត ដែលថាអាចពាក់ព័ន្ធទាក់ទងទៅនឹងឋានានុក្រម។ រចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជាលេខ២ ដែលអាចនឹងទាក់ទង ដូចថាវារៀបរាប់អំពីការទទួលខុសត្រូវសមាជិកនៃគណៈអចិន្ត្រៃយ៍ ហើយមានឯកសារមួយទៀតដែលរៀបរាប់អំពីការទទួលខុសត្រូវរបស់ក្រសួងផ្សេងៗ ហើយគណៈអចិន្ត្រៃយ៍ផងដែរនោះ ជាគួរឲ្យចាប់អារម្មណ៍ គឺដែលរៀបរាប់ពីចំណុចទាំងនេះ ទំនាក់ទំនងនៃឋានានុក្រមរវាង-- ហើយចំណុចមួយទៀត១៩ មានតែឯកសារទាំងនេះទេ ដែលខ្ញុំអាចយល់ថា វាមានការទាក់ទងទៅនឹងសវនាការវគ្គទីមួយនេះ។ ចំពោះផ្សេងទៀតនោះ គឺមិនទាក់ទងទេ។

[១១:០៩:២០]

ខ្ញុំបញ្ជាក់ជូនតុលាការម្តងថ្មីទៀត គឺថាឯកសារទាំងអស់ គឺថាវាត្រូវតែមានឯកសារថ្មីៗ ហើយត្រូវតែបញ្ជាក់នៅក្នុងបញ្ជី ហើយថា គឺត្រូវបានកើតឡើងនៅក្នុងឆ្នាំ១៩៧៥ គឺ៤ខែ គឺក្រោយពីការរំដោះទីក្រុងភ្នំពេញ ដែលយើងនឹងស្នើដាក់ជូនដេញដោលក្នុងតុលាការក្នុងផ្នែកទីមួយនេះ។

ហើយចំណុចផ្សេងទៀតដែលពិនិត្យយើង គឺយើងនិយាយតែពីការផលិតស្រូវ ពាណិជ្ជកម្មជាមួយចិន សង្គ្រាមជាមួយវៀតណាម ហើយព័ត៌មានជាច្រើនជាមួយវៀតណាម។ ការវាយខ្មាំងទាំងផ្ទៃក្នុងៗ ការដ្ឋានការងារ...។ល។ ព័ត៌មានហ្នឹងវាសំខាន់ហើយ ក៏ប៉ុន្តែមិនមែនជាប្រធានបទដែលត្រូវមកដេញដោលក្នុងវគ្គទីមួយនេះទេ។ បើយើងធ្វើបែបនេះ គឺថាវាអាចនឹងមានហានិភ័យមួយដែលថាព័ត៌មានទាំងអស់នេះ គឺថាព័ត៌មានហ្នឹងមិនពាក់ព័ន្ធ ប៉ុន្តែដូចតុលាការបង្ខំឲ្យភាគីហ្នឹងយកមកអានយក

មកដេញដោលដែលវាមិនពាក់ព័ន្ធ ដែលមិនបង្ហាញអំពីពិរុទ្ធភាព ឬក៏ដោះបន្ទុកឲ្យកូនក្តីរបស់ខ្ញុំទេ។

លោក លោកស្រីចៅក្រម គឺថាត្រូវពិនិត្យពិចារណាឲ្យពី-- ឯកសារទាំងអស់នេះមិនត្រឹមតែនៅក្នុង A3 នោះទេ វាត្រូវទាំង A4, A5 រហូតដល់6 នោះផងដែរ។ ដោយថាបញ្ជីទាំងអស់នោះ ខ្ញុំមើលសេចក្តីបកស្រាយ ឬសេចក្តីអធិប្បាយរបស់សហព្រះរាជអាជ្ញានៃឯកសារទាំងអស់ហ្នឹង គឺថាអាចនឹងត្រូវលុបឯកសារទាំងអស់នោះចេញ ទោះបីជាសហព្រះរាជអាជ្ញាលើកឡើងថាពាក់ព័ន្ធនោះក៏ដោយ ប៉ុន្តែមានកន្លែងឯកសារមួយចំនួនវាមិនពាក់ព័ន្ធនៅក្នុងផ្នែកទីមួយនៃសវនាការនេះទេ។ នេះជាចំណុចសំខាន់ដែលខ្ញុំចង់លើកឡើង។

បើសិនជាខ្ញុំសល់ពេលខ្លះនោះ ខ្ញុំនឹងវិភាគទានទៅឲ្យក្រុមលោក អៀង សារី ជាអ្នកប្រើ។ សូមអរគុណតុលាការ។

[១១:១១:២១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ជាបន្ត អង្គជំនុំជម្រះផ្តល់វេទិកាការពារក្តីលោក អៀង សារី ដើម្បីធ្វើការបង្ហាញអំពីការជំទាស់របស់ខ្លួន។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងសវនាការទាំងមូល។

ក្នុងវគ្គចុងក្រោយនៃសវនាការហ្នឹង ខ្ញុំចង់ផ្តល់សេចក្តីសង្កេតដែលខ្ញុំចង់គួរតែបានធ្វើនោះ ក៏ប៉ុន្តែដោយសារថាអង្គជំនុំជម្រះកត់សម្គាល់ដល់ភាគីកាលពីអាទិត្យមុននោះ ដែលយើងចាំហើយពីមួយសប្តាហ៍មុននោះ។ ខ្ញុំបានជំទាស់ទៅសហព្រះរាជអាជ្ញាដែលផ្តល់ភស្តុតាងទាក់ទងទៅនឹងរបាយការណ៍ព័ត៌មានតាមវិទ្យុ។ នេះជារបាយការណ៍មួយ គឺថាដែលថាសេចក្តីសុន្ទរកថារបស់ ប៉ុល ពត នោះគឺថានេះជាស្ថានភាពមិនធម្មតាដែលថា តើវាករណីអ្វីដែលខ្ញុំត្រូវជំទាស់នោះ? គឺថាខ្ញុំជំទាស់ដោយមូលហេតុថាសហព្រះរាជអាជ្ញានិយាយថានឹងធ្វើការពិភាក្សាសម្រេចនៅក្នុងករណីនេះ គឺថាការជំទាស់របស់ខ្ញុំត្រូវកត់សម្គាល់ ហើយសេចក្តីសង្កេតដែលភាគីលើកឡើងនោះ គឺថាបានផ្តល់សក្ខីកម្ម ហើយសហព្រះរាជអាជ្ញាបានលើកឡើង ប៉ុន្តែមិនមានភស្តុតាងអ្វីបញ្ជាក់ដែលថា ចៅក្រមជាអាជីពដែលថាយើងត្រូវពិនិត្យអ្វីដែលត្រូវពិនិត្យមើលនោះ គឺថាយើងអាចប្តូរ-- តើអ្វីជាភស្តុតាង? តើអ្វីជាទឡ្ហីករណ៍នោះ? ឬក៏ជា

សេចក្ដីអធិប្បាយរបស់ភាគីនោះ។

[១១:១៣:០២]

ឥឡូវនេះ ខ្ញុំលើកពីបញ្ហានេះជម្រាប ដោយហេតុថាកំណត់សម្គាល់របស់ខ្ញុំគឺទាក់ទងទៅនឹងជំទាស់ឧបសម្ព័ន្ធ៣ គឺដូចគ្នា ដូចដែលបានលើកឡើងចំពោះឧបសម្ព័ន្ធ១, ២ នោះដែរ។ ដោយបានស្ដាប់សហព្រះរាជអាជ្ញាថ្ងៃនេះ ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីថ្ងៃនេះ ពួកគាត់បានឃើញថាយើងមិនជំទាស់ជាក់លាក់គ្រប់គ្រាន់ទេ។ ជាបឋមនោះ យើងនិយាយអំពីប្រភេទនៃភស្ដុតាង នេះជាចំណុចទីមួយ។ តាមដែលខ្ញុំយល់ គឺថាមិនមែនយើងមានបន្ទុកទេ ហើយមិនមែនជាការចាំបាច់ដែលយើងត្រូវបង្ហាញការជំទាស់គ្រប់ឯកសារជាក់លាក់ទាំងអស់នោះទេ យើងជំទាស់ជាក្រុម ដូចជាក្នុងនេះ គឺថាយើងមានកំណត់ហេតុកិច្ចអង្គប្រជុំរបស់បក្សកុម្មុយនីស្ដកម្ពុជា។ យើងអាចធ្វើការជំទាស់ជាទូទៅ ដូចដែលយើងបានធ្វើនោះឯង។ ប៉ុន្ដែ សហព្រះរាជអាជ្ញាលើកឡើងថ្ងៃនេះ ដើម្បីបង្ហាញថាយ៉ាងហោចណាស់ ឧបសម្ព័ន្ធ១ ហើយខ្ញុំស្នើថាយើងនឹងត្រូវតែធ្វើដូចគ្នានៅក្នុងឧបសម្ព័ន្ធ៣ ដូចខាងក្រោមនេះ គឺថាយើង-- គាត់បានផ្ដល់ គាត់បានជឿជាក់ថា គឺជាមូលដ្ឋាននៃឯកសារជាក់លាក់មួយនេះ ដែលត្រូវដាក់ចូលក្នុងសំណុំរឿង។ ហើយក៏ជាសំណើសុំការផ្ដល់ជាភស្ដុតាង ប៉ុន្ដែតាមធម្មតាសាក្សីជាត្រូវធ្វើសំណើផ្ដល់ភស្ដុតាងនោះទេ ប៉ុន្ដែប្រហែលជាខ្ញុំច្រឡំ ប៉ុន្ដែនៅក្នុងប្រព័ន្ធស៊ីវិលឡ ប្រហែលជាសហព្រះរាជអាជ្ញា ប្រហែលជាមានគំនិតល្អជាងមេធាវីការពារដែលគេត្រូវផ្ដល់សក្ខីកម្មរបស់សហព្រះរាជអាជ្ញាដែលថាចៅក្រមត្រូវគោរព។ ថាតើត្រូវស្ដាប់សក្ខីកម្មរបស់ព្រះរាជអាជ្ញា ឬក៏ត្រូវស្ដាប់សក្ខីកម្មរបស់សាក្សី? នេះហើយថាជាផ្នែកមួយនៃភស្ដុតាង អ្វីដែលយើងត្រូវធ្វើ សូមឲ្យសហព្រះរាជអាជ្ញាធ្វើសក្ខីកម្ម ថាជាភស្ដុតាង។

[១១:១៥:០៤]

ដូច្នេះខ្ញុំហានជម្រាបបែបនេះ គឺថាមិនមែនជាការយល់ច្បាស់អំពីប្រព័ន្ធស៊ីវិលឡទេ ប៉ុន្ដែអ្វីដែលឃើញថ្ងៃនេះ គឺថាការជំទាស់របស់យើងដែលយើងលើកឡើងនោះ គឺថាមិនគ្រប់គ្រាន់ទេ ដែលគ្រាន់តែថាឯកសារនេះមាន-- ដែលមានរូបសញ្ញាទង់ប្រាំ ហើយជាពណ៌ក្រហម ហើយវាស្រដៀងគ្នា។ ដូច្នេះហើយយើងមានភស្ដុតាងគ្រប់គ្រាន់ថា ជាឯកសារនេះមានយថាភាព។ ព្រះរាជអាជ្ញាគាត់លើកឡើងអ៊ីចឹង។

យើងសូមជម្រាបតុលាការថា នៅក្នុងសេចក្ដីស្នើរបស់យើងថា ទម្លាប់អនុវត្តដែលប្រើយ៉ាងត្រឹម

ត្រូវរបស់ច្បាប់របស់តុលាការអន្តរជាតិនៅទីនេះផងដែរ។ បើយើងនាំសាក្សីមក គឺសាក្សីដែលបានពិនិត្យមើលឯកសារមួយនេះ ហើយអាចនឹងផ្ដល់នូវសក្ខីកម្មបាន ជាឧទាហរណ៍។ យើងអាចកោះហៅសាក្សីមួយជាអ្នកជំនាញកម្ពុជា ដែលស្ថិតនៅក្នុងកម្ពុជាដែលបានពិនិត្យមើលឯកសារហ្នឹង ជាឯកសារច្បាប់ដើម ដែលឃើញយល់ច្បាស់ភាសាខ្មែរ ហើយគេប្រើពេលច្រើន ហើយគាត់អាចនឹងនិយាយថាចំណាយពេលច្រើនក្នុងឯកសារនេះ ហើយកត់សម្គាល់ថានេះជា វាមាននិន្នាការមួយចំនួន ហើយរយៈកាលនេះ គឺថាគាត់មើលឯកសារនេះ ក្នុងកម្រិតណាមួយនៃភាពពិតប្រាកដ ដែលថាវាមានភវនីយភាពទំនងជាឯកសារមានយថាភាព។ ក្នុងករណីនេះ យើងមិនធ្លាប់មាននរណាធ្វើបែបនេះទេ សូមតុលាការជ្រាប ប៉ុន្តែសហព្រះរាជអាជ្ញាបានពិនិត្យមើលទៅលើឯកសារនោះ នេះចំណុចនេះគឺស្រដៀងនឹងឯកសារមួយនេះ។ ដូច្នេះជាឯកសារដូចគ្នាបេះបិទ អាហ្នឹងហើយគេហៅថាជាសក្ខីកម្មដើម្បីឲ្យទទួលយក។ ប៉ុន្តែការនេះមិនត្រូវទទួលយកទេ ហើយចំណុចមួយក្នុងចំណុចទាំងនោះ គឺថាតើគាត់ត្រូវយកសាក្សីមក ឬគាត់អាចស្នើដាក់ភស្តុតាង ឬក៏គាត់អាចធ្វើសេចកក្ដីអត្ថធិប្បាយ ប៉ុន្តែថ្ងៃនេះតុលាការបានឃើញសហព្រះរាជអាជ្ញា គឺសហព្រះរាជអាជ្ញាអន្តរជាតិបានចង្អុលបង្ហាញថា យើងនឹងបានស្ដាប់ យើងនឹងអាចបានស្ដាប់សាក្សីដែលនឹងបញ្ជាក់ថា ក ខ គ ឃ។ នេះហើយជាចំណុចដែលយើងត្រូវរង់ចាំ ដែលនឹងកសាងនូវមូលដ្ឋានមួយ ហើយគាត់នឹងជូនដំណឹងទៅអង្គជំនុំជម្រះនិងភាគីអំពីបញ្ហានោះ។ ប្រសិនបើសាក្សីហ្នឹងមិនមកនៅក្នុងអនាគតទេ ជាពិសេសគឺថា តុលាការបានជ្រាបពីរឿងនោះហើយ។

[១១:១៧:៤៥]

យថាភាពនៅក្នុងករណីដែលថា ភាពជឿជាក់បាននៃឯកសារនឹងភ្ជាប់ទៅនឹងសក្ខីកម្មដែលយើងនឹងស្ដាប់នៅពេលក្រោយ។ យើងក៏ជំទាស់ផងដែរ ទៅនឹងសញ្ញាណដែលគេថា អ្វីៗបានកើតឡើងក្នុងរឿងក្ដី ឌុច ។ នៅក្នុងរឿងក្ដី ឌុច តុលាការបានជ្រាបគឺថា កំណត់ហេតុបក្សកុម្មុយនីស្តកម្ពុជា យើងបានពិភាក្សានៅក្នុងហ្នឹង។ ពីម្សិលមិញហ្នឹងគឺថាយើងមិនបានជំទាស់ទេ យើងមិនមែនស្ថិតនៅក្នុងរឿងក្ដី ០១ ទេ គេប្រើទ្រឹស្ដីរឿងក្ដីផ្សេង។ ក៏ប៉ុន្តែបើការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងបានធ្វើការវិភាគ ដើម្បីបង្ហាញថាឯកសារទាំងអស់នោះ គឺថាខ្លួនបានពឹងផ្អែកគឺថា ជាកម្មវត្ថុដែលមិនមានការជំទាស់ ហើយក៏ចាត់ទុកថាជាមានយថាភាព ហើយអាចទុកចិត្តបានដោយមិនចាំបាច់ពិនិត្យមើលដំណើរការទាំងអស់នោះនៅក្នុងរឿងក្ដីត្រូវសម្រេច ថាតើឯកសារណាដែលត្រូវពាក់ព័ន្ធ មានយថាភាព ឬក៏មិនជឿទុកចិត្តបាននោះ។

[១១:១៨:៥៤]

លើកលែងតែមានភស្តុតាងបញ្ជាក់ច្បាស់ពីរឿងហ្នឹង ទោះបីជាក្នុងមានករណីបញ្ជាក់ច្បាស់នៅក្នុងករណីនោះក៏ដោយ ប៉ុន្តែករណី០០២ នេះយើងមានសិទ្ធិនឹងធ្វើការជំទាស់ ហើយសូមឲ្យសហព្រះរាជអាជ្ញា និងបង្ហាញនូវថា មូលហេតុអ្វីដែលគេពឹងផ្អែកលើឯកសារហ្នឹង។ តើឯកសារហ្នឹងមានយថាភាពអាចជឿជាក់បាន ហើយពាក់ព័ន្ធដែរឬទេ? យើងបានដាក់សំណើទាក់ទងទៅនឹងអង្គហេតុដែលបានជម្រះរួចហើយនោះ។ តុលាការបានចាំច្បាស់ណាស់ករណីនេះ យើងបានប្រើជំហានរាំងកាត់ជាមុនក្នុងការលើកហ្នឹង ដោយសារបទពិសោធន៍នៅក្នុងតុលាការឡាអេរបស់ខ្ញុំ។

[១១:១៩:៣៩]

អ្វីដែលថា កំណត់នៅក្នុងវិធានផ្ទៃក្នុងហើយ គឺថាអង្គហេតុដែលជម្រះរួចនោះគឺថាមិនត្រូវយកមកអនុវត្តក្នុងរឿងក្តីនេះទេ។ តុលាការមិនអាច អង្គជំនុំជម្រះមិនអាចថា ប្រើការរកឃើញ ឬក៏អ្វីៗដែលរកឃើញនៅក្នុងរឿងក្តី ឌុច យកមកដាក់ទាំងអស់នៅក្នុងរឿងក្តី០០២ នោះទេ ដែលចាត់ទុកថាអង្គហេតុហ្នឹងមានភស្តុតាងរួចហើយ យកមកអនុវត្តនៅក្នុងរឿងក្តីនេះនោះ។ លើកលែងតែភាគីបានជំទាស់ ឬដេញដោលម្តងទៀតសិន។ ដូចដែលចៅក្រមជ្រាបហើយថា ខ្ញុំចាត់វិធានការបង្ការមុនដែលថាវិធានការនេះនៅក្នុងវិធាន ហើយខ្ញុំបានប្រុងប្រយ័ត្នណាស់ ហើយតុលាការអាចនឹងណែនាំថាឲ្យពិនិត្យមើលឡើងវិញ ក៏ប៉ុន្តែខ្ញុំបានធ្វើបែបនោះក្នុងគោលបំណងជាក់លាក់។ ឥឡូវនេះ យើងដល់ពេលហ្នឹងហើយនេះ បញ្ហាគឺវាកើតឡើង។

[១១:២០:៣០]

លោក លោកស្រីចៅក្រមជាទីគោរព ដើម្បីនឹងយកឯកសារពីរឿងក្តី ឌុច ដោយផ្អែកលើមូលដ្ឋានថា ដោយហេតុថាប្រើក្នុងរឿងក្តី ឌុច ហើយយកមកប្រើបាន។ ខ្ញុំជូនជាឧទាហរណ៍មួយៈ សញ្ញាណនៃស្តង់ដារអន្តរជាតិ ជាពិសេសនៅក្នុងរឿង *ប្រលើក ខេស* នៅក្នុងរឿងក្តីតុលាការអន្តរជាតិដែលភាគីបានលើកឡើងដេញដោលល្អិតល្អន់ណាស់។

[១១:២០:៥៤]

នៅក្នុងរឿងក្តី *ប្រលើក* នោះ មានឯកសារមួយចំនួន គឺប្រតិចារឹករបស់ប្រធានាធិបតី។ ដូចជាប្រធានធិបតី និចស៊ុន។ ប្រធានាធិបតីហ្នឹងគឺបានប្រើកត់ត្រាជាខ្សែអាត់ រួចហើយគាត់ធ្វើ*ត្រេនស្គ្រីប*ជាធម្មតាអ៊ីចឹង។ កាលណាកំណត់ត្រានោះវាមិនមានទេ គឺគេត្រូវធ្វើប្រតិចារឹកពីសំឡេង ឬក៏ថាត្រូវមាន

ហើយត្រូវយកមកប្រើនៅក្នុងរឿងក្ដីពីមុនៗនោះ ដែលថាអង្គហេតុបានផ្សារភ្ជាប់ទៅនឹងរឿងក្ដី រឿងឈ្មោះ *ប្របើក* នោះ។ ហើយក្នុងរឿងក្ដីផ្សេងៗ គេបានទទួលស្គាល់ថាជាប្រតិចារឹក ប៉ុន្តែអង្គជំនុំជម្រះក៏ត្រូវធ្វើវិភាគ ហើយអង្គជំនុំជម្រះពិតជាត្រូវតែធ្វើអ៊ីចឹង គឺដោយខ្លួនឯង គឺប៉ុន្តែធ្វើដូច្នោះ ដោយសារមេធាវីការពារស្នើទទួចឲ្យសហព្រះរាជអាជ្ញាបង្ហាញភស្តុតាង ប្រភពដើមនៃប្រតិចារឹករបស់ប្រធានាធិបតីនោះ ហើយនិងយថាភាព ហើយនិងភាពទុកចិត្តបាន ហើយភាពពាក់ព័ន្ធដែលត្រូវពិនិត្យពិចារណា ប៉ុន្តែផ្ទុយទៅវិញ ពួកគេត្រូវតែបង្ហាញឲ្យឃើញច្បាស់។

[១១:២២:០៥]

អ្វីដែលយើងឃើញថ្ងៃនេះ ពីព្រះរាជអាជ្ញានោះ ជាឧទាហរណ៍ល្អណាស់ដែលថាគួរតែបានធ្វើ ប៉ុន្តែអាហ្នឹងត្រូវធ្វើឡើងដោយសាក្សីទេ មិនមែនធ្វើឡើងដោយព្រះរាជអាជ្ញានោះទេ។ យើងជម្រាបតុលាការថា នេះគឺជាអ្វីដែលថា ដូចយើងប្រាប់។ ដែលហៅថា "*ភ័រទីស៊ីស*"(?) ដូចជាសេចក្ដីសម្អតិកម្មដោយសារសហព្រះរាជអាជ្ញា។ គំនិតនោះ គឺថាជាពិសេសនៅទីនេះ អង្គជំនុំជម្រះរឿងក្ដីហ្នឹងគឺត្រូវបានបំបែក សហព្រះរាជអាជ្ញាក៏មានគំនិតថា មិនមានរឿងក្ដីទីពីរ ទីបីនោះទេ។ គំនិតហ្នឹងថា គ្រាន់តែបញ្ជាក់ថាអានេះអ្ហែ! ឯកសារទាំងអស់នៅក្នុង*ដូស្យេ* យកទាំងអស់ទៅ។ ថាតើឯកសារហ្នឹងទាក់ទងនៅពេលនេះដែរ មិនទាក់ទង មិនត្រូវមិនបាច់និយាយទេ? ថាតើបញ្ជាក់ដោយសាក្សីដែរឬអត់ហ្នឹង គឺមិនបាច់គិតទេ? យើងថាវាពាក់ព័ន្ធ យើងមាន យើងបញ្ជាក់ថាមានយថាភាព។ ចូរតុលាការយកទាំងអស់ហ្នឹងទៅ។

[១១:២៣:០៤]

ដូច្នេះអ្វីដែលកើតឡើងនៅទីនេះ យើងមិនមានការជំនុំជម្រះ ដែលថាដែលត្រូវស្ដាប់សក្ខីកម្មទាំងអស់ទេ ប៉ុន្តែវាអាចនឹងក្លាយជាសវនាការមួយដោយការប្រើឯកសារ ដែលមិនមានការធ្វើតេស្តបញ្ជាក់នោះទេ។ នេះហើយគឺជាករណីពិសេស ហើយខ្ញុំនឹងនិយាយច្រើនទៀតនៅថ្ងៃស្អែកនៅពេលដែលយើងធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់នោះ។ អ្វីដែលយើងនឹងធ្វើការនៅតុលាការឡាអេ ក្នុងរឿងក្ដី*ប្របើក* ហ្នឹង គឺតិចនិកដែលយើងប្រើនោះ គឺយ៉ាងដូចម្ដេច? ដែលថាភាគីទេដែលជាអ្នកបញ្ជូននូវភស្តុតាងត្រូវបង្ហាញភស្តុតាងមានយថាភាព ជឿទុកចិត្តបាន។ វាអាចជារបាំងត្រូវឆ្លោះមួយ ប៉ុន្តែជាកម្រិតមួយ។ បើគ្រាន់តែលើកឡើងថានេះ ជាការថ្លែងទៅអង្គការសហប្រជាជាតិ មិនគ្រាប់គ្រាន់ទេ។ ដូចជាគណៈកម្មាធិការតាមដានរបស់អ៊ឺរ៉ុបហ្នឹង គឺថាខ្ញុំជូនជាឧទាហរណ៍មួយ នៅក្នុងស្ដាប់-- នៅពេលដែលមានសង្គ្រាមនៅ

បូស្នៀ ហ្នឹងគឺថាមានការតាមដានជាសម្ងាត់ធ្វើរបាយការណ៍។ របាយការណ៍ហ្នឹងរាយនៅថ្នាក់មូលដ្ឋាន ហើយបញ្ជូនទៅថ្នាក់លើនៅការិយាល័យផ្សេង ហើយបញ្ជូនទៅដល់ទីបញ្ជាការដែលគេចងក្រងឯកសារហ្នឹង គឺទុកមួយកន្លែង។

[១១:២៤:២៧]

ជាសាមញ្ញនោះ ដោយហេតុយើងមាន គឺថាអ្នកតាមដានអ៊ុំរ៉ុប គឺថាការដែលប្រើឈ្មោះនេះក៏មិនបញ្ជាក់ថាឯកសារហ្នឹងមានយថាភាព អាចជឿជាក់បាន ហើយយកមកប្រើបាននោះទេ គឺថាសហព្រះរាជអាជ្ញាក៏ត្រូវតែប្រើកិច្ចប្រឹងប្រែងដើម្បីបង្ហាញថាធ្វើដោយរបៀបណា? អ្នកណាជាអ្នកធ្វើ? តើរបៀបនៃការគ្រប់គ្រង បញ្ជូនតទៅណា? អ្នកណាទុក? គេប្រមូលវាបែបណា? តើរក្សាទុកបែបណា?

គឺអាស្រ័យទៅលើភាគីនៅក្នុងការពិនិត្យមើលឯកសារក្នុងការជំទាស់ថា តើខ្លឹមសារនៃឯកសារនោះអាចទុកចិត្តបានទេ ឬក៏ពាក់ព័ន្ធដែរឬទេ? ដូច្នេះ យើងស្នើតុលាការថា ការអះអាងបែបនោះ គឺថាឯកសារ-- មជ្ឈមណ្ឌលឯកសារកម្ពុជាថា ជាអង្គការមួយនោះគឺថា វាមិនមែនមានន័យថា ឯកសារនោះយថាភាពនោះទេ។ ដូច្នេះ គឺថាត្រូវតែពិនិត្យមើលទៅតាមនីតិវិធីឲ្យបានត្រឹមត្រូវ។ ដូចការបង្ហាញខ្លះគឺត្រូវតែធ្វើឡើង។

សហព្រះរាជអាជ្ញាក៏ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ដោយមានច្បាស់លាស់ថា តើមានឯកសារហ្នឹងត្រូវដាក់ដេញដោលចំពោះតុលាការហ្នឹង គឺឯកសារអ្វី? ដោយមូលហេតុអ្វី? ក្នុងការធ្វើបែបនោះគឺខ្លួនត្រូវបង្ហាញថា ឯកសារនោះគឺត្រូវមានយថាភាព អាចទុកចិត្តបាន ហើយវាមានភាពពាក់ព័ន្ធទៅនឹងផ្នែកសវនាការ។

[១១:២៥:៥១]

ឃើញថាព្រះរាជអាជ្ញាមិនបានធ្វើបែបនោះទេ។ ហើយវាត្រូវមាន វាមានឃ្លាមួយចំនួន មានឡូហ្គូ សញ្ញាអីគ្រប់គ្រាន់នោះទេ។ គឺត្រូវមានសាក្សីមកបង្ហាញ បញ្ជាក់ថាបែបហ្នឹងមែន តាមរយៈសក្ខីកម្ម។

ដោយបានបញ្ជាក់បែបនេះ លោក លោកស្រីចៅក្រម ខ្ញុំនឹងត្រូវចំណុចដើមមួយរបស់ខ្ញុំ បើយើងនិយាយកំណត់ហេតុអង្គប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា ជំទាស់ដ៏សំខាន់របស់យើងគឺដូចខាងក្រោម៖

លើកលែងតែភាគីអាចបញ្ជាក់ដោយសាក្សីបាន គឺមិនតាមរយៈសក្ខីកម្មទេ គឺត្រូវឲ្យសាក្សីបញ្ជាក់ថា តើឯកសារហ្នឹងគេផលិតម៉េច? អ្នកណាជាអ្នកធ្វើ? លក្ខខណ្ឌអ្វី? តើរក្សាទុកម៉េច? គឺជា

ការងារដែលបង្ហាញឲ្យចៅក្រមទុកចិត្តច្បាស់ថា ឯកសារហ្នឹងគឺដូចដែលអ្វីដែលព្រះរាជអាជ្ញាអះអាងថា ជាឯកសារពិតហ្នឹង។ ប៉ុន្តែតាមពិតទៅ នៅពេលដែលឯកសារចូលមកភាគី គឺមានសិទ្ធិជំទាស់បដិសេធទៅលើខ្លឹមសារសារធាតុរបស់វានោះ។

[១១:២៦:៥៦]

បើសិនព្រះរាជអាជ្ញាបង្ហាញភស្តុតាងថា វាច្បាស់អ៊ីចឹង អាហ្នឹងមិនបញ្ហាទេ។ ដូច្នេះយើងពិនិត្យថា ត្រូវបង្ហាញដូចដែលម្សិលមិញ និងថ្ងៃនេះដែរត្រូវតែធ្វើឲ្យច្បាស់ ប៉ុន្តែម្សិលមិញគឺល្អទេ។ គេនិយាយថា យើងជឿជាក់ថា ឯកសារទាំងអស់នេះគឺមានទំនាក់ទំនងគ្នា ហើយទាំងអស់នេះជាឯកសារដែលភ្ជាប់ទៅនឹង-- ជាឧទាហរណ៍ ឯកសារ ក, ខ, គ,...។ល។ ហើយយើងត្រូវពិនិត្យមើល ថាវាយ៉ាងដូចម្ដេច? ហើយតុលាការត្រូវពិនិត្យមើលផងដែរ ប៉ុន្តែយើងស្នើយើងជម្រាបតុលាការថា ពីម្សិលមិញនេះ យើងមិនអាចផ្ដល់ឲ្យនូវ*ហេស្តេក* ដូចជា ស្រូវមួយជង្រុកធំអ៊ីចឹងទេ។

យើងតុលាការមិនអាចតម្រូវឲ្យយើងចុចរកឯកសារក្នុងមួយជង្រុកធំ ដូចជាស្រូវអ៊ីចឹង ទៅរកមួយណាមកលម្អិតជំទាស់បាននោះទេ វាមិនច្បាស់ នេះហើយជាករណីដែលយើងបានជួបនៅថ្ងៃនេះ។

[១១:២៨:០១]

យើងនៅទីនេះ ថ្ងៃនេះ លោក លោកស្រីចៅក្រម យល់ហើយ ដោយហេតុថា ពិនិត្យមើលជំហររបស់សហព្រះរាជអាជ្ញាដោយថា គាត់មិនបានប្រមើលជាមុនទេ ដែលគាត់គួរតែដឹងមុន។ នីតិវិធីដែលយើងអនុម័តនៅតុលាការនេះ ជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយក៏ជារឿងក្ដីវិសាមញ្ញដែរ ពិសេសដែរ ដែលមិនតែងតែកើតឡើងក្នុងតុលាការធម្មតាទេ។ នៅក្នុងប្រព័ន្ធស៊ីវិលឡូ ធម្មតាបារាំងរបស់បារាំង ឬក៏របស់កម្ពុជានោះទេ។

[១១:២៨:៣៤]

ដោយហេតុថានៅទីនេះ យើងមាន*ដូស្សេ*ទាំងអស់នេះ ហើយយើងទាំងអស់គ្នាឯកសារថា ពាក្យថា *"ដូស្សេ"* ហ្នឹងគឺជាដូចជាពិភពនៃអង្គហេតុទាំងអស់ដែលមានឯកសារភស្តុតាងអីនៅក្នុងហ្នឹងទាំងមូល ដែលថាភាគីអាចនឹងពិនិត្យមើលថា ឯកសារនោះមកពីខាងក្នុង ឬក៏ខាងក្រៅ។ ប៉ុន្តែនៅក្នុងប្រព័ន្ធដែលយើងប្រើនៅទីនេះ ចៅក្រមទាំងឡាយត្រូវអានឯកសារទាំងអស់ ហើយចៅក្រមជាអ្នកដឹកនាំនីតិវិធី។ ប៉ុន្តែនៅទីនេះ យើងងាកចេញពីនោះបន្តិច ដែលសូមឲ្យភាគីកំណត់ថា តើឯកសារអ្វីដែលគេជឿជាក់ថាមានការចាំបាច់ ដើម្បីផ្ដល់ភស្តុតាង ឬក៏មិនភស្តុតាងនូវរឿងក្ដី។ គឺអាស្រ័យទៅលើ ផ្អែកទៅលើ

ដីកាដំណោះស្រាយ។

[១១:២៩:២២]

នៅក្នុងករណីនេះ គឺថាអាចសហព្រះរាជអាជ្ញា មិនមែនជាកាពីតែននៃកប៉ាល់របស់ខ្លួនឯងទៀតទេ ពីព្រោះថាគាត់មានរឿងក្តី ក៏ប៉ុន្តែរឿងក្តីរបស់គេមិនត្រូវបាន របៀបមួយដែលគាត់ចង់បង្ហាញនោះទេ ដោយថាអង្គជំនុំជម្រះជាអ្នកបង្គាប់ទៅវិញ គឺថាជាអ្នកបង្គាប់លំដាប់លំដោយនៃសាក្សីទៅវិញ។

នៅក្នុងប្រព័ន្ធប្រតិបក្ខវិញ ដែលថាភាគីជាអ្នកតទល់គ្នាហ្នឹងគឺថា ភាគី គឺជាកាពីតែននៃនាវារបស់ខ្លួន។ ដូច្នេះថា អ្នកណាជាសាក្សីរបស់ខ្លួនលំដាប់លំដោយម៉េច? ឯកសារអ្វី? គឺភាគីជាអ្នកបង្ហាញ។

ដូច្នេះនៅក្នុងប្រព័ន្ធមួយដែលថាចម្រុះ នៅក្នុងស្ថានភាពផ្សេងពីប្រព័ន្ធស៊ីវិលឡ ឬខំមិនឡូខ្លួន--ស៊ីវិលឡូខ្លួនឯង។ ខ្ញុំមិននិយាយរិះគន់តុលាការណាមួយនោះទេ ក៏ប៉ុន្តែន័យនេះយើងជឿ ហើយជម្រាបតុលាការថា ដើម្បីចៀសវាងនូវការជំទាស់នូវពេលអនាគតនោះ។ ល្អបំផុតសហព្រះរាជអាជ្ញាត្រូវតែបង្ហាញតាមរយៈសាក្សី មិនមែនធ្វើសក្ខីកម្មខ្លួនឯងជំនួសសាក្សីនោះទេ។ នៅពេលដែលយើងជឿជាក់ថាប្រភេទឯកសារអី ទង់បដិវត្ត តេឡេក្រាម ហើយសៀវភៅអ្វី? ធ្វើឲ្យវាមានយថាភាពនោះ ឲ្យយើងជឿនោះគឺថា មិនជាការលំបាកទេ គាត់ដឹងពីរឿងក្តីរបស់គាត់ យើងដឹងពីរឿងក្តីរបស់យើង។ គឺថាយើងសូមឲ្យមានជំនួយពីអ្នកជំនាញ ឬក៏ពីតុលាការ យើងអាចធ្វើដូច្នោះបាន។ នេះហើយជាចំណុច ដែលតុលាការគប្បីពិចារណា។

[១១:៣១:០៣]

ខ្ញុំសូមអរគុណ ចំពោះលោក លោកស្រីចៅក្រម ហើយនិងសវនាការទាំងមូល។ បើសិនមានសំណួរ ខ្ញុំនឹងឆ្លើយជូន។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីការពារក្តី ខៀវ សំផន ដើម្បីលើកឡើងអំពីការជំទាស់របស់ខ្លួនទៅលើឯកសារ ឧបសម្ព័ន្ធA3។

[១១:៣១:៤៥]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។

សម្រាប់ឧបសម្ព័ន្ធទី៣ ដែលមាននៅក្នុងឯកសាររបស់សហព្រះរាជអាជ្ញាលេខ E158 នេះ។

យើងខ្ញុំបានពិនិត្យឃើញថា សហព្រះរាជអាជ្ញាបានបង្ហាញ បានព្យាយាមបង្ហាញនូវចំណុចពាក់ព័ន្ធមួយចំនួនចំពោះឯកសារ។ ហើយឯកសារដែលសហព្រះរាជអាជ្ញាបានព្យាយាមបង្ហាញនូវតម្រុយនោះ គឺមានត្រឹមតែ២៧ ក្នុងចំណោមឯកសារទាំងអស់ដែលមាន នៅក្នុងឧបសម្ព័ន្ធទី៣នេះ។ ក្រៅពីនោះ យើងឃើញមានការបែងចែកចំណាត់ថ្នាក់ឯកសារមាន៖

១) កំណត់ហេតុអង្គប្រជុំនៃគណៈអចិន្ត្រៃយ៍ ទី២) កំណត់ហេតុអង្គប្រជុំនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ទី៣) កំណត់ហេតុអង្គប្រជុំសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ និងទី៤) កំណត់ហេតុអង្គប្រជុំផ្សេងៗទៀត។

[១១:៣៣:១៩]

ជារួមយើងខ្ញុំមើលឃើញថា នៅក្នុងឧបសម្ព័ន្ធនេះ ការជំទាស់របស់យើងខ្ញុំមិនខុសអ្វីពីក្នុងនៅឧបសម្ព័ន្ធទី២ទេ ជាគោលការណ៍នោះ។ គឺថាការលើកឡើងរបស់សហព្រះរាជអាជ្ញាមិនបានបង្ហាញពីខ្សែចង្វាក់នៃការរក្សាឯកសារ ដើម្បីបង្ហាញពីភាពត្រឹមត្រូវ ពុំមានការកែបន្លំ ឬក៏ការប្រឌិតចំពោះឯកសារ។ ចំណុចទាំងនេះ វាបង្កឲ្យមានភាពសង្ស័យ។ ដូច្នេះហើយបានយើងខ្ញុំទាមទារឲ្យមានការត្រួតពិនិត្យចំពោះអ្នកដែលបានផ្តល់ឯកសារទាំងនោះ។

[១១:៣៤:៣៤]

ខ្ញុំបាទសូមលើកពីកំណត់ហេតុអង្គប្រជុំនៃគណៈអចិន្ត្រៃយ៍។ កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ភាគច្រើនត្រូវបានរកឃើញនៅក្នុងកាលៈទេសៈដូចគ្នាទៅនឹងសេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលមានលេខ D279/7.2 នោះដែរ ដែលយើងខ្ញុំបានលើកពីម្សិលមិញពីភាពមិនច្បាស់លាស់នៃការទទួលបានឯកសារនោះ។

ទីពីរ ទាក់ទងនឹងកំណត់ហេតុប្រជុំនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ យើងមានឯកសារចំនួនពីរច្បាប់នៅក្នុងប្រភេទឯកសារនេះ ដោយឯកសារទាំងនោះជាកំណត់ហេតុជំនួបសន្ទនារវាងគណៈប្រតិភូបរទេសនៃប្រទេសកម្ពុជា និងគណៈប្រតិភូប្រទេសចិន។

[១១:៣៦:០១០]

ហើយអ្វីខ្លះដែលសហព្រះរាជអាជ្ញាបានបង្ហាញចំពោះឯកសារទាំងពីរនេះ ទាក់ទងទៅនឹងតម្រុយដែលអាចជឿជាក់បាននោះ។ ឯកសារទីមួយ សហព្រះរាជអាជ្ញាបានបង្ហាញថា ឯកសារនេះទទួលបានពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រគល់ឲ្យទៅមជ្ឈមណ្ឌលឯកសារកម្ពុជាៗ បាទ (ឌី.ស៊ី.ខេម) នៅឆ្នាំ

១៩៩៥។ អ៊ីចឹងបានន័យថាភាពពាក់ព័ន្ធគ្រាន់តែនាយករដ្ឋមន្ត្រីប្រគល់ឲ្យទៅ ឌី.ស៊ី.ខេម គឺថាវាមានភាពជឿជាក់ទៅលើឯកសារនោះទាំងស្រុង ឬមួយយ៉ាងណា។ អ្វីដែលយើងចង់ដឹងថែមទៀតនោះគឺថា តើលោកនាយករដ្ឋមន្ត្រីកាលពីឆ្នាំ១៩៩៥ហ្នឹង គាត់បានទទួលឯកសារនោះដោយរបៀបណា? ទទួលពីនរណា? ទទួលដោយយ៉ាងម៉េច? នេះដើម្បីបញ្ជាក់ថា វាជាច្បាប់ដើម ឬក៏ច្បាប់ថតចម្លងជាដើម ដើម្បីបង្ហាញពីភាពជឿជាក់ឲ្យកាន់តែច្បាស់។

[១១:៣៧:៥២]

ម្យ៉ាងទៀត សហព្រះរាជអាជ្ញាបានបញ្ជាក់ផងដែរថា ខ្លឹមសារនៃឯកសារនោះត្រូវបានបញ្ជាក់ដោយសាក្សីម្នាក់ដែលមានលេខសម្គាល់TCW-583 នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ សម្រាប់ព័ត៌មានត្រឹមតែប៉ុណ្ណឹង យើងមិនអាចឲ្យតម្លៃថាឯកសារមួយនេះជាឯកសារត្រឹមត្រូវគួរឲ្យជឿបានទាំងស្រុងទេ គឺត្រូវតែនាំអ្នកដែលផ្តល់ឯកសារនោះមកសួរបញ្ជាក់ ដើម្បីបង្ហាញថាគាត់បានទទួលឯកសារនោះដោយរបៀបណា? នៅពេលណា? និងមានអ្វីខ្លះក្នុងស្ថានភាពណាខ្លះ? ដែលជាប់ចោទពាក់ព័ន្ធក្នុងកាលៈទេសៈដែលគាត់បានទទួលឯកសារនោះ។

[១១:៣៩:០៦]

ចំពោះឯកសារទីពីរ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារនោះប្រមែប្រមូលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា (ឌី.ស៊ី.ខេម) នោះ នៅបណ្ណសារដ្ឋានជាតិនៅឆ្នាំ២០០២។ សហព្រះរាជអាជ្ញាបានផ្តល់ព័ត៌មានមួយទៀត (សូមទោស) សហព្រះរាជអាជ្ញាគាត់មិនបានផ្តល់ព័ត៌មានបន្ថែមទៀតទាក់ទងទៅនឹងការរក្សាទុកឯកសារមុនពេលដែលឯកសារនោះធ្លាក់មកដល់ដៃមជ្ឈមណ្ឌលឯកសារនោះទេ។ (សុំទោស) មុនពេលដែលឯកសារនោះទទួលបាននូវបណ្ណសារដ្ឋានជាតិនោះទេ។ អ្វីដែលយើងខ្ញុំ ចង់ដឹងគឺថាតើឯកសារនោះ រកឃើញនៅកន្លែងណា? ដោយអ្នកណា? នៅពេលណា? ហើយគេបញ្ជូនទៅកាន់បណ្ណសារដ្ឋានជាតិដោយរបៀបណា? ព័ត៌មានទាំងអស់នេះ វាអាចបញ្ជាក់ពីភាពដើម និងភាពដែលអាចជឿបាននៃឯកសារនោះ។

ប្រភេទឯកសារទីបី គឺកំណត់ហេតុអង្គប្រជុំនៃសភាតំណាងប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារមួយដែលអាចកំណត់-- ដែលអាចជាកំណត់ហេតុនៃការប្រជុំរបស់សភាតំណាងប្រជាជនកម្ពុជាប្រជាធិបតេយ្យនោះ គឺដោយសារតែឯកសារនោះមានប្រើពាក្យថា “ចក្រពត្តិអាមេរិក” គ្រាន់តែពាក្យថា ចក្រពត្តិអាមេរិក ដែលជាតម្រុយមួយនៃភាពជឿជាក់ទៅលើ

ឯកសារនេះ។ ដោយសារព្រះរាជអាជ្ញាយល់ថា វាជាពាក្យពេចន៍ដែលប្រើជាចំណុចពិសេសសម្រាប់បម្រើមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជា។ ការពិតទៅពាក្យថា "ចក្រពត្តិអាមេរិក" នេះ គឺត្រូវបានប្រើយ៉ាងទូលំទូលាយនៅក្នុងតំបន់អាស៊ីនេះរួចទៅហើយ ក្នុងទសវត្សរ៍៧០ នោះ។ មិនមែនគ្រាន់តែឃើញពាក្យពេចន៍នេះមួយមាត់នៅក្នុងឯកសារនោះ ហើយក៏បញ្ជាក់ថាវាជាឯកសារមួយរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ។

[១១:៤២:៣៧]

ទីបួន កំណត់ហេតុនៃកច្ចិប្រជុំផ្សេងៗទៀត។ មានឯកសារចំនួនពីរនៅក្នុងក្រុមចំណាត់ថ្នាក់ឯកសារនេះ ដែលសហព្រះរាជអាជ្ញាបានលើក។ តាមសហព្រះរាជអាជ្ញា គឺឯកសារទីមួយត្រូវបានបុគ្គលម្នាក់ដែលមានលេខសម្គាល់ TCE-38 ប្រគល់ទៅឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា (ឌី.ស៊ី.ខេម) នៅឆ្នាំ១៩៩៦។ ចំណោទដូចមុនទៀត គឺថាយើងមិនអាចដឹងថាបុគ្គលដែលមានលេខសម្គាល់ TCE-38 នេះបានទទួលឯកសារនោះពីណា? បានទទួលដោយរបៀបណា? បានទទួលនៅពេលណា? ក៏យើងអត់បានដឹងដែរ។ ដូច្នេះ យើងឃើញថានៅក្នុងឯកសារនេះ ម្យ៉ាងទៀតគឺថាមានព័ត៌មានផ្ទុយគ្នា ពីព្រោះប្រភពនៃការទទួលបានឯកសារ បញ្ជាក់នៅលើឯកសារផ្សេងទៀតមិនដូចគ្នា។

[១១:៤៤:២៤]

ជាចុងបញ្ចប់ ខ្ញុំបាទយល់ឃើញថា តម្រុយពីភាពជឿជាក់ដែលសហព្រះរាជអាជ្ញាបានលើកបង្ហាញចំពោះឯកសារទាំងនោះ មិនទាន់គ្រប់គ្រាន់ទេ។ ដូច្នេះ ខ្ញុំសូមទទូចដដែលៗ សុំឲ្យពិនិត្យទៅលើការជឿជាក់នេះ ឲ្យច្បាស់លាស់ ហើយមធ្យោបាយដែលអាចធ្វើបាននោះ គឺថាត្រូវហៅ ត្រូវអញ្ជើញអ្នកដែលជាប់ពាក់ព័ន្ធនេះ ដើម្បីឲ្យភាគីមានឱកាសដេញដោល ដើម្បីបញ្ជាក់ពីភាពជឿជាក់បាននៃភស្តុតាង ឬឯកសារទាំងអស់នោះ។ សូមអរគុណ។

[១១:៤៥:២១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សឹមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឲ្យនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់ខាងក្រោមរង់ចាំ ហើយនិងរហូតដល់រសៀលម៉ោង-- សូមឲ្យនាំខ្លួនគាត់មកកាន់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤៦ នាទី ដល់ម៉ោង ១៣:៣៦ នាទី)*

[១៣:៣៦:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

*(ចៅក្រមពិភាក្សាគ្នា)*

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ កាលពីព្រឹកមិញយើងបានស្ដាប់នូវសេចក្ដីជំទាស់ពីក្រុមមេធាវីការពារក្ដីទាំងបីក្រុមរួចហើយលើឯកសារឧបសម្ព័ន្ធA3 ហើយដល់ពេលនេះគឺវេទិកា ត្រូវបានទៅសហព្រះរាជអាជ្ញា ហើយនិងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការធ្វើអំណះអំណាងតបទៅនឹងការជំទាស់ពាក់ព័ន្ធនឹងឯកសារឧបសម្ព័ន្ធA3 ប៉ុន្តែមុននឹងផ្ដល់វេទិកាទៅសហព្រះរាជអាជ្ញាអង្គជំនុំជម្រះ សូមសួរទៅសហព្រះរាជអាជ្ញាឲ្យធ្វើការកត់សម្គាល់លើសំណើសុំរបស់មេធាវី នួន ជា ដែលបានស្នើសុំកាលពីព្រឹកមិញថា ឲ្យការិយាល័យសហព្រះរាជអាជ្ញាធ្វើការកំណត់នូវអត្តសញ្ញាណ ឯកសារទាំងអស់ដែលមានប្រភពពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីងាយស្រួលនៅក្នុងការពិភាក្សាដេញដោលពាក់ព័ន្ធនឹងសាក្សីដែលជាថ្នាក់ដឹកនាំ ជាអ្នកទទួលខុសត្រូវមជ្ឈមណ្ឌលឯកសារកម្ពុជាដែលអង្គជំនុំជម្រះគ្រោងធ្វើនៅសប្ដាហ៍ក្រោយ។

សូមអញ្ជើញប្រសិនបើមានបំណងក្នុងការធ្វើការកត់សម្គាល់លើបញ្ហានេះ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

បាទ ទាក់ទងនឹងបញ្ហាបឋមនេះលោកប្រធាន។ ជាបឋមខ្ញុំគិតថា យើងមានធាតុផ្សំដែលអាចឲ្យយើងនិយាយបានថា ឯកសារទាំងអស់នេះមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងឃើញនៅក្នុងឯកសារ E158 ហើយមានព័ត៌មានទាក់ទងទៅនឹងឯកសារដែលមាននៅ-- ដែលមានការអធិប្បាយនៅក្នុងឯកសារហ្នឹង យើងបានទទួល។ អ៊ីចឹងគឺថា យើងដាក់វាទៅក្នុងតារាងព័ត៌មានទាំងអស់ហ្នឹង

តម្រូវស៊ីពេលវេលាច្រើនណាស់ចំពោះយើង អ៊ីចឹងគឺថាយើងមិនប្រាកដថាអាចធ្វើបានមុនសវនាការនៅថ្ងៃច័ន្ទ ហ្នឹងទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាបន្ត អង្គជំនុំជម្រះបង្ហាញបញ្ជាក់អំពីការពាក់ព័ន្ធទៅនឹងការជំទាស់របស់មេធាវីការពារក្ដី អៀង សារី ទៅនឹងការបង្ហាញរបស់សហព្រះរាជអាជ្ញាកាលពីព្រឹកមិញ អង្គជំនុំជម្រះយល់ឃើញថាមិនបញ្ហាអ្វីទេសម្រាប់អង្គជំនុំជម្រះ ទាក់ទងនឹងការបង្ហាញរបស់សហព្រះរាជអាជ្ញានេះ ដែលពាក់ព័ន្ធ ទៅនឹងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងនៃអ.វ.ត.ក។ អង្គជំនុំជម្រះអាចនឹងស្ដាប់សក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងពិនិត្យភស្តុតាងផ្សេងៗទៀតមុននឹងធ្វើការសម្រេចនៅពេលចុងក្រោយ។ នេះជាបញ្ហាការបញ្ជាក់ ហើយដើម្បីឱ្យបានកាន់ច្បាស់លាស់ទៀត សូមប្រគល់នាទីទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីបញ្ជាក់បន្ថែមជាភាសាអង់គ្លេស។

[១៣:៤០:៥៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថាការប្រែជាភាសាអង់គ្លេសនេះ គឺមានកំហុស មានបញ្ហាបន្តិចបន្តួច។ ចំណុចនេះគឺវាទាក់ទងទៅនឹងសំណើពីខាងមេធាវីលោក អៀង សារី។ អង្គជំនុំជម្រះគឺមិនឆ្លើយតបទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងនៅក្នុងទទ្បីករណ៍នោះទេ។ អង្គជំនុំជម្រះនឹងមិនធ្វើការឆ្លើយតបថាតើនៅធ្វើការសម្រេចនៅពេលណានោះឡើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយបញ្ហាមួយទៀត អង្គជំនុំជម្រះសួរទៅភាគីពាក់ព័ន្ធនៅក្នុងសំណុំរឿងក្ដី០០២ នេះ អំពីតម្រូវការពេលវេលានៅក្នុងការសួរទៅកាន់សាក្សីចំនួនពីររូប គឺសាក្សីTCW-766 ហើយនិងសាក្សី TCW-542។ អង្គជំនុំជម្រះមិនទាន់ មិនចង់បានចម្លើយ និងការឆ្លើយបញ្ជាក់អំពីបញ្ហានេះនៅពេលនេះទេ ប៉ុន្តែអង្គជំនុំជម្រះនឹងសុំឱ្យបានលទ្ធផលនោះនៅថ្ងៃស្អែក ដើម្បីអង្គជំនុំជម្រះយកទៅពិនិត្យពិចារណា និងកំណត់នូវពេលវេលាក្នុងការបែងចែកពេលវេលានាំឱ្យកិច្ចដំណើរការសួរដេញដោលប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

[១៣:៤២:២៣]

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកា--

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ យើងរីករាយនឹងផ្តល់ជូនរយៈពេលរបស់យើងនៅ-- ចំពោះការសួរទៅកាន់លោកមកពីខាង ឌី.ស៊ី.ខេម។ ថាតើចំពោះសាក្សីរូបនេះ យើងស្តាប់គាត់មួយថ្ងៃ ឬក៏មួយថ្ងៃជាង? សូមឲ្យលោកអង្គជំនុំជម្រះធ្វើការបញ្ជាក់ លោកចៅក្រមធ្វើការបញ្ជាក់។

សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៤:៤៧]

**ប្រធានអង្គជំនុំ៖**

ជាចម្លើយតបគឺមានបញ្ហាពីរ ទីមួយនៅក្នុងការស្តាប់សក្ខីកម្មសាក្សីដែលយើងនឹងអញ្ជើញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺអង្គជំនុំជម្រះកំណត់នូវការសួរដេញដោលនោះ តែលក្ខណៈទូទៅនៃកិច្ចដំណើរការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប៉ុណ្ណោះ មិនមែនធ្វើកិច្ចដំណើរការនីតិវិធីសួរបញ្ជាក់នូវឯកសារមួយម្តងៗនោះទេ។

បញ្ហាទីពីរ គឺអង្គជំនុំជម្រះចង់ដឹងអំពីពេលវេលា ដែលតម្រូវការរបស់ភាគី ប៉ាន់ស្មាន និងប្រមើលមើលនៅក្នុងការតាំងសំណួរចំពោះសាក្សីទាំងពីររូបនេះ ដោយពេលវេលាដាច់ដោយឡែកពីគ្នារវាងសាក្សី TCW-766 ហើយនិង TCW-542។ អង្គជំនុំជម្រះនឹងប្រមូលព័ត៌មាននោះមក ហើយនិងអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចមួយកំណត់ពេលវេលាសមស្របសម្រាប់ភាគី ដែលពាក់ព័ន្ធនៅក្នុងការសួរទៅសាក្សី។ ដូច្នេះច្បាស់ហើយ មិនមែនអង្គជំនុំជម្រះសួរទៅភាគី ហើយភាគីសួរមកអង្គជំនុំជម្រះវិញទេ គឺឲ្យលោកប៉ាន់ស្មានបឋមសិនទៅ ថាតើវាត្រូវការពេលវេលាប៉ុន្មាន ភាគីនីមួយៗអង្គជំនុំជម្រះនឹងបូកសរុប និងគិតពិចារណា និងសម្រេចយ៉ាងជាក់លាក់ដើម្បីធ្វើឲ្យកិច្ចដំណើរការសវនាការដេញដោល ប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាព។

ជាបន្តទៅនេះអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាមានរយៈពេល៤៥នាទី ក្នុងការលើកឡើងនូវអំណះអំណាងតប ទៅនឹងការជំទាស់របស់ក្រុមមេធាវីទាំងបីក្រុមនូវឯកសារឧបសម្ព័ន្ធA3។ សូមអញ្ជើញ!

[១៣:៤៧:១៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទសូមអរគុណលោកប្រធាន។ បន្ទាប់ពីបានស្តាប់ការនិយាយរបស់ភាគីការពារក្តីព្រឹកមិញនេះ គឺថា ខ្ញុំគិតថា ជាមិនមែនការសមស្របទេ ដែលយើងនិយាយអំពីលក្ខណៈវិនិច្ឆ័យ នៅចំពោះមុខអង្គជំនុំជម្រះ។ នេះគឺស្តង់ដារអប្បបរមា នៃ-- ទាក់ទងនឹងភាពទទួលយកបាន ទាក់ទងទៅនឹងយុត្តិសាស្ត្រដែលមានមកហើយ។ បើតាមចំណាប់អារម្មណ៍ដំបូងនោះ ថាតើឯកសារដែលដាក់ជូនទៅអង្គជំនុំជម្រះនោះ គួរឲ្យទុកចិត្តបានដែរឬទេ ឬក៏មានភាពពាក់ព័ន្ធដែរឬទេ? ឬក៏សុទ្ធតែជាឯកសារក្លែងក្លាយ? យើងសូមរំឭកថា យុត្តាធិការអន្តរជាតិនោះ គឺថា បង្កើតឲ្យមានខ្សែចង្វាក់កាន់កាប់ឯកសារ មិនមែនជាការតម្រូវចាំបាច់ ដែលថាភាគីការពារក្តីតម្រូវតាំងពីដើមមកនោះទេ។ វាមិនជាការចាំបាច់ទេក្នុងការផ្ទៀងផ្ទាត់សម្រាប់ឯកសាររាប់ពាន់ឯកសារ ដែលមាននោះ ដែលថា ដឹងថាអ្នកណាអ្នករកឃើញឯកសារនេះបាន ហើយអ្នកណាអ្នកផ្តល់ជូន ហើយក្នុងកាលៈទេសៈណា។

បើយើងឈរលើមូលដ្ឋាន ដែលថាតម្រុយនៅខាងក្រៅ នៅខាងក្នុងនៃភាពដែលជឿជាក់បាននេះ ហើយនិងការរៀបចំឯកសារ កាន់កាប់ឯកសារនេះ យើងត្រូវចោទសំណួរទៅលើតម្លៃភស្តុតាង ថាតើឯកសារនៅក្នុងឧបសម្ព័ន្ធ៣ នេះគួរឲ្យទុកចិត្តបាន ឬក៏មានភាពពាក់ព័ន្ធដែរឬក៏អត់?

[១៣:៤៩:០៥]

ខ្ញុំបានឮអម្បាញ់មិញនេះទាក់ទងនឹងវិធាន៨៧(៣) នេះ។ ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវី កាណា-វាស អម្បាញ់មិញនេះ។ គាត់សុំឲ្យសហព្រះរាជអាជ្ញា បង្ហាញភស្តុតាងលើភាពជឿជាក់បាន ហើយនិងយថាភាព ហើយនិងសុំឲ្យមានផ្តល់សក្ខីកម្មផងដែរ ហើយការធ្វើយ៉ាងដូច្នេះគឺថា ចង់បំបិទមាត់ខាងសហព្រះរាជអាជ្ញាតែម្តង។ តាំងពីដើមសវនាការមកនោះគឺថា អ្វីដែលយើងធ្វើគឺថា យើងគ្រាន់តែចង់បង្ហាញពីទស្សនៈរបស់យើង ទស្សនៈរបស់ព្រះរាជអាជ្ញាទៅលើធាតុផ្សំ នៃភស្តុតាងដែលមាននៅក្នុងសំណុំរឿង ដែលខាងការពារក្តីក៏មានដែរ។ អ៊ីចឹងគឺថា ភាគីការពារក្តីគេមានសេរីភាពធ្វើអ្វីក៏បានដែរស្រេចតែគេ គេអាចស្តីបន្ទោសយើង គេអាចបន្ទោសលើខ្លឹមសារ អត្ថបទ ឬក៏ថាក្រុម ឬក៏ផ្នែកផ្សេងៗនៃអត្ថបទទាំងអស់នោះ។

នេះគឺជាតួនាទីរបស់យើងក្នុងការធ្វើការងារនេះ ហើយក៏ជាកាតព្វកិច្ចរបស់យើងដែរ។ ហើយក្នុងឯកសារជាច្រើននៅក្នុងឧបសម្ព័ន្ធ៣ នេះគឺថាមានឯកសារ២៧ ដែលមានការអត្ថាធិប្បាយ ហើយ

នៅក្នុងឯកសារ E158។ បើសិនមានកំណត់ហេតុ៣១ នោះ មិនមានអត្ថាធិប្បាយទេ ពីព្រោះថា មានតែឯកសារចំនួន៩៧៨ តែប៉ុណ្ណោះ ដែលមានបញ្ចូលនូវព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[១៣:៥១:០១]

យើងមានការប្រជុំរបស់គណៈអចិន្ត្រៃយ៍ គឺថាមានកំណត់ហេតុ២២ ហើយ២៦ របស់យោធា ការប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រីមានពីរ ហើយនិងនៅក្រសួងផ្សេងៗទៀត ហើយគឺយើងឃើញមានកំណត់ហេតុបី នៅពាណិជ្ជកម្មអន្តរជាតិ ហើយមានកំណត់ហេតុមួយ ដែលបានលើកឡើងកាលពីព្រឹកមិញនោះគឺថាចេញមកពីសភាតំណាងប្រជាជនកម្ពុជា ហើយខ្ញុំយោងទៅលើឯកសារមួយនេះ ហើយខ្ញុំព្រឹកមិញនេះ ខ្ញុំបានលើកឧទាហរណ៍មួយ ទាក់ទងនឹងឯកសារនេះ។ ឥឡូវនេះ ខ្ញុំសូមឆ្លើយតបទៅនឹងភាគីការពារក្តីរបស់លោក នួន ជា ថាឯកសារមួយចំនួនដែលអានមិនដាច់នោះ ខ្ញុំសូមបញ្ជាក់ជូនអង្គជំនុំជម្រះ ហើយនិងសាធារណជនថា នៅ*ហ្វាយឡេប* នោះយើងអានស្រួលជាង ជាងពេលដែលយើងបញ្ចាំងនៅលើកញ្ចក់អេក្រង់នៅទីនេះ។

ជាការពិតណាស់ដែលថាឯកសារនេះពិបាកអាន ក៏ប៉ុន្តែវាមិនមែនជាថា ការមួយមិនអាចអានដាច់នោះទេ ព្រោះថាមានការបកប្រែជាភាសាបារាំង ហើយនិងអង់គ្លេសរួចទៅហើយ។ ទោះបីជាគឺថាមានផ្នែកណាមួយ ឬក៏បន្ទាត់ណាមួយមិនអាចអានបាន នេះគឺថា មិនមែនជាមូលហេតុដែលថា ធ្វើឲ្យឯកសារនោះមិនអាចទុកចិត្តទៅបានទេ ពីព្រោះថា មានផ្នែកធំដែលគេអានដាច់។

[១៣:៥២:៤៥]

ទាក់ទងទៅនឹងភាពពាក់ព័ន្ធទៅនឹងឯកសារទាំង៥៨នេះ ដែលទាក់ទងទៅនឹងសំណុំរឿងទីមួយនេះ។ ភាគីការពារក្តីរបស់ នួន ជា ភ្លេចថា ការពិភាក្សានេះមិនមែនកម្រិតត្រឹមតែថា ការជម្លៀសប្រជាជនដំណាក់កាលទីមួយ ទីពីរ នោះទេ ក៏ប៉ុន្តែវាបានពង្រីកទៅផ្នែកផ្សេងទៀត នៃដីកាដំណោះស្រាយគឺថាដែលមានតាំងពីលេខកថាខណ្ឌរៀបរាប់ប្រាប់ទៀតផង។ ឯកសារដែលនៅក្នុងឧបសម្ព័ន្ធទី៣ នេះគឺថាសុទ្ធតែជាឯកសារដែលមានភាពពាក់ព័ន្ធ ហើយពាក់ព័ន្ធទៅនឹងគណៈមជ្ឈិមយោធាកម្ពុជាប្រជាធិបតេយ្យ គឺថានៅពេលដែលយើងអានកំណត់ហេតុនៃកិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍ គឺថា យើងឃើញមានសមាសភាព នៃគណៈអចិន្ត្រៃយ៍នេះ។ ហើយយើងឃើញពីតួនាទី និងមុខងាររបស់ជនជាប់ចោទទាំងអស់នោះ។ នៅពេលដែលយើងអានកំណត់ហេតុទាំងអស់នេះ យើងយល់ថា តើអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះទាក់ទងគ្នាយ៉ាងម៉េច ឬធ្វើការយ៉ាងម៉េចក្នុងការធ្វើឧក្រិដ្ឋកម្មសហកម្មរួម ហើយថាការនោះសម្រេច

ចិត្តធ្វើយ៉ាងម៉េច ហើយនិងបញ្ជូនព័ត៌មានទាំងអស់នោះទៅថ្នាក់ក្រោមយ៉ាងម៉េច? អ្នកដែលនៅក្រោមបង្គាប់នោះ។

[១៣:៥៤:២៥]

ទាក់ទងទៅនឹងឯកសារនៃកំណត់ហេតុរបស់គណៈយោធា គឺថាពេលយើងអានឯកសារទាំងអស់នោះ យើងអាចយល់ពីរចនាសម្ព័ន្ធយោធា នៃកងទ័ពបដិវត្តន៍កម្ពុជា និងបេសកកម្មចម្បងរបស់ខ្លួន។ ផ្នែកទាំងអស់នេះ នៃដីកាដំណោះស្រាយ មាននៅក្នុងការជំនុំជម្រះលើកទី១ នេះ។ ឯកសារខ្លះនោះមិន កម្រមានដែរ ក៏ប៉ុន្តែមាននិយាយអំពីការជម្លៀសដំណាក់កាលទី១ និងទី២។

ខ្ញុំគ្រាន់តែសូមលើកឧទាហរណ៍ពីរ ដែលដកចេញពីឯកសារ E109/4.3 ដែលទាក់ទងទៅនឹងដំណាក់កាលទីមួយ នៃការកាត់សេចក្ដីនេះយើងនេះ។ នៅកូឡោនចុងក្រោយ គឺថាមាននៅក្នុងដីកាដំណោះស្រាយ គឺថាមានលើកពីចំណុចពាក់ព័ន្ធនៃឯកសារនីមួយៗ។ បើខ្ញុំលើកឧទាហរណ៍ពីរ ដែលថាដោយចៃដន្យ ឯកសារ E13.7 ដែលជាឯកសារចេញថ្ងៃទី០៨ មីនា ឆ្នាំ១៩៧៦ កំណត់ហេតុនៃកិច្ចប្រជុំលើការឃោសនា។ គឺថាមានការពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធគណៈមជ្ឈិម ដែលក្រសួងផ្សេងៗនៃរដ្ឋាភិបាលសម័យនុំង ហើយក៏មានពាក់ព័ន្ធទៅនឹងទំនាក់ទំនងនៅក្នុងគណៈមជ្ឈិម ទាក់ទងទៅនឹងវិទ្យុរបស់រដ្ឋ ហើយនិងតួនាទីរបស់ជនជាប់ចោទ ដែលខ្លួនជាសមាជិករបស់គណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍។

[១៣:៥៦:៣០]

ឯកសារ IS13.34 គឺថាមានឧទាហរណ៍នៃកំណត់ហេតុនៃគណៈយោធា ដែលចុះថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៦ ប្រជុំរវាងលេខា អនុលេខា គណៈកងពល ហើយនិងវរសេនាធំ។ និយាយក្នុងនេះ គឺថាមាននិយាយអំពីរចនាសម្ព័ន្ធយោធា និងប្រព័ន្ធទាក់ទងរវាងយោធា រវាងកងពល ហើយនិង--។

ឥឡូវនេះខ្ញុំបកមកនិយាយអំពីប្រភេទឯកសារធំៗពីរ គឺថាកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា គឺថាមានកិច្ចប្រជុំមួយចំនួន ដែលកំណត់ហេតុ ជាពិសេស គឺប្រជុំយោធា។ នៅក្នុងគណៈអចិន្ត្រៃយ៍មានកំណត់ហេតុដែលនៅសល់។ ជនជាប់ចោទ ខៀវ សំផន បានធ្វើសេចក្ដីថ្លែងការណ៍ដូចតទៅនេះ នៅថ្ងៃទី២៣ ខែ១១ ឆ្នាំ២០១១ នៅចំពោះមុខអង្គជំនុំជម្រះ។ គាត់និយាយអំពីចំនួនទំព័រ រាប់ពាន់ទំព័រនៅក្នុងសំណុំរឿង គាត់លើកឡើងយ៉ាងដូច្នេះ។

[១៣:៥៨:០៤]

បើសិនជាអស់លោកបានអានឯកសារទាំងអស់នេះ ថាតើលោកអាចចាត់ទុកថា ខ្ញុំជាសមាជិកគណៈកម្មាអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាបានដែរឬទេ ក្នុងខណៈដែលពុំមានឯកសារណាមួយនៃសំណុំរឿងមិនបានចង្អុលប្រាប់ថា ខ្ញុំជាសមាជិកនៃគណៈអចិន្ត្រៃយ៍នោះទេ? ហើយលោកមានតែកំណត់ហេតុចំនួន១៩តែប៉ុណ្ណោះនៃកិច្ចប្រជុំទាំងអស់នោះ នៅលើចំនួនកំណត់ហេតុចំនួនជាង១០០កំណត់ហេតុដែលបានធ្វើឡើងនៅក្នុងចន្លោះឆ្នាំ៧៥ និង៧៩។

ខ្ញុំសូមលើកថែមទៀត បើសិនជាអស់លោកបានអានឯកសារទាំងអស់នោះ តើលោកអាចធ្វើជឿថា ខ្ញុំមានជាប់ពាក់ព័ន្ធដែរ ឬទេ? ពីព្រោះថានៅលើ-- លោកមានតែកំណត់ហេតុចំនួន១៩តែប៉ុណ្ណោះ។

[១៣:៥៩:១០]

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមានតែ១៤ អ៊ីចឹង ដូច្នេះខ្ញុំពុំមានជាប់ពាក់ព័ន្ធអីទៅនឹងឧក្រិដ្ឋកម្មដែលចោទប្រកាន់មកលើខ្ញុំនោះទេ។ ហើយអស់លោកនឹង-- ពេលនោះ ខៀវ សំផន និយាយទៅកាន់សហព្រះរាជអាជ្ញា។ សេចក្តីប្រកាសនេះមាននៅក្នុងប្រតិចារឹកថ្ងៃទី២៣ វិច្ឆិកា E1/15.1 ហើយគឺថានៅម៉ោងប្រាំបួនហាសិបបួន។ លោកស្រីចៅក្រមជាទីគោរព គឺថាអស់លោកចៅក្រមនឹងចាំនឹងពាក្យ អះអាងរបស់ជនជាប់ចោទរូបនេះដែលកាលនោះស្គាល់ ទទួលស្គាល់នូវការជឿជាក់បាននៃកំណត់ហេតុទាំង១៩នេះ។ បើតាមយើងរាប់នោះ ថាវាមានលើសពី១៩ គឺមានដល់ទៅ២២ឯណោះ។ កាលនៅថ្ងៃទី១៩ វិច្ឆិកា ឆ្នាំ២០០៧ នៅពេលដែលនិយាយចំពោះមុខអង្គ-- ចៅក្រមស៊ើបអង្កេត ខៀវ សំផន បានគាត់ថាបានចូលកិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍ជាច្រើនដង។ ជាការពិតណាស់ដែលខ្ញុំបានចូលរួមនៅក្នុងគណៈអចិន្ត្រៃយ៍ដែលពេលនោះ គឺយើងនិយាយអំពីបញ្ហាទូទៅតែប៉ុណ្ណោះ។ ឧទាហរណ៍ដូចជា ការការពារជាតិ កសាងជាតិ សង្គ្រាមជាមួយវៀតណាម ឬក៏ការលាលែងពីតំណែងរបស់ នរោត្តម សីហនុ។

[១៤:០១:០១]

ឯកសារ C27 ទំព័របារាំងទី៥ នៅក្នុងសៀវភៅគាត់ដែលសរសេរនៅឆ្នាំ២០០៧ ទាក់ទងនឹងការពិចារណាលើប្រវត្តិថ្មីៗរបស់ប្រទេសកម្ពុជា ខៀវ សំផន បានអះអាងថា ប៉ុល ពត និង នួន ជា មានវត្តមាននៅក្នុងកិច្ចប្រជុំថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៧៦ គឺថាយើងការអះអាងនេះនៅទំព័រជាភាសាអង់គ្លេស 00498263 ទៅដល់ 64 ជាភាសាបារាំង 00643868 ទៅដល់ 69 ជាភាសាខ្មែរ 00380427 ទៅដល់ 28។ គាត់បានអះអាងផងដែរថា មានកំណត់ហេតុនៅឆ្នាំ១៩៧៦ ទាក់ទងទៅនឹងរបបអង្គរដែលផ្ទុះបញ្ចាំងអំពីគំនិតរបស់ ប៉ុល ពត។ គាត់បានគូសបញ្ជាក់ថា កំណត់ហេតុទាំងអស់នេះត្រូវបានចែកចាយ

ទៅមនុស្សតិចជាង១០នាក់ ពីព្រោះថាវាមានលក្ខណៈសម្ងាត់ខ្លាំងមែនទែន។

[១៤:០២:២៥]

ខ្ញុំសួរមានសំណួរមួយ ព្រោះព្រឹកមិញខ្ញុំបានឮមេធាវីរបស់ ខៀវ សំផន បានមកចោទជាបញ្ហានៅលើ មិនគួរឲ្យទុកចិត្តបានលើឯកសារយោធា ឬក៏កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍។

ខ្ញុំសួរថា តើមេធាវីរបស់ ខៀវ សំផន អាចមកសើរើលើភាពមិនអាចទុកចិត្តបាននៃឯកសារទាំងអស់នេះ ដោយយកហេតុថាការកាន់កាប់ហ្នឹងមិនត្រូវបានបង្ហាញច្បាស់លាស់ ហើយជនជាប់ចោទខ្លួនឯងនោះ ក៏បានប្រាប់ដែរថាខ្លួនឯងបានចូលរួមទៅក្នុងកិច្ចប្រជុំនៃគណៈអចិន្ត្រៃយ៍ ហើយដឹងថាមានកំណត់ហេតុទៀតផង។

មេធាវី ខៀវ សំផន ថាតើដឹងថាតើនេះជាការកែប្រែគោលជំហររបស់ជនជាប់ចោទ ឬក៏គាត់បានទទួលបញ្ហាពីជនជាប់ចោទ? ខ្ញុំគិតថា ខៀវ សំផន មិនគួរថាមិនទទួលស្គាល់ឯកសារទាំងអស់នេះទេ គឺថា ឧទាហរណ៍ E131 ក្រុម ខៀវ សំផន បានលើកឡើងថាខ្លួនមានចេតនា លើកឡើងថាមានកំណត់ហេតុបីដែលមានទំនាក់ទំនងជាមួយនឹងសាក្សីទីមួយ។ នៅក្នុងឯកសារនេះពុំមានលក្ខខណ្ឌ ឬក៏មានការជំទាស់មួយដែលទាក់ទងទៅនឹងឯកសារទាំងបីនោះទេ ដែលគាត់ចង់បង្ហាញទៅដល់សាក្សីមួយចំនួន គឺជាកំណត់ហេតុកិច្ចប្រជុំថ្ងៃទី៩ តុលា ឆ្នាំ១៩៧៥ ដែលមានលេខកូដ IS13.2 ដែលចេញថ្ងៃទី១៣ មីនាឆ្នាំ១៩៧៨-- ៧៦ IS13.11, D279/7.2 ហើយកិច្ចប្រជុំមួយទៀតនៅថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦ IS13.14, D279/7.1 គាត់ចង់បដិសេធឯកសារទាំងបីនេះ ដែលមិនអាចជំទាស់ទៅនឹងឯកសារទាំងអស់នេះបានទេ។ យើង-- ចំពោះមេធាវីរបស់ នួន ជា, អៀង សារី ដែលថាកូនក្តី-- គាត់នឹងក៏មានវត្តមានទៅហ្នឹងក្នុងកិច្ចប្រជុំទាំងអស់ហ្នឹងដែរ ហើយយើងចង់បានទទួលប្រតិកម្មរបស់ខាងភាគីការពារក្តី។

[១៤:០៦:០២]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យគាត់បន្ថយបន្តិច ពីព្រោះអ្នកបកប្រែតាមអត់ទាន់ទេ លោកប្រធាន។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសំណួរនោះត្រូវបានចោទ ហើយ-- អ៊ីចឹងយើងនឹងទទួលប្រតិកម្មពីខាងភាគីការពារក្តីវិញ។ នេះគឺថាទាក់ទងទៅនឹងកំណត់ហេតុនៃកិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍។ ខ្ញុំនឹងពង្រីកប្រធានបទនេះបន្តិច

ហើយខ្ញុំចង់និយាយថា ១៨ កំណត់ហេតុលើ២២ គឺថាមានសរសេរឈ្មោះអ្នកចូលរួមទៅកិច្ចប្រជុំទាំងអស់នោះ។ បើតាមឯកសារនេះ នួន ជា មានវត្តមានរហូត ប៉ុល ពត ចូលរួម ថា១៧/១៨ មានឈ្មោះអ្នកចូលរួមទាំងអស់ ហើយ ខៀវ សំផន នោះ ចូលរួម១៥/១៨ ហើយ អៀង សារី នោះ គឺ១០ដង។

អ៊ីចឹង គឺថាកំណត់ហេតុទាំង២២ នោះ គឺថាមានលក្ខណៈមានគ្នា ហើយមានខ្នាតហ្នឹងក៏ដូចគ្នាដែរ មានលក្ខណៈពិសេសដូចគ្នា គឺថាទៅជាលើទំព័រ*អាកាត់* (A4)។ នៅ-- បញ្ហាដែល និយាយ នៅក្នុងកំណត់ហេតុទាំងអស់នេះ គឺថាសុទ្ធតែជាបញ្ហាៗរបស់រដ្ឋ ដែលអនុលោមទៅតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឧទាហរណ៍ ដូចជាការពារជាតិ កិច្ចការបរទេស ដែលទាំងអស់នេះសុទ្ធតែជាប្រធានបទសំខាន់ៗ ដែលមាននៅក្នុងកំណត់ហេតុ១៥/២២ នេះ។

[១៤:០៨:០៥]

ការពិតនៃកំណត់ហេតុទាំងអស់នេះ គឺថាវាមានការស៊ីសង្វាក់គ្នារវាង-- នៅលើពាក្យពេចន៍របស់សាក្សីដែលបានលើកឡើងនោះ គឺថាមានTCW និងសាក្សីមួយចំនួននោះ ដែលបានលើកឡើងហើយវាមានភាពស៊ីសង្វាក់គ្នា។ ឧទាហរណ៍ទាក់ទងទៅនឹងកិច្ចការពាណិជ្ជកម្មនៃរបបនុំង ហើយនិងគណៈប្រតិភូ ឬក៏ការផ្ទេរមុខងារនៃគណៈកម្មការផ្សេងៗនៃបក្ស។ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឯកសារ D311/2 ចុះថ្ងៃទី១៦ តុលា ឆ្នាំ២០០៩ និយាយ-- បានអះអាងថា ឌី.ស៊ី.ខេម មានឯកសារដើម។ គឺថាឯកសារ IS13.1, IS13.24, IS13.2។ ២០/២២ នៃឯកសារប្រជុំនៅគណៈកម្មាធិការអចិន្ត្រៃយ៍នោះ ត្រូវបានទទួលបញ្ចូលទៅក្នុងមូលទិន្នន័យនៃ ឌី.ស៊ី.ខេម គឺថា E38។

[១៤:០៩:៣៨]

អ្នកជំនាញ TCE-38 គាត់នឹងបញ្ជាក់ថាគាត់បានទទួលឯកសារទាំងអស់ក្នុងកាលៈទេសៈណាហើយមានតម្រុយបឋមដែលមានផ្តល់ទៅក្នុងជាសំណៅអង់គ្លេស គឺថា D267/5/1.1.25 ដែលមានតែជាភាសាអង់គ្លេសទេ ឥឡូវនេះ ហើយនៅទំព័រទីបី។ គាត់ពន្យល់នៅក្នុងសេចក្តីផ្តើមនៃឯកសារនុំងនៅក្នុងឯកសារ IS14.1 គាត់បញ្ជាក់ថា គាត់រកបានឯកសារនោះតាមរបៀបណា? ហើយនិងកំណត់ហេតុនៃគណៈអចិន្ត្រៃយ៍នោះតាមរបៀបណា? គាត់ពន្យល់ថា ឯកសារទាំងអស់នេះត្រូវបានរកឃើញដោយមនុស្សម្នាក់បានផ្តល់ជូនទៅឲ្យគាត់ ដាក់នៅផ្ទះមួយដែលអៀង សារី ប្រហែលជានៅកន្លែងនោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែល-- ក្នុងខណៈដែលជនជាប់ចោទ ខៀវ សំផន ស្គាល់-- ទទួលស្គាល់តម្លៃនៃកំណត់ហេតុ ១៩/២២ នេះ។ អ៊ីចឹងបាន

ន័យថា ខ្សែចង្វាក់នៃការកាន់កាប់ឯកសារនោះមិនសំខាន់ប៉ុន្មានទេ។ នេះជាតម្រុយនៃភាពអាចគួរឲ្យទុកចិត្តបាននៃឯកសារទាំងអស់នេះ ហើយសូមឲ្យអង្គជំនុំជម្រះគិតពីបញ្ហានេះ។

[១៤:១១:១៣]

មានឯកសារពីរដែលទទួលបានពី ស៊ី.ឌី.ខេម ដែលទទួលបានពីក្រសួងមហាផ្ទៃនៅឆ្នាំ១៩៨៦ ហើយ២២ឯកសារទៀតទទួលបាននៅខែ៧ ឆ្នាំ២០០៧ ហើយឯកសារទី២២ នោះបានខាងសហចៅក្រមស៊ើបអង្កេតបានរកឃើញនៅពេលដែលគាត់ស៊ើបអង្កេត។ ដូច្នេះគឺថាមាន ១៧/២២នេះ ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០១។ ខ្ញុំនឹងផ្តល់ឧទាហរណ៍ មួយចំនួនដោយខ្លីៗដែលគាំទ្រលើឯកសារទាំងអស់នេះ។

ដូច្នេះ វានឹងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះយល់ឃើញថា ការសម្រេចនេះគឺយោងទៅលើអង្គហេតុដែលមានចែងនៅក្នុងឯកសារ ឬសក្ខីកម្មផ្សេងទៀត។ ខ្ញុំផ្តល់ឧទាហរណ៍បួន កំណត់ហេតុបីនៃគណៈអចិន្ត្រៃយ៍ ដែលបានបញ្ជាក់ពីភាពចាំបាច់ក្នុងការកសាងអាកាសយានដ្ឋានយោធាថ្មីមួយ គឺឯកសារកំណត់ហេតុ IS13.2 ISគឺចុះនៅថ្ងៃទី៩ តុលា ឆ្នាំ៧៥ IS13.5 គឺ-- ហើយនិង IS13.14 ពីថ្ងៃទី-- នៅក្នុងឆ្នាំ៧៦។

[១៤:១២:៥៧]

នៅក្នុងកំណត់ហេតុពីរដំបូង គឺនៅទំព័រចុងក្រោយ គឺគេមាននិយាយថា គេមានការគិតទៅលើកន្លែងថ្មី ដើម្បីសាងសង់អាកាសយានដ្ឋាន គឺកំពង់ឆ្នាំង គឺត្រូវបានគេលើកឡើងថាជាលទ្ធភាពដែលត្រូវសាងសង់អាកាសយានដ្ឋាននៅទីនោះ។

នៅក្នុងកំណត់ហេតុទីបី គឺខែមេសា ឆ្នាំ៧៦ គឺគណៈអចិន្ត្រៃយ៍បានជ្រើសរើសរួចមកហើយគឺថាកំណត់កន្លែងនៃការសាងសង់អាកាសយានដ្ឋានថ្មីនេះ។ ហើយគឺកំណត់ថា យកខេត្តកំពង់ឆ្នាំងដើម្បីសាងសង់។ ផ្ទុយទៅវិញយើងមានសក្ខីកម្មជាច្រើន សក្ខីកម្មជាលាយលក្ខណ៍អក្សរ គឺជាអ្នកដែលត្រូវបានសហចៅក្រមស៊ើបអង្កេតសម្ភាសន៍សួរសំណួរ គឺបានបញ្ជាក់ថាការសាងសង់អាកាសយានដ្ឋាននេះគឺបានសម្រេចដោយគណៈអចិន្ត្រៃយ៍ ហើយបានចាប់ផ្តើមនៅដើមឆ្នាំ១៩៧៦។

[១៤:១៣:៥៤]

នៅពេលដែលក្រុមសាងសង់ទីមួយបានមកដល់ទីកន្លែង ដើម្បីកាប់ឆ្ការកន្លែងនោះ។ នៅក្នុងឯកសារ D176/110 សាក្សីដែលមាននៅក្នុងបញ្ជីរបស់យើងគឺថាជាសាក្សី P243 នៅទំព័រទីបួន

គាត់បានពន្យល់ថា គាត់ត្រូវបានគេបញ្ជូនទៅកំពង់ឆ្នាំងនៅខែកុម្ភៈ ឆ្នាំ៧៦ ជាមួយនឹងក្រុម មួយក្រុមទៀត ដែលមានគ្នា១០នាក់ ដើម្បីធ្វើការនៅការដ្ឋានសាងសង់នោះ ហើយនិងមានជនជាតិចិន១0នាក់ នៅពេលដែលកន្លែងនោះគឺថានៅតែជាព្រៃនៅឡើយទេ មិនទាន់ត្រូវបានសាងសង់ទេ។

ហើយមានសក្ខីកម្មជាច្រើនទៀត ផ្សេងទៀតជាពិសេសគឺនៅក្នុងឯកសារ D232/81 ហើយនិងឯកសារ D232/89 គឺថាមានបុគ្គលដែលបានធ្វើការនៅក្នុងឆ្នាំ៧៦ នៅក្នុងការដ្ឋានអាកាសយានដ្ឋាននោះ ដែលបានសម្រេចដោយគណៈអចិន្ត្រៃយ៍។

ឧទាហរណ៍ទីពីរ កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅខែ២ (ស៊ីក) វិច្ឆិកា ឆ្នាំ៧៥ ដែលមានលេខឯកសារ IS13.3 គឺមានការពិភាក្សាគ្នាអំពីការទស្សនៈកិច្ចនៅប្រទេសថៃដោយលោក អៀង សារី។ ហើយហេតុការណ៍នោះ គឺថាត្រូវបានគាំទ្រដោយអត្ថបទ ញូវយ៉កថាមស៍ ដែលបញ្ជាក់អំពីទស្សនៈកិច្ចរយៈពេល៥ថ្ងៃរបស់លោក អៀង សារី នៅប្រទេសថៃ ចាប់ពីថ្ងៃទី២៨ តុលា ឆ្នាំ៧៥។ នេះគឺជាឯកសារព័ត៌មានមួយទំព័ររបស់សារព័ត៌មាននេះ ដែលមានលេខ D56-10.49-49។

[១៤:១៦:០៦]

ឧទាហរណ៍ទីបី គណៈអចិន្ត្រៃយ៍នៅក្នុងឯកសារ IS13.20 នៅថ្ងៃទី១៧ ឧសភា ៧៦ បានពិភាក្សាអំពីការចូលរួមនៅក្នុងសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធនៅក្នុងទីក្រុងកូឡុំបូ។ ដូច្នេះវា-- ចំណុចនេះគឺថា បានពង្រឹងដោយរបាយការណ៍របស់វិទ្យុភ្នំពេញ គឺ-- ហើយនិងឯកសាររបស់អែហ្វ.បេ.អ៊ី.អេស គឺ D162 នៅថ្ងៃទី២ សីហា ដែលមាននិយាយអំពីការចូលរួមនៅក្នុងសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធនៅក្នុងទីក្រុងកូឡុំបូ។ ហើយឯកសារមួយទៀតនៅថ្ងៃទី១៦ សីហា ឆ្នាំ៧៦ គឺនិយាយអំពីសកម្មភាពរបស់ លោក ខៀវ សំផន និងលោក អៀង សារី នៅក្នុងសន្និសីទនៅក្នុងទីក្រុងកូឡុំបូទាំងនោះ។

ហើយជាចុងក្រោយឧទាហរណ៍ចុងក្រោយ គណៈអចិន្ត្រៃយ៍បានពិភាក្សានៅថ្ងៃទី១៣ មីនា ឆ្នាំ៧៦ អំពីការបង្កើតគណៈកម្មាធិការមួយដើម្បីពិនិត្យ និងរៀបចំទំនិញដែលត្រូវទិញ។ ហើយបានចាត់តាំងលោក ហែម គឺលោក ខៀវ សំផន នេះឯង ជាសមាជិកគណៈកម្មការនេះ ហើយលោក វ៉ាន់ គឺលោក អៀង សារី ជាសមាជិកពិគ្រោះយោបល់នៃគណៈកម្មការនេះ។ នេះជាឯកសារ IS13.11 ហើយមានលេខយោង D279/7.2។

[១៤:១៧:៥៤]

លោក ខៀវ សំផន ហាក់ដូចជាបានបញ្ជាក់អះអាងច្បាស់ណាស់ នៅពេលដែលការជជែកដេញដោលតទល់គ្នាអំពីមុខងាររបស់គាត់នេះ នៅក្នុងឯកសារ D25 គាត់និយាយថា មន្ទីរ-៨៧០ នោះទទួលបន្ទុកក្នុងការកំណត់នូវកម្រិតនៃតម្លៃ គឺនៅទំព័រទី៤ ជាភាសាអង់គ្លេស-- បារាំង។ ហើយលោកឃើញនៅក្នុងសំណុំរឿងដែរ ថាមានឯកសារជាច្រើន ដែលបានផ្ញើជូនលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងបញ្ហាពាណិជ្ជកម្ម គឺរបាយការណ៍ដែលផ្ញើជូនផ្ទាល់តែម្ដងទៅលោក ខៀវ សំផន ឬការចម្លងជូនដែលពាក់ព័ន្ធទៅនឹងការដឹកជញ្ជូន ឬក៏ការនាំចូលទំនិញមកកាន់កម្ពុជាប្រជាធិបតេយ្យ។ ហើយជាឧទាហរណ៍មានឯកសារបី IS18.18, IS18.19 ឬក៏ឯកសារ D366/7.1.148 ដែលឯកសារទាំងអស់នេះ គឺពាក់ព័ន្ធទៅនឹងបញ្ជីនៃសម្ភារៈដែលនាំចូលមកពីប្រទេសចិនតាមកប៉ាល់។

[១៤:១៩:០៩]

ឥឡូវនេះខ្ញុំនឹងនិយាយអំពីកំណត់ហេតុ២៦ នៃឃោធាដែលមាននៅក្នុងឧបសម្ព័ន្ធA3 នេះ។ ក្នុងចំណោមឯកសារទាំង២៦ នេះ គឺមានកំណត់ហេតុជាង១៥ នៃកិច្ចប្រជុំរបស់លេខា និងអនុលេខាកងពលធំ ហើយនិងវរសេនាធំ ឬក៏កិច្ចប្រជុំរបស់លេខានៃផ្នែកសេដ្ឋកិច្ចនៃកងពលទាំងអស់នេះ។ ហើយឯកសារផ្សេងទៀតនោះ គឺជាកំណត់ហេតុនៃកិច្ចប្រជុំជាក់លាក់ជាងនេះ។ ឧទាហរណ៍ គឺពាក់ព័ន្ធទៅនឹងកងពលធំមួយច្បាស់លាស់ គឺកងពលធំលេខ១០០ របស់-- (សុំទោស) គឺកងពលធំរបស់គណៈមជ្ឈិម។

[១៤:២០:០២]

ដូច្នេះ យើងថាគឺមានឯកសារជាច្រើន ដែលបញ្ជាក់ថាអ្នកចូលរួមនោះ គឺថាជាបុគ្គលដដែលៗនៅក្នុងកិច្ចប្រជុំ ហើយចំពោះកិច្ចប្រជុំទូទៅ គឺដោយ-- ជាកិច្ចប្រជុំសម្របសម្រួល និងផ្ដល់ជូនព័ត៌មាននោះ គឺបងលេខ៨៩ ដែល សុន សេន ដែលជាអ្នក-- ដែលអ្នកធ្វើជាអធិបតីក្នុងកិច្ចប្រជុំទាំងអស់នោះ ហើយនិងមានមេដឹកនាំ ឬក៏ជំនួយការរបស់មេដឹកនាំនៃកងពលធំ ដែលមានលោក អឿន នៃកងពលធំ ៤៥០ លេខ៤៥០ ដែលដឹកនាំដោយលោក សួន, ហើយកងពលធំ៧០៣ ដែលដឹកនាំដោយ ពិន, កងពលធំ៥០២ ដឹកនាំដោយលោក ម៉េត, កងពលធំ២៩០ ដឹកនាំដោយ តាល់, កងពលធំ១៦៤ ដឹកនាំដោយ មុត។ ហើយគឺជាញឹកញាប់ គឺថាការប្រជុំនោះត្រូវធ្វើរបាយការណ៍ទៅវរ:-- ទៅអនុសេ-- ទៅខាង សុន សេន ដែលជានាយសេនាធិការ។

[១៤:២១:១៧]

ហើយជាទូទៅ សុន សេន គាត់ជាអ្នកធ្វើអនុសាសន៍ចុងក្រោយ បន្ទាប់ពីបានស្តាប់មតិយោបល់របស់អ្នកចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នោះ បន្ទាប់មកធ្វើរបាយការណ៍។ ហើយយើងនឹងឃើញមេដឹកនាំធំៗផ្សេងទៀត បានចូលរួមនៅក្នុងកិច្ចប្រជុំដែលមានលក្ខណៈរឹតត្បឹតដូចជា ប៉ុល ពត ហើយនិងលោក វន វ៉េតជាដើម។

ហើយកិច្ចប្រជុំមួយចំនួន គឺមានតែកងពល៧០៣ ឬក៏មន្ទីរអង្គការ ហើយមន្ទីរស-២១ ក៏មានការចូលរួមផងដែរ។

នៅពេលដែលយើងអានកំណត់ហេតុកិច្ចប្រជុំទាំងអស់នេះ ប្រធានបទដែលនៅក្នុងរបៀបវារៈនៅក្នុងកិច្ចប្រជុំនោះ គឺពាក់ព័ន្ធទៅនឹងបេសកកម្មដែលផ្តល់ជូនទៅដល់កងយោធាមជ្ឈិមតាមរយៈរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ហើយជាពិសេសនៅមាត្រា១៩ គឺឯកសារ IS9.2 មាត្រា១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងថាបេសកកម្មនេះ គឺការពារយុទ្ធផលបដិវត្តន៍ ការពារប្រទេសឲ្យបានត្រឹមត្រូវ ហើយនិងការពារនូវភារកិច្ចអប់រំ ភារកិច្ចកសាងជាតិឲ្យបានត្រឹមត្រូវ។

លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាលេខ IS9.1 នៅក្នុងមាត្រា២៧ បានបញ្ជាក់ថា កងទ័ពគឺទទួលបន្ទុកនៅក្នុងសន្តិសុខផ្ទៃក្នុង ហើយនិងសន្តិសុខក្រៅប្រទេស ហើយនិងមានភារកិច្ចក្នុងការចូលរួមនៅក្នុងការកសាងជាតិ។

[១៤:២៣:០៥]

កិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅក្នុង នៅថ្ងៃទី៣០ ខែ៣ ៧៦ គឺលេខ IS13.21 បង្ហាញអំពីការបង្កបង្កើនផលខាងផ្នែកកសិកម្មរបស់ខាងកងទ័ព ហើយបញ្ជាក់អំពីតួនាទីរបស់យោធានៅក្នុងការការពារប្រទេសផង និងចូលរួមនៅក្នុងការងារបង្កបង្កើនផលផង។

ការប្រជុំនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ៧៦នេះ គឺមានកិច្ចប្រជុំទៀងទាត់ក្នុងចំណោមកំណត់ហេតុទាំង២៦ នេះ ហើយនៅក្នុងចំណោមកិច្ចប្រជុំនោះ គឺមានកងពលធំ កងវរសេនាធំ គាត់បានធ្វើរបាយ-ការណ៍អំពីការបង្កបង្កើនផលរបស់ខ្លួន។

[១៤:២៣:៥៨]

ហើយយើងកត់សម្គាល់ឃើញថា ក្នុងចំណោមកំណត់ហេតុទាំង២៦ នេះ គឺយើងនិយាយអំពីការបង្កបង្កើនផល ការផលិតស្រូវ ហើយនិងការកំណត់អត្តសញ្ញាណ ឬការកម្ទេចខ្មាំង ឬក៏ពួកជនក្បត់ ឬក៏ការប្រឈមមុខដាក់គ្នារវាងកម្ពុជា និងវៀតណាម ហើយនិងភារកិច្ចចាំបាច់នៅក្នុងការអប់រំ

នយោបាយដល់យោធានៅក្នុងកងពលផ្សេងៗនៃមជ្ឈិមបក្ស។

នៅជាដំបូងគឺការបង្កបង្កើនផងខាងផ្នែកកសិកម្មនេះ គឺត្រូវបានគេលើកមកនិយាយដដែល ហើយបន្ទាប់មក គឺនិយាយអំពីស្ថានភាពរបស់ខ្មាំងនៅពេលបោសសម្អាត ហើយនិងស្ថានភាពខ្មាំងមកពីខាងក្រៅ ហើយទាំងអស់នេះ គឺជាចំណុចនេះដែលស្ថិតនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់។

[១៤:២៤:៥២]

ឯកសារទាំងអស់នេះ គឺថាមានការបង្ហាញទម្រង់ដូចគ្នាសរសេរអក្សរដូចគ្នា ទម្រង់អីគឺដូចគ្នាបេះបិទ រចនាសម្ព័ន្ធដូចគ្នា ហើយពាក្យពេចន៍ដែលប្រើប្រាស់ដូចច្បាស់លាស់ ប្រើប្រាស់ដូចគ្នា គឺមានពាក្យដដែលៗ ដែលប្រើដោយរបបនោះ ដូចជាពាក្យថា បដិវត្តន៍សង្គមនិយម, កម្ទេចសត្រូវ, ឬជនក្បត់នៅក្នុងជួរបក្ស ហើយនិងការប្រុងប្រយ័ត្នផ្នែកបដិវត្តន៍ ការបោសសម្អាត ការសម្លាប់ ឬក៏ដូចដែលលោកខាងមេធាវីការពារក្តីបានលើកឡើងអម្បាញ់មិញ គឺចក្រពត្តិអាមេរិក។

លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅក្នុងពេលដែលគាត់បានផ្តល់ចម្លើយនៅក្នុងឯកសារ D86.13 នោះ គឺក្នុងចំណោមកំណត់ហេតុនោះ គឺថា បានទទួលបានពីក្រសួងមហាផ្ទៃនៅក្នុងឆ្នាំ១៩៨៧ ដែលមាននៅក្នុងមូលដ្ឋានទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ហើយឯកសារ២០ នៃកំណត់ហេតុយោធានោះត្រូវបានទទួលយកដោយអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០១ រួចមកហើយ។

[១៤:២៦:១០]

ដូច្នេះ ខ្ញុំនឹងបញ្ចប់ ហើយខ្ញុំនឹងមិននិយាយអំពីឯកសារ១០ផ្សេងទៀតទេ ពីព្រោះថាយើងបានជជែកផ្តល់យោបល់ហើយទៅលើឯកសារទាំងអស់នេះ។ ហើយឯកសារនោះគឺមាននៅក្នុងលេខ E158។

ជាចុងក្រោយ ជាថ្មីម្តងទៀត យើងគិតថា ធាតុផ្សំទាំងអស់នេះ ដែលបាន យើងបានបង្ហាញជូននៅថ្ងៃនេះ ហើយនៅក្នុងឯកសារជាលាយលក្ខណ៍អក្សរផងដែរ គឺជាធាតុដែលយើងអាចឲ្យយើងសន្និដ្ឋានថា តម្រុយនៃភាពជឿជាក់បាន គឺមិនពាក់ព័ន្ធទៅនឹងស្តង់ដារអប្បបរមាដែលកំណត់ដោយតុលាការ ដើម្បីទទួលយកឯកសារ ថាអាចទទួលយកបាននោះទេ។ ខ្ញុំសូមអរគុណលោកប្រធាន។

[១៤:២៧:០២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដែលមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិ ឡើងធ្វើអំណះអំណាងតបទៅនឹងការជំទាស់ទៅនឹងឯកសារក្នុងឧបសម្ព័ន្ធA3 ដោយក្រុមមេធាវីការពារក្តី។ មេធាវីមានរយៈពេល១៥នាទី ក្នុងការធ្វើអំណះអំណាង។ សូមអញ្ជើញ!

**កញ្ញា ហ្វីលីពីន ស៊ុតហ្សំ៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមទាំងអស់ សូមគោរពភាគីទាំងអស់ ខ្ញុំនឹងនិយាយខ្លីទេ ពីព្រោះថាប្រធានបទនៃកំណត់ហេតុរបស់បក្សកុម្មុយនីស្តកម្ពុជានោះ ត្រូវបាននិយាយច្រើនរួចមកហើយ ដោយសហព្រះរាជអាជ្ញា។ ដូច្នេះយើងពិភាក្សាអំពីឯកសារដែលដាក់ដោយខាងសហព្រះរាជអាជ្ញា ហើយយើងគិតថាមិនមែនជាតួនាទីសំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឆ្លើយតបទៅនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីទេ។ ពីព្រោះថា វាមានលក្ខណៈបច្ចេកទេសណាស់ ហើយខ្ញុំចង់ធ្វើការបង្ហាញជាលក្ខណៈទូទៅ ហើយនិងសង្ខេបទៅលើប្រភេទនៃបរិមាណ នៃការជំទាស់ដែលលើកឡើងដោយខាងមេធាវីការពារក្តីពាក់ព័ន្ធទៅនឹងច្បាប់ជាធរមាន។

គឺថាចំណុចទាំងអស់នេះត្រូវបានជជែក លើកឡើងដដែលៗក្នុងរយៈពេលប៉ុន្មានថ្ងៃមកនេះ ហើយខាងមេធាវីការពារក្តី ក៏គាត់បានទទួលយកនូវការជំទាស់ដែលបានធ្វើឡើងសម្រាប់ក្រុមមេធាវីការពារក្តីទាំងបី ហើយវាមានលក្ខណៈទូទៅ ហើយដដែលៗ។ ខាង អៀង សារី គឺគាត់បានកាត់តគ្នាមក មានតែការជំទាស់ដដែលៗ ពាក់ព័ន្ធទៅនឹភាពអាច-- យថាភាព ភាពដែលអាចជឿជាក់បាន ភាពពាក់ព័ន្ធ។ ហើយខាងក្រុម នួន ជា និយាយដដែលៗ ថាត្រូវតែស្តាប់ចម្លើយលោក ឆាំង យុ ជាដើម។

[១៤:២៩:១០]

ខ្ញុំគិតថា នៅពេលដែលធ្វើការជំទាស់នេះគឺខាងមេធាវីការពារក្តីគាត់យល់ច្រឡំទៅលើការជជែកដេញដោលនោះ គឺគាត់ចង់ធ្វើជាការជជែកទៅលើការទទួលយកឯកសារ។ ខ្ញុំគិតថាវាមានសារៈសំខាន់ណាស់ ក្នុងការលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ហើយលោក លោកស្រីចៅក្រម នឹងពិភាក្សា-- នឹងវាយតម្លៃទៅលើភស្តុតាងទាំងនេះ ទៅតាមការជឿជាក់ដោយឥស្សរចិត្តរបស់ចៅក្រមទាំងអស់។

ខ្ញុំគិតថា យើងត្រឡប់មកលើកគោលការណ៍នៃការដាក់ភស្តុតាងដោយសេរី គឺគោលការណ៍នេះមានន័យថា គ្រប់ភស្តុតាងទាំងអស់គឺអាចទទួលយកបានជាបឋមនៅចំពោះមុខអង្គជំនុំជម្រះ ហើយតម្លៃនៃធាតុផ្សំ គឺតម្លៃជាភស្តុតាងនោះនឹងត្រូវវាយតម្លៃទៅដោយចៅក្រមនៅពេលក្រោយ។ ពិតណាស់គឺមានអញ្ញត្រកម្មទៅនឹងគោលការណ៍នេះ ប៉ុន្តែគឺថាអញ្ញត្រកម្មនេះអាចទទួលបាន គឺតែនៅក្នុងករណី

ច្បាស់លាស់ ដែលថែងដោយវិធានផ្ទៃតែប៉ុណ្ណោះ។ ដូច្នេះដើម្បីឲ្យទទួលយកបាននោះ គឺថាត្រូវតែមានលក្ខណៈជាក់លាក់ ច្បាស់ទៅនឹងឯកសារណាមួយជាក់លាក់ ដើម្បីឲ្យការជំទាស់នោះអាចទទួលយកបានដោយតុលាការនេះ។

ប្រសិនបើយើងអនុវត្តគោលការណ៍ទាំងនេះ ទៅតាមច្បាប់ស៊ីវិលឡនោះ គឺលក្ខណៈវិនិច្ឆ័យយថាភាព ភាពអាចជឿជាក់បាន និងភាពពាក់ព័ន្ធនោះ គឺថាត្រូវតែបកស្រាយមួយតាមរបៀបរឹតត្បិតដូចដែលលោកខាងសហព្រះរាជអាជ្ញាបានបញ្ជាក់រួចមកហើយ។ គឺមានន័យថា ប្រសិនបើឯកសារជាក់លាក់ណាមួយមិនត្រូវបានសន្និដ្ឋានថា មានភាពពាក់ព័ន្ធនោះ គឺថាដោយសារតែឯកសារនោះ គឺនិយាយអំពីហេតុការណ៍នៃសម័យផ្សេងទៀត មិនមែនសម័យកម្ពុជាប្រជាធិបតេយ្យទេ ឬមួយក៏ឯកសារណាមួយដែលសន្និដ្ឋានថា មិនអាចជឿជាក់បាននោះ គឺថាដោយសារតែឯកសារនោះ ពេលដែលយើងមើលឃើញដំបូង គឺជាឯកសារក្លែងក្លាយតែម្តង។

[១៤:៣១:១២]

ដូច្នេះ នេះគឺជាខ្លឹមសារនៃការធ្វើតេស្ត នៃភាពអាចទទួលយកបានជាបឋម នៃធាតុផ្សំនៃភស្តុតាង។ ហើយយើង ប្រសិនបើ ច្បាស់លាស់ណាស់ថា ភាពអាចជឿជាក់ យថាភាព ឬក៏ពាក់ព័ន្ធនៃឯកសារមួយនោះត្រូវតែមានការសង្ស័យ ដោយសារតែមានមូលហេតុច្បាស់លាស់ ឬក៏ជាក់លាក់នោះៗ ពេលនោះហើយឯកសារនោះយើងអាចច្រានចោលបាន។

ខ្ញុំសូមនិយាយដដែលៗ ថាការទទួលយកឯកសារណាមួយនោះ គឺថាវាមិនមានលក្ខណៈធ្វើបុរេវិនិច្ឆ័យទៅលើកម្លាំងជាភស្តុតាងនៃឯកសារនោះទេ។ ហើយខ្ញុំគិតថា ខាងមេធាវីការពារក្តីយល់ច្រឡំថា យើងជជែកពិភាក្សាទៅលើតម្លៃនៃភស្តុតាង។ នេះមិនមែនជាការជជែក យើងនឹងជជែកនៅពេលក្រោយ។

[១៤:៣២:០៤]

ខ្ញុំមានការកត់សម្គាល់ច្បាស់លាស់មួយចំនួន ពាក់ព័ន្ធទៅនឹងភាពអាចជឿជាក់ ហើយនិងយថភាពនៃឯកសារគណៈអចិន្ត្រៃយ៍ ហើយក៏ខាងសហព្រះរាជអាជ្ញាក៏បាននិយាយច្រើនរួចមកហើយទៅលើបញ្ហាទាំងនេះ។ ហើយខ្ញុំនឹងបញ្ចប់នៅដល់ចំណុចនេះ លោក លោកស្រីចៅក្រម។ ហើយជនជាប់ចោទទាំងបី គឺថាគាត់បានតវ៉ាទៅលើភាពជឿជាក់បាននៃឯកសារកំណត់ហេតុនៃគណៈអចិន្ត្រៃយ៍។ ក៏ប៉ុន្តែយើងឃើញហើយថា គឺថា អ្នកទាំងពីរ គឺ នួន ជា និង អៀង សារី នេះគាត់គឺជាសមាជិកហើយគណៈអចិន្ត្រៃយ៍ ហើយ ខៀវ សំផន ក៏បានទទួលស្គាល់ដែរថា គាត់បានចូលរួមនៅក្នុងកិច្ចប្រជុំជាច្រើន

នៅក្នុងនេះ។ ថាតើអ្នកណាទៅដែលអាចបញ្ជាក់បានឲ្យច្បាស់ជាងពួកគាត់ ដែលជាសមាជិកនៃគណៈអចិន្ត្រៃយ៍នោះ។ សូមអរគុណ។

[១៤:៣៣:០០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកស្រីមេធាវី។

ឥឡូវនេះដល់ពេលវេលាសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៤ នាទី ដល់ម៉ោង ១៤:៥៤ នាទី)*

[១៤:៥៤:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ យើងបន្តការស្តាប់ការជំទាស់ទៅលើឯកសារនៅក្នុងឧបសម្ព័ន្ធA4 នៅក្នុងការជំទាស់នៅក្នុងឧបសម្ព័ន្ធA4 នេះ មេធាវីការពារក្តីក្នុងមួយក្រុមមានរយៈពេល៤០នាទី ក្នុងការបង្ហាញនូវការជំទាស់របស់ខ្លួន លើកលែងតែក្រុមមេធាវីការពារក្តីមានការបែងចែកពេលវេលាខុសពីនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសូមប្រគល់ទៅមេធាវីការពារក្តី នួន ជា មុនគេដើម្បីមានពេលវេលាក្នុងការធ្វើការជំទាស់ បង្ហាញការជំទាស់។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន!

ខ្ញុំនៅតែប្រកាន់ជំហរបស់ខ្ញុំអំពីការសង្ស័យលើយថាភាពរបស់ឯកសារឧបសម្ព័ន្ធ៤ ដែលយកមកជជែកក្នុងពេលនេះ។ ដូចនេះ ខ្ញុំនៅប្រកាន់ជំហររបស់ខ្ញុំ ដូចអ្វីដែលខ្ញុំបានជំទាស់ទៅលើឯកសារឧបសម្ព័ន្ធ៣ ដែរ។ ខ្ញុំសូមបន្ថែមថាការរកឯកសារដើមរបស់ឯកសារទាំងនេះគឺងាយរកបានសោះ។

ដោយយោងទៅលើការផ្តល់សម្ភាសជាមួយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រម ស៊ើបអង្កេត ក្នុងការបទសម្ភាសន៍រវាងភ្នាក់ងាររបស់ចៅក្រមស៊ើបអង្កេតទៅនឹងលោកប្រធាន ឌី.ស៊ី.ខេម តាម ឯកសារលេខD204/4 សាក្សីមកពីមជ្ឈមណ្ឌលឯកសារ គឺមន្ត្រីជាន់ខ្ពស់របស់ ឌី.ស៊ី.ខេម បាន ឆ្លើយប្រាប់អ្នកសួរ អ្នកអង្កេតរបស់ចៅក្រមស៊ើបអង្កេតបានប្រាប់ថា "គាត់មានឯកសារជាច្បាប់ដើម ប្រភេទ នេះទាំងអស់" ជាការបញ្ជាក់ជាក់លាក់ណាស់ អាចជួយបន្ធូរបន្ថយការបារម្ភរបស់សហព្រះរាជ អាជ្ញា ក្នុងការរកបានឯកសារដើមដែលខ្លួនបានដាក់ជូនតុលាការអង្គសវនាការសាលាដំបូង។ បើសិនជា សាក្សី នោះបានបង្ហាញភស្តុតាងឯកសារដើមនោះមកតុលាការនៅពេលនេះប្រាកដមែន។

[១៤:៥៧:២៩]

យើងខ្ញុំសូមស្នើផងដែរ ឲ្យមានការកោះហៅសាក្សីដែលមានការពាក់ព័ន្ធក្នុងការធ្វើឯកសារ ទំនាក់ទំនងជាផ្លូវការរវាងថ្នាក់ក្រោមនិងថ្នាក់លើ ដូចជាទូរសារ ឬគេហៅថាទូរសារ តេឡេក្រាម ដើម្បី បញ្ជាក់ថាជាឯកសារទំនាក់ទំនងពិតប្រាកដរបស់កម្ពុជាប្រជាធិបតេយ្យមែនដែរឬទេ?

នៅក្នុងឧបសម្ព័ន្ធ៤នេះ ខ្ញុំមានការឆ្លើយតបតែប៉ុណ្ណេះ ប៉ុន្តែសហការីរបស់ខ្ញុំមានបន្តទៅទៀត សូមអរគុណលោកប្រធាន។

[១៤:៥៨:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញមេធាវីអន្តរជាតិការពារក្តី នួន ជា បើសិនជាមាន។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនត្រូវការពេលច្រើនទេ ជាពិសេសគឺមិនដល់៤០នាទីទេ។ មុន នឹងចាប់ផ្តើមខ្ញុំសូមជម្រាបតុលាការថា ប្រហែលជាមួយម៉ោងកន្លងទៅនេះ នៅក្នុងពេលការឆ្លើយតប របស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់យើង។ ខ្ញុំយល់ថានៅឥឡូវនេះ គឺថាគាត់ភ្ញាក់ពីសម្រាន្ត ហើយៗ គាត់ព្យាយាមតាមដានសវនាការពីបន្ទប់ខាងក្រោម។ ប៉ុន្តែគាត់មិនបានតាមដានទាំងស្រុងទេ ដោយសារគាត់នៅខ្សោយ រីឯការតាមដានតាមអេក្រង់វិញក៏នឿយហត់ដែរ គាត់ក៏បានចុះហត្ថលេខា លើលិខិតបោះបង់សិទ្ធិនៅថ្ងៃម្សិលមិញ ថ្ងៃនេះផងដែរ ក្នុងផ្នែកខ្លះ។

[១៤:៥៩:១៩]

ប៉ុន្តែទាក់ទងទៅនឹងឯកសារដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៤។ ប៉ុន្តែ ជាបឋមដើម្បីឲ្យ

ច្បាស់លាស់នោះ ខ្ញុំនឹងនិយាយឡើងវិញ គឺថាអ្វីដែលជាប្រភេទឯកសារនោះ។ ដែលថាឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងហ្នឹង គឺថាជំហររបស់យើងគឺថាតុលាការត្រូវតែបដិសេធ លើកលែងតែស្តាប់សវនាការលោក ឆាំង យុ នៅតុលាការដែលផ្តល់ឱកាសយើង ភាគីខាងមេធាវីហ្នឹងអាចជំទាស់ហើយអាចនឹង-- ទាក់ទងទៅនឹងការិយាល័យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតផងដែរ ដោយសារថា ឯកសារហ្នឹងវាពាក់ព័ន្ធ។ ហើយថា តើឯកសារហ្នឹងគឺត្រូវបញ្ជូនយ៉ាងម៉េច? ទទួលដូចម្តេចពី ឌី.ស៊ី.ខេម? ហើយគឺយើងក៏ត្រូវការបញ្ជីដែលចង្អុលបង្ហាញថា ឯកសារណាដែលសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបានទទួលពី ឌី.ស៊ី.ខេម នោះ។ ឥឡូវនេះ យើងអាចធ្វើបញ្ជីនោះបាន មិនត្រូវការប្រើពេលច្រើនប៉ុន្មានទេ។ អ៊ីចឹងហើយ យើងខ្ញុំចង់បានបញ្ជីបែបនោះ មិនចាំបាច់ថ្ងៃច័ន្ទនោះទេ ប៉ុន្តែថ្ងៃអង្គារ អាទិត្យក្រោយ នៅពេលដែលយើងបើកសវនាការនោះ ដែលថាយើងស្តាប់សាក្សីលេខ៧៦៦ នោះ។

[១៥:០០:៥០]

ដូចដែលខ្ញុំបានបញ្ជាក់កាលពីព្រឹកមិញនោះដែរ គឺថាយើងមិនជំទាស់ត្រឹមតែឯកសារទាំងនោះដោយផ្អែកលើមូលដ្ឋានពីភាពអាចជឿជាក់បាន កង្វះនូវយថាភាពប៉ុណ្ណោះនោះទេ។ តាមពិតក្នុងករណីខ្លះគឺថា មិនមានភាពពាក់ព័ន្ធដែលជាកត្តាចាំបាច់នោះផងដែរ សម្រាប់សវនាការវគ្គដំបូងក្នុងរឿងក្តី ០០២ នេះ។ ហើយខ្ញុំមិនពិនិត្យបញ្ជីទាំងស្រុងទេ ដូចលោកចៅក្រមជ្រាបហើយគឺថា មានឯកសាររហូតទៅដល់ជាង៧០ ឯណោះ។ អនុលោមតាមពាក្យសហព្រះរាជអាជ្ញានោះគឺថា ដំណាក់កាលដំបូងនៃសវនាការនេះ ខ្ញុំឆ្ងល់ណាស់ថាតើហេតុអីឯកសារអ្វីខ្លះ? ឯកសារដែលសហព្រះរាជអាជ្ញាចង់បង្ហាញភស្តុតាងដែលផ្អែកលើភស្តុតាងនេះនោះ ខ្ញុំមិនយល់សោះ។ ឯកសារ១៦៥ នៃបញ្ជីជាឧទាហរណ៍ ជាឯកសារ ចុះថ្ងៃ៣០ ខែមេសា ឆ្នាំ១៩៧៧ គឺជាតេឡេក្រាមចេញពី កែ ពក ទៅប្រធានមន្ទីរ៨៧០។ បញ្ហានិយាយអំពី “ការងារនយោបាយហើយនិងការងារប្រុងប្រយ័ត្ន”។ មិនដឹងថាព្រះរាជអាជ្ញាគាត់ចង់បញ្ជាក់ភស្តុតាងអី?

[១៥:០២:១២]

ឯកសារ២១២ នៅលើបញ្ជីថ្ងៃទី១៧ មិថុនា ឆ្នាំ១៩៧៧ គឺថាពីរខែ-- ពីរឆ្នាំក្រោយពីការរំដោះហ្នឹង គឺថាទាក់ទងអំពីវ៉ាដា គេថតពីលើឡូកគោ ពោធិ៍ចិនតុង ទាក់ទងទៅនឹងយន្តហោះ ហើយនិងកិច្ចការអាកាសចរណ៍ គឺចម្លងជូន សុន សេន។ ខ្ញុំមិនដឹងថា វាពាក់ព័ន្ធដូចម្តេចនៅក្នុងសវនាការវគ្គនេះ?

ឯកសារ៣៥៤ ថ្ងៃ៣០ មីនា ឆ្នាំ១៩៧៨ គឺជូនទៅក្នុងនាមក្រសួងកិច្ចការសង្គមកិច្ច ទៅលោក វ៉ាន់ រិត។ ហើយមិនដឹងថា សហព្រះរាជអាជ្ញាបង្ហាញឯកសារនេះ គឺឲ្យតុលាការពិនិត្យគឺបង្ហាញភស្តុតាងពីអ្វីនោះទេ។

ឯកសារ៣៥៩ គឺថាថ្ងៃទី៤ មេសា ឆ្នាំ១៩៧៨ គឺបីឆ្នាំក្រោយពីរំដោះភ្នំពេញ របាយការណ៍មកពីមុត ទៅបង៨៧ ដែលនិយាយអំពីកប៉ាល់បុកមីនហើយខូចកប៉ាល់ គឺថាមានរបួសមនុស្សមួយចំនួនគឺថា ៨នាក់នោះគឺថា ចិនផង។ គឺថាមិនទាក់ទងទេ។

ឯកសារ៣៦៥ ថ្ងៃទី៩ មេសា ១៩៧៨ គឺជាលិខិតទៅមន្ទីរ៨៧០ នោះដែរ។ របាយការណ៍ទាក់ទងទៅនឹងគឺថាការប្រយុទ្ធគ្នា គឺថាការដែលមានអគ្គីភ័យគឺដុតភ្លើង ដែលថាមានបុរសពីរនាក់ដែលបង្កឲ្យមានអគ្គីភ័យ ភ្លើងឆេះហ្នឹង។ គឺថាជាចំណុចដែលខ្ញុំចន្លោះទេ នៅក្នុងចំណោមឯកសារគាត់។ ឯកសារលេខ៤០៣ កក្កដា ឆ្នាំ១៩៧៨ គឺថារបាយការណ៍និយាយអំពីឆ្មប។ ក្នុងឆ្នាំហ្នឹងគឺថានិយាយអំពីការងាររបស់ឆ្មបនៅក្នុងមន្ទីរពេទ្យ។ បញ្ជាក់ពីចំណុចវិជ្ជមាន ហើយកង្វះខាត ហើយនិងការប្រុងប្រយ័ត្នខាងបដិវត្តគោលនយោបាយរបស់ឆ្មប។ មិនដឹងថាឯកសារនេះ វាពន្យល់បង្ហាញភស្តុតាងពីអ្វីនោះទេ។

[១៥:០៥:០១]

មិនមែនឯកសារទាំងអស់ដែលថា មានតម្លៃ ឬក៏មានភាពប្រាកដនោះទេ។ ដូច្នេះខ្ញុំសូមអញ្ជើញអង្គជំនុំជម្រះពិនិត្យឯកសារទាំងអស់នោះឲ្យបានល្អិតល្អន់ ហើយច្រានចោលឯកសារទាំងអស់គឺថា មិនត្រូវទទួលស្គាល់ទាំងអស់នោះទេ ពីព្រោះថាឯកសារមួយចំនួនគឺថាមិនពាក់ព័ន្ធទៅនឹងសវនាការវគ្គដំបូង ហើយនិងការជម្លៀស ទីមួយ ទីពីរ នៅក្នុងអង្គហេតុនេះទេ។ ហើយឯកសារមួយចំនួន គឺថាមិនត្រូវអនុញ្ញាតយកមកប្រើដើម្បីឲ្យធ្វើអង្គហេតុហ្នឹងមិនច្បាស់លាស់នោះទេ។

ចំពោះចំណុចមួយទៀត គឺថាយើងនឹងមិន-- តែមេធាវីការពារនោះទេ គឺថាមិនត្រឹមតែអង្គជំនុំជម្រះនោះទេ គឺថាអាចនឹងជួបប្រទះនឹងការលំបាកក្នុងការកំណត់នៅឯកសារទាំងអស់នេះ ដែលព្រះរាជអាជ្ញាដាក់មកទាំងមូលបែបនេះនោះ គឺថាយើងមានការពិបាក។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយជាបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកា ទៅក្រុមមេធាវីការពារក្តីលោក អៀង សារី។ សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងអង្គសវនាការ។ មុននឹងខ្ញុំចាប់ផ្ដើមដល់ទឡ្ហីករណ៍របស់ខ្ញុំ ខ្ញុំលើកចំណុចមួយពីមេធាវី នួន ជា នោះដែលគាត់បានចង្អុលបង្ហាញ។ ខ្ញុំក៏លើកពីដំបូងដែរ ដែលថាការប៉ុនប៉ងឲ្យអង្គជំនុំជម្រះទទួលឯកសារទាំងអស់ដែលមិនទាក់ទងទៅនឹងរឿងក្ដី០០២ វគ្គទីមួយនេះ។

តាមពិតព្រះរាជអាជ្ញាប៉ុនប៉ង គឺអ្វីដែលគាត់មានទាំងអស់នូវឯកសារ ទោះបីជាឯកសារ ឬក៏ភស្តុតាងមានបង្ហាញនូវជាសេចក្ដីសង្ខេប គេអាចអះអាងបែបនោះ ប៉ុន្តែគឺជាឯកសារក្នុងរឿងក្ដីទាំងមូលគឺក្នុងដីកាដំណោះស្រាយទាំងអស់ គឺមិនទាក់ទងទៅនឹងក្នុងករណីដែលថា០០២, ០០៣ នោះទេ។ ដូច្នេះហើយសូមឲ្យអង្គជំនុំជម្រះកម្រិតបំបែករឿងក្ដីដើម្បីឲ្យមានឯកសារដាច់ដោយឡែក ដើម្បីកម្រិតនូវសក្ខីកម្មនៅក្នុងវគ្គដំបូងនៃសវនាការ ដែលថាឯកសារហ្នឹង គឺត្រូវដាក់ឲ្យកម្រិតត្រឹមតែសវនាការវគ្គដំបូងនេះតែប៉ុណ្ណោះ។

[១៥:០៧:៤១]

រីឯទីពីរ ទីបីទៀត គឺត្រូវគិតបែបនោះដែរ។ ដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងក៏បាននិយាយថាឯកសារនេះ៤.០០០ ត្រូវប្រើទាំងស្រុងក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះ អាហ្នឹងគឺមិនត្រឹមត្រូវទេ បើនិយាយពីបរិបទនេះ ដែលថាយើងវគ្គទីមួយទេ មិនទាំងស្រុងទេ។ បើសិនជាយើងគ្រាន់តែកាត់ឯកសារមកយកមកផ្គាក់ទាំងស្រុងបែបនេះ គឺថាមិនសមស្របទេ។ ដូច្នេះគឺថាមិនថាអាចនឹងបានការទទួលស្គាល់ខ្ពស់ ឬក៏ទាបនោះទេ នេះគឺជានីតិវិធីដែលតុលាការបានកំណត់ទៅតាមផ្លូវច្បាប់។

មូលហេតុដែលថា ហេតុអីត្រូវដាក់ឯកសារនេះ? មិនត្រូវដាក់ឯកសារនោះ របស់សហព្រះរាជអាជ្ញា របស់មេធាវីការពារ? ក៏យើងនឹងប្រើវិធីសាស្ត្ររបស់យើងក្នុងការឆ្លើយតបដូចជា យើងខ្ញុំជាមេធាវីតំណាងឲ្យ អៀង សារី ប្រើនោះដែរ។ គឺថាមិនថាតែសាលាក្ដីនេះទេ សាលាក្ដីណា គឺថាគេតែងតែកំណត់ប្រភេទឯកសារដូចជា សារទូរលេខ កំណត់ហេតុអង្គប្រជុំ ដែលតាមធម្មតានោះ យើងមានទឡ្ហីករណ៍ពិសេសទាក់ទងទៅនឹងទឡ្ហីករណ៍ទូទៅ ហើយនិងឯកសារជាក់លាក់ផងដែរ ដូចជាលិខិតសារទូរលេខជាដើម។

[១៥:០៩:០០]

កាលណាយើងនិយាយអំពីករណីដែលថានីតិវិធីរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ឯកសារ

ភស្តុតាងដែលស្រដៀងទៅនឹងតេឡេក្រាម សារទូរលេខហ្នឹងដូចជា *ម៉ានេចជីខេស* (មិនច្បាស់) ក្នុងរឿងក្តី *ម៉ានេចជី--វីលីក*(មិនច្បាស់) នោះគឺថា អ្នកកាន់វិទ្យុទាក់ទងដែលទទួលសារពីប្រភពផ្សេងៗ ពីភាគីផ្សេងៗ ហើយក៏កត់ត្រាដោយផ្ទាល់ដៃនូវសំឡេងហ្នឹង។ សហព្រះរាជអាជ្ញា ដើម្បីដាក់នូវការថត ឬក៏ការចាប់សំឡេងនោះគឺថា *អុបពេរ៉េតទ័រ* គឺថាអ្នកកាន់វិទ្យុហ្នឹងគឺត្រូវមកបង្ហាញភស្តុតាង បើគាត់មិនមានវត្តមានទេ បើសិនសហព្រះរាជអាជ្ញាចង់យកឯកសារហ្នឹងដែលទាក់ទងទៅនឹងការថតសំឡេងនេះគឺថាយ៉ាងហោចណាស់ក៏ត្រូវតែមានសាក្សីផ្តល់សក្ខីកម្មអំពីនីតិវិធីបែបបទដែលថា តើគេថតសំឡេងម៉េច? ទទួលសារម៉េច? ក្នុងហ្នឹង ដើម្បីឲ្យច្បាស់អំពីវិធី ឬក៏បែបបទនៃការកត់ត្រាសំឡេងនៅពេលដែលឮហ្នឹង ហើយនៅពេលដែលគេថតជាសំឡេងហ្នឹងជាដើម តើគេឮសំឡេងឈ្មោះមនុស្ស ឮរបៀបម៉េច? គេកត់ត្រារបៀបម៉េច? ...។ល។ នេះហើយជាចំណុចសំខាន់ គឺខ្ញុំមិនបានស្នើឲ្យទីនេះតុលាការនេះប្រើបែបនោះទេ ប៉ុន្តែចំពោះឯកសារមួយចំនួន គឺយើងឲ្យសាក្សីមកបញ្ជាក់បង្ហាញថា តើវាបែបណា? បើនិយាយអំពីការប្រាស្រ័យទាក់ទងនៅក្នុងឧបសម្ព័ន្ធ៤។

[១៥:១០:៤៤]

ខ្ញុំចង់លើកឧទាហរណ៍បួន ដែលខ្ញុំជឿជាក់ថា ឬក៏អង្គជំនុំជម្រះអាចនឹងយល់ឃើញថា ជាការដែលត្រូវប្រុងប្រយ័ត្ននោះថា ទីមួយ គឺទាក់ទងទៅនឹងអំពើទារុណកម្ម ឬក៏ភស្តុតាងដែលប៉ះពាល់ដល់អំពើទារុណកម្ម គឺថា 108 គឺថា-- យើងថា /26.282 យើងមើលឯកសារនេះ យើងនឹងមើលឃើញថាមានទិន្នន័យមួយចំនួនដែលកើតចេញពីចម្លើយសារភាព។ នេះជាជំហររបស់យើង គឺត្រឹមត្រូវណាស់តាមច្បាប់ដែលយើងអាចនិយាយថា ចម្លើយសារភាពដែលកើតចេញពីអំពើទារុណកម្មជាគ្រប់រូបភាពនៃចម្លើយសារភាពនេះមិនគប្បីទទួលយកមកប្រើប្រឆាំងនឹងជនដែលគេចោទថា ជាជនរងគ្រោះនោះទេ លើកលែងតែប្រឆាំងនឹងជនដែលប្រព្រឹត្តអំពើទារុណកម្ម។ ដូច្នេះឯកសារដែលបានមកពីអំពើទារុណកម្មនេះមិនគប្បីតុលាការទទួលយកទេ ហើយជាសេចក្តីស្នើ ឬសន្និដ្ឋានរបស់យើងខ្ញុំ គឺយើងជំទាស់នូវការទទួលយកនូវឯកសារមួយចំនួនថ្ងៃទី០៦ កញ្ញា ២០១១ E114 កថាខណ្ឌ១, កថាខណ្ឌ២ ដល់ ៥, កថាខណ្ឌ៧ ដល់ ៩, ១០ ហើយនិងកថាខណ្ឌ១៧។

[១៥:១២:១៩]

ឧទាហរណ៍មួយទៀត និយាយអំពីសារទូរលេខ ហើយយើងនឹងបានឮសាក្សីមួយចំនួន-- ចង់ឮពីសាក្សីមួយចំនួន ដូច្នេះហើយ ដែលយើងប្រកាន់ជំហររបស់យើង គឺថាមិនមែនជាជំហរតាមប្រភានោះ

ទេថា-- ទៅតាមប្រភេទនោះទេ ជំហររបស់យើងគឺថា ត្រូវកម្មវត្ថុនៃ ឬលើកលែងតែសហព្រះរាជអាជ្ញាធ្វើការងារដូចជា ក, ខ, គ សិន។ ប៉ុន្តែយើងត្រូវទទួលស្គាល់ថា យើងត្រូវធ្វើការវាយតម្លៃភស្តុតាងដោយសេរីទាំងអស់គ្នា។ 1S12.14 នេះជាសារទូរលេខ ដែលគេអះអាងថា នឹងត្រូវធ្វើឡើងដោយមនុស្សម្នាក់ឈ្មោះ HANA (ស៊ីក) ដូចហង់ ឬក៏ហេង ឈ្មោះគាត់ហ្នឹង។ យើងជំទាស់។ បើតុលាការទទួលយកឯកសារនោះយើងនឹងជំទាស់លើកលែងតែមានឈ្មោះខាងក្រោមនោះ លើកលែងតែសហព្រះរាជអាជ្ញាអាចបង្ហាញឲ្យច្បាស់ថា មានយថាភាព មានភាពពាក់ព័ន្ធ ហើយនិងអាចទុកចិត្តផង ផ្អែកទៅលើខ្លឹមសារនៃទូរលេខនោះ ដែលធ្វើឲ្យយើងមានការងាយស្រួល។

[១៥:១៣:៤២]

បើសិនជាយថាភាពចោទជាបញ្ហា ថាតើសហព្រះរាជអាជ្ញាត្រូវធ្វើដូចម្តេចដើម្បីបញ្ជាក់នោះ? យ៉ាងហោចណាស់យើងជម្រាបថា សហព្រះរាជអាជ្ញាត្រូវតែបញ្ជាក់ថា អ្នកណាអ្នកទទួលខុសត្រូវចំពោះខ្លឹមសារនៃឯកសារនេះ។ ម្យ៉ាងវិញទៀត អ្នកធ្វើឯកសារហ្នឹងអត្តសញ្ញាណគាត់ហ្នឹងអ្នកណា? ឈ្មោះអី? តំណែងអ្វី? ឧទាហរណ៍។ យើងត្រូវមើលមូលដ្ឋានមួយចំនួន ត្រូវតែបង្ហាញឲ្យច្បាស់ថា អ្នកធ្វើហ្នឹង អ្នកធ្វើឯកសារហ្នឹង បានទទួលការអនុញ្ញាតឲ្យធ្វើឯកសារហ្នឹងបានត្រឹមត្រូវតាមគោលការណ៍របស់គេនោះទេ? គឺថាវាមានបទដ្ឋានអប្បបរិមាមួយ ដែលការទទួលយកតែឡេក្រាមដោយគ្រាន់តែមានឈ្មោះ ដោយមិនមានសក្ខីកម្មថា អ្នកណាជាអ្នក-- ជាហេង ឬក៏ហង់ ហ្នឹងថា ថាតើគាត់មានសមត្ថភាពអ្វី? យើងជឿជាក់ថា បើសិនជាប្រើឯកសារនេះ គឺថាធ្វើឲ្យភាគីមេធាវីការពារហ្នឹង គឺរងគ្រោះធ្ងន់ណាស់ដោយសារយើងមិនដឹងថា ឈ្មោះហ្នឹងជាអ្នកណា? បុគ្គលហ្នឹងជាអ្នកណា? មិនមានអ្នកណាមកអះអាងថា ឯកសារហ្នឹងជាអ្វីចេញពីអ្នកណា? ដូច្នេះយើងពិបាកនឹងដេញដោល។ ដូច្នេះគប្បីតែតុលាការពិចារណាចំណុចនេះ។

ដូច្នេះយើងខ្ញុំស្នើថា ប្រសិនបើនៅពេលណាឯកសារហ្នឹងនឹងត្រូវបានទទួលយក ហើយបើយើងមិនមានឱកាសក្នុងការជំទាស់ទៅនឹងអ្នកធ្វើឯកសារនោះទេ ហើយបើសិនជាធ្វើការពិចារណាទៅ បើយើងនិយាយថាយើងត្រូវធ្វើការថ្លឹងថ្លែងឯកសារនោះ តើយើងធ្វើដូចម្តេចកើត?

ដូច្នេះគឺលុះណាតែយើងមានតម្រុយឯករាជ្យថា ខ្លឹមសារ ឬក៏ទម្រង់ឯកសារនោះ គឺជាប្រភពព័ត៌មានមួយដែលថា គួរឲ្យជឿជាក់បំផុត។ អាហ្នឹងទាល់មានតម្រុយបង្ហាញបែបនោះ។ យើងក៏សូមបញ្ជាក់ផងដែលថា ឯកសារដូចជាទូរលេខ មានឈ្មោះកូនក្តីរបស់ខ្ញុំនៅលើហ្នឹង ហើយយើងក៏សូមស្នើ

ដែរថា គ្រាន់តែមានឈ្មោះកូនក្តីនៅលើឯកសារនោះ មិនមែនឈ្មោះហ្នឹង ឬក៏ឯកសារហ្នឹងបង្ហាញថា កូនក្តីរបស់យើងបានទទួលឯកសារនោះទេ។ គ្រាន់តែថា ឧទាហរណ៍ថា ចម្លងជូន ជាប្រភេទនៃពាក្យ ឬក៏ភស្តុតាងត្រូវតែបង្ហាញឲ្យច្បាស់។

[១៥:១៦:២២]

ដូច្នេះសូមតុលាការជ្រាបថា កូនក្តីរបស់យើងពិតជាបានទទួល ឬមិនបានទទួល ឬក៏គ្រាន់តែឯកសារមួយគ្រាន់ដាក់ថាចម្លងជូនកូនក្តីខ្ញុំ ចាត់ទុកថាបានទទួលនោះទេ។ អានោះជាទម្រង់បែបបទដែលគេប្រើនៅពេលហ្នឹង។ មិនដឹងថាបានទទួលឬអត់។

ដូច្នេះនៅក្នុងសេចក្តីសន្និដ្ឋាននៅចុងក្រោយគួរតែពិចារណា ដែលខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះអំពីការព្រួយបារម្ភរបស់ខ្ញុំអំពីប្រភេទនៃឯកសារទាំងអស់នេះ។ ឧទាហរណ៍មួយទៀត អំពីទូរលេខ D366/7.1.793។ នេះជាឯកសារមួយ ដែលអ្នកធ្វើឯកសារនេះ គេអះអាងថា បងនីម។ តើនរណាជាបង នីម? តើបង នឹម អាចមកធ្វើសក្ខីកម្មបានទេ? ថាតើគាត់មានសម្ថតិភាពជាអ្នកធ្វើទូរលេខហ្នឹងដែរទេ? ហើយជឿថា ហើយយើងសូមជម្រាបតុលាការថា យើងមានកាតព្វកិច្ចក្នុងការការពារកូនក្តីរបស់យើង ក្នុងការតាមដានមើលប្រភពនៃឯកសារនេះ។ ហើយទាមទារថា បើអាចធ្វើទៅបាន ឲ្យព្រះរាជអាជ្ញាឲ្យបង្ហាញឲ្យអស់ពីសមត្ថភាព ថាតើបង្ហាញគ្រប់គ្រាន់ទេ ពីភាពយថាភាព ភាពអាចជឿទុកចិត្តបាន ហើយនិងអត្តសញ្ញាណនៃបុគ្គលនោះ ហើយត្រូវតែមានមូលដ្ឋានមួយចំនួនចំនួនមិនច្រើនប៉ុន្មានទេ ប៉ុន្តែត្រូវតែមានកម្រិតមួយ ត្រូវតែបង្ហាញឲ្យច្បាស់ថាបុគ្គល បងនឹម ហ្នឹង គឺថាពិតជាបានធ្វើឯកសារហ្នឹងមែន។ ហើយតាមពិតនៅក្នុងករណីលើកលែង ដូចខ្ញុំបានលើក ការរក្សាសិទ្ធិដែលខ្ញុំលើកឡើង គឺថាយើងនឹងរក្សាសិទ្ធិនៅក្នុងការសួរតទល់ជាមួយ បងនឹម ហ្នឹង។ តើគាត់អាចនិយាយអំពីឯកសារនេះជាក់លាក់នោះទេ មុននឹងតុលាការអាចនឹងឲ្យតម្លៃបាន មុននឹងកំណត់អំពីតម្រុយឯករាជ្យ អំពីតម្លៃនៃឯកសារនេះនោះ។

[១៥:១៨:៤៣]

អ្នកធ្វើឯកសារនោះ អះអាងថាខ្លួនបានចម្លងជូនទៅកូនក្តីខ្ញុំ ប៉ុន្តែអង្គជំនុំជម្រះគប្បីតែពិចារណាមុននឹងបញ្ជាក់ ឬក៏ថ្លឹងថ្លែងឯកសារណាមួយនៅពេលដែល មានឈ្មោះកូនក្តីរបស់ខ្ញុំនៅលើទីនោះៗ នៅលើឯកសារនោះ។ នេះជារបាយការណ៍ នេះឯកសារមួយទៀត។

ខ្ញុំគ្រាន់តែបញ្ជាក់បង្ហាញអំពីឯកសារខ្លះដែលយើងគិតថា ដែលធ្វើឲ្យយើងយល់ថា ភស្តុតាង

មួយចំនួនអាចនឹងបង្កើតឡើងដោយសហព្រះរាជអាជ្ញា ដែលដាក់ដោយព្រះរាជអាជ្ញាហ្នឹង គឺថាត្រូវតែខ្លួនមានបន្ទុកក្នុងការបង្ហាញភស្តុតាងបន្ថែម D108/26.81។ ឯកសារនេះ គឺគេអះអាងថា ធ្វើឡើងដោយលោក ឆាន-- “C-H-A-N”-- ថាន់។ ដោយមូលហេតុដដែលដែរ ខ្ញុំមិនចង់ចំណាយពេលរបស់តុលាការទេ កុំឱ្យខ្ញុំនិយាយដដែលឡើងវិញ។ មូលហេតុដដែលយើងជឿថា ត្រូវតែសហព្រះរាជអាជ្ញាបង្ហាញភស្តុតាងឱ្យគ្រប់គ្រាន់ អំពីយថាភាពនៃឯកសារនេះ។ គឺត្រូវធ្វើឡើងតាមរយៈយ៉ាងហោចណាស់បង្ហាញឱ្យឃើញច្បាស់ថា អ្នកធ្វើឯកសារហ្នឹងនៃរបាយការណ៍ អ្នកធ្វើរបាយការណ៍នេះគឺ តើគាត់មានអត្តសញ្ញាណដូចម្តេច? ដែលថាផ្អែកតាមគោលការណ៍វិចារបុគ្គលហ្នឹងគឺថា គាត់ជាអ្នកអាចធ្វើរបាយ-ការណ៍ហ្នឹងបានមែន។ អ៊ីចឹងគឺថា និយាយអំពី *ប៉ុស្តិ៍កាត* គឺនិយាយថា *ប៉ុស្តិ៍កាត* D199/14.2 គេហៅថាកាតប៉ុស្តាល់។

[១៥:២២:២២]

សហព្រះរាជអាជ្ញានោះបាននិយាយថា ត្រូវធ្វើឡើងដោយយកចិត្ត-- ឧបសម្ព័ន្ធ៤ គឺថា 155 ដោយមូលហេតុដដែលគឺថា យើងជំទាស់ឯកសារនេះ។ ប្រភេទឯកសារនេះ លើកលែងតែមានមូលដ្ឋានដែលព្រះរាជអាជ្ញា បានបញ្ជាក់ឱ្យច្បាស់ ដូចដែលខ្ញុំបានលើកឡើងពីខាងដើម បើមិនមានទេ យើងនៅតែជំទាស់ ខ្ញុំមិនបញ្ជាក់ដដែលឡើងវិញនោះទេ។

ជាថ្មីម្តងទៀត លោក លោកស្រីចៅក្រមដើម្បីបញ្ជាក់ឱ្យច្បាស់ថា ការជំទាស់របស់យើងគឺច្បាស់ មិនមែនថា ជំទាស់មិនឱ្យដាក់ឯកសារណាមួយទាំងអស់នោះទេ។ យើងមិនបញ្ជាក់តុលាការថាមិនមានអ្វីដែលថាគ្មានយថានុភាព មិនមានអ្វីដែលគួរឱ្យទុកចិត្តបានទេ។ សំណើរបស់យើងគឺថា នៅដំណាក់កាលមួយសហព្រះរាជអាជ្ញា មិនចាំបាច់ពីដំបូងទេ ប៉ុន្តែនៅពេលណាមួយ នៅពេលដែលសហព្រះរាជអាជ្ញាហ្នឹងចង់វិភាគ ឬក៏ប្រជុំសម្រេចឯកសារហ្នឹងក៏ត្រូវតែបង្កើតនូវមូលដ្ឋានសម្រាប់ឯកសារទាំងអស់នេះ ដែលធ្វើឱ្យតុលាការទុកចិត្តថា ឯកសារហ្នឹងវាមានលក្ខណៈថា មានយថាភាព អាចទុកចិត្តបាន បើនិយាយអំពីភាពពាក់ព័ន្ធវិញ គឺថាយើងអាចនឹងដឹងច្បាស់នៅក្នុងរឿងក្តី។

ខ្ញុំមិនមានអ្វីបន្ថែមទៀតទេ លោក លោកស្រីចៅក្រម សូមអរគុណចំពោះសវនាការ។ អរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ហើយជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការ។

សម្រាប់ឧបសម្ព័ន្ធទី៤ ទាក់ទងនឹងឯកសារ ដែលមានទំនាក់ទំនងកម្ពុជាប្រជាធិបតេយ្យ យើងឃើញថា សហព្រះរាជអាជ្ញាបានលើកឯកសារចំនួន ៣៩៤ឯកសារ ដែលក្នុងនោះយើងបានពិនិត្យឃើញភាពពាក់ព័ន្ធមួយចំនួន ដែលសហព្រះរាជអាជ្ញា បានបង្ហាញពីតម្រុយដែលអាចជាប់ពាក់ព័ន្ធ ក្នុងការគួរឲ្យជឿនោះមានចំនួនតែ ៩៩ឯកសារតែប៉ុណ្ណោះ។ ហើយក្នុងចំនួន ៩៩ឯកសារនេះ មិនមែនមានន័យថា សុទ្ធតែឯកសារដែលអាចផ្តល់នូវព័ត៌មានគ្រប់គ្រាន់ សម្រាប់ឲ្យជឿទាំងស្រុងទេ។ វាមានព័ត៌មានតិចតួចបំផុត ហើយនិយាយម៉្យាងទៀតថា មានចំណុចខ្វះខាតជាច្រើនសម្រាប់បញ្ជាក់អំពីភាពត្រឹមត្រូវនៃឯកសារ ឬក៏ភាពខ្វះចន្លោះចំពោះព័ត៌មានទាំងឡាយ ពាក់ព័ន្ធទៅនឹងការរក្សាទុកឯកសារ ឬការកាន់កាប់ឯកសារក្នុងរយៈពេលកន្លងមក មុនពេលឯកសារទាំងនោះចូលមកដល់ដៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៥:២៤:១១]

យោងតាមឯកសារដែលបានបញ្ជាក់នោះឃើញថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារទាំងនេះពីប្រភពផ្សេងៗ ពុំមានលក្ខណៈច្បាស់លាស់បញ្ជាក់ថា រយៈពេល ឬក៏ទីកន្លែងអ្នកប្រគល់មកឲ្យនោះ បញ្ជាក់អំពីអត្តសញ្ញាណត្រឹមត្រូវនោះទេ។ ក្នុងប្រភពឯកសារទាំងនោះ យើងឃើញមានបួនប្រភព ដែលមានបណ្ណសារដ្ឋានជាតិទួលស្លែង ក្រសួងមហាផ្ទៃ និងមួយទៀតចេញពីប្រភពបុគ្គលដែលមានលេខសម្គាល់ TCE038។ ចំណុចនេះការលើកបង្ហាញរបស់ខ្ញុំ គឺមិនខុសអ្វីឧបសម្ព័ន្ធមុនៗទេ គឺថាព័ត៌មានទាក់ទងទៅនឹងឯកសារ ការកាន់កាប់ ការផ្តល់ ឬការផ្តល់បុគ្គលដែលអ្នក-- អ្នកដែលប្រគល់ឲ្យ គឺត្រូវបានបាត់បង់។ សហព្រះរាជអាជ្ញាមិនបានបង្ហាញឲ្យឃើញ ថាពីពេលដែលផលិតឯកសារ ដែលឯកសារត្រូវបានកើតឡើងនោះនៅពេលណាពិតប្រាកដ? ហើយបន្តការគ្រប់គ្រងដោយរបៀបណានោះទេ?

[១៥:២៦:៣០]

ចំណុចនេះ ខ្ញុំមើលឃើញថា ហាក់ដូចជាមានការប្រទាញប្រទង់គ្នា ដោយខាងសហព្រះរាជអាជ្ញាយល់ថា វាជាភារកិច្ចរបស់មេធាវីការពារក្នុងការលើកជំទាស់ទៅលើចំណុចណាមួយនៃឯកសារនេះ។ ប៉ុន្តែអ្វីដែលជាគោលជំហររបស់យើងខ្ញុំនោះ គឺថាសហព្រះរាជអាជ្ញាខកខានមិនបានបញ្ជាក់អំពី

យថាភាព ក៏ដូចជាភាពដែលគួរឲ្យជឿបាននៃឯកសារទាំងនោះ មុនពេលយកឯកសារនោះមកដាក់ជូនអង្គសវនាការ។

ដូច្នេះបើសិនជាយើងខ្ញុំពិនិត្យទៅលើឯកសារទាំងអស់នោះ វាហាក់ដូចជាយើងខ្ញុំត្រូវបង្ហាញនូវភាពជឿជាក់ ឬក៏យថាភាពនៃឯកសារទាំងអស់នោះជំនួសសហព្រះរាជអាជ្ញាទៅវិញ។ កន្លងមកខ្ញុំតែងបានលើកមួយ ឬក៏ពីរជាឧទាហរណ៍ ប៉ុន្តែមិនមែនមានន័យថា ក្នុងចំណោមឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធនីមួយៗ ដែលខ្ញុំបាទបានលើកមានត្រឹមតែមួយ ឬពីរប៉ុណ្ណោះទេ។

[១៥:២៨:២១]

ខ្ញុំសូមទាញការចាប់អារម្មណ៍របស់ក្រុមប្រឹក្សាជំនុំជម្រះ និងអង្គសវនាការផងដែរ ចំពោះភាពខុសគ្នា ឧទាហរណ៍ទាក់ទងទៅនឹងពេលវេលា ទាក់ទងទៅនឹងបុគ្គលដែលរកឃើញឯកសារ ទាក់ទងទៅនឹងបុគ្គលដែលទទួលឯកសារ ទាក់ទងទៅនឹងទីកន្លែងដែលរកឃើញឯកសារ ឬក៏ទាក់ទងទៅនឹងស្ថានភាពផ្សេងៗជុំវិញការទទួលឯកសារ ឬក៏ការរក្សាទុកឯកសារ។ ហេតុអីបានមានភាពចាំបាច់? ហេតុអីបានយើងគិតថា វាមានចំណុចសង្ស័យ? ហេតុអីបានយើងត្រូវរកឲ្យឃើញថា អ្នកណាជាអ្នកធ្វើឯកសារ? អ្នកណាជាអ្នករក្សាឯកសារ? ឬអ្នកណាអ្នករកឃើញឯកសារទាំងអស់នោះ?

ដោយសារនៅដែលបុគ្គលផ្សេងពីគ្នារកឃើញឯកសារនោះ វាអាចនាំឲ្យយើងមានភាពសង្ស័យផ្សេងៗគ្នាដែរ ពីព្រោះថាឯកសារដែលស្ថិតនៅទីកន្លែងមួយ ឬរកឃើញដោយបុគ្គលណាម្នាក់នោះ មិនមែនមានតម្លៃគួរឲ្យជឿស្មើគ្នាទាំងអស់នោះជាមួយនឹងអ្នកដទៃទៀតនោះទេ ឬជាមួយនឹងទីកន្លែងដទៃទៀតទេ។

[១៥:២៩:៤៤]

បើឯកសារដែលស្ថិតនៅកន្លែងមួយ ដែលបង្ហាញនូវភាពអព្យាក្រឹត ទំនងជាការជឿអាចមានច្រើនជាង។ ក៏ប៉ុន្តែបើឯកសារនោះស្ថិតនៅក្នុងកន្លែងមួយ ដែលបង្ហាញនូវភាពអព្យាក្រឹត ឬក៏ភាពលម្អៀង។ អ៊ីចឹងការជឿទុកចិត្តទៅលើឯកសារនោះវាមានកាន់តែច្រើន។ ដូច្នេះហើយបានជាយើងទាមទារហើយទាមទារទៀត ចំពោះការស្វែងរកឲ្យឃើញដើម្បីបញ្ជាក់អំពីយថាភាព ក៏ដូចជាភាពជឿជាក់ចំពោះឯកសារនីមួយៗ។ ហើយការធ្វើបែបនេះបាន ទាល់តែយើងតាមដាននូវភាពពាក់ព័ន្ធរវាងឯកសារ និងបុគ្គលទាំងឡាយណាដែលមានជាប់ពាក់ព័ន្ធនឹងឯកសារនោះ។ ហើយការនេះអាចបង្ហាញបានតែចំពោះមុខអង្គសវនាការនេះ ដោយមានការដេញដោលពីភាគី ដើម្បីបញ្ជាក់ឲ្យអស់មន្ទិល ឲ្យអស់

ភាពសង្ស័យ។

ដូច្នេះជាថ្មីម្តងទៀត ខ្ញុំបាទសូមទទូចដល់ក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យទៅលើលទ្ធភាពដែលអាចកោះអញ្ជើញអ្នកដែលពាក់ព័ន្ធ ដើម្បីឲ្យភាគីអាចសួរដេញដោលនៅក្នុងអង្គសវនាការនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាកិច្ចបន្តអង្គជនុំជម្រះផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានលទ្ធភាពក្នុងការធ្វើ លើកឡើងនូវអំណះអំណាងតបប្រសិនបើមាន។

សូមញ្ជើញសហព្រះរាជអាជ្ញា!

[១៥:៣២:០៤]

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

នៅពេលនេះ ក្នុងនាមខ្ញុំតំណាងសហព្រះរាជអាជ្ញាសូមបង្ហាញជូននូវការឆ្លើយតបទៅនឹងអ្វីដែលមេធាវីការពារក្តីបានលើកឡើងទាក់ទិននឹងឧបសម្ព័ន្ធ៤ ដែលមានចំណងថា “ការប្រាស្រ័យទាក់ទងរបស់កម្ពុជាប្រជាធិបតេយ្យ” ហើយមានភាពស្មើភាពនៃក្រុមឯកសារដូចតទៅ៖ របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ លិខិតរបស់កម្ពុជាប្រជាធិបតេយ្យ សារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ កំណត់សម្គាល់របស់កម្ពុជាប្រជាធិបតេយ្យ និងបទបញ្ជាផ្សេងទៀតរបស់កម្ពុជាប្រជាធិបតេយ្យ។ មេធាវីការពារក្តីបានលើកឡើងអំពីការជំទាស់បួនប្រភេទខុសគ្នា។ ពោលគឺទាក់ទិននឹងឯកសារនានាដែលមាននៅក្នុងឧបសម្ព័ន្ធ៤ នៃបញ្ជីឯកសារ។ ខ្ញុំបានកត់សម្គាល់ឃើញថា ប្រភេទនីមួយៗនៃការជំទាស់ទាំងនេះ គឺត្រូវបានធ្វើច្រំដែលៗ តាមពាក្យពេចន៍ដូចគ្នាទៅនឹងឯកសារក្រុមធំ ដែលមាននៅក្នុងឧបសម្ព័ន្ធនោះដែរ និងមិនបានលើកអំពីបញ្ហាជាក់លាក់ណាមួយចំពោះឯកសារណាមួយនោះទេ។

[១៥:៣៣:៣៥]

ដើម្បីលើកឡើងអំពីការជំទាស់ទាំងអស់នេះ ដំបូងខ្ញុំនៅតែប្រកាន់ជំហរសង្ខេបអំពីបទដ្ឋានច្បាប់ដែលពាក់ព័ន្ធ ដោយហេតុថាបទដ្ឋានទាំងនោះអនុវត្តចំពោះការជំទាស់ទាំងបួននោះ ដែលបានលើកឡើងទាក់ទិននឹងក្រុមឯកសារនេះ។ ខ្ញុំសូមលើកទាក់ទិនទៅនឹងចំណុចសំខាន់ៗដូចតទៅនេះ៖

ការធ្វើតេស្តពិសោធន៍ផ្លូវច្បាប់អំពីភាពអាចទទួលយកបាន ដែលអាចនិយាយបានថាជាករណីទូទៅមួយ។ ចំណុចចាប់ផ្តើមនៃការវិភាគសម្រាប់ការកំណត់ អំពីភាពអាចទទួលយកបាននៃឯកសារគឺជាការសន្មតអំពីភាពអាចទទួលយកបានដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក។ វិធាន៨៧(១) ដែលបានចែងថា "រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក ស្ថិតនៅក្រោមវិធាន៨៧(៣) ដែលចែងអំពីកម្រិតអំពីទឡ្ហីករណ៍ជាក់លាក់អំពីការច្រានចោលនៃភស្តុតាង"។

[១៥:៣៤:៤២]

ភាពពាក់ព័ន្ធ និងការជឿទុកចិត្តបាន ខ្ញុំសូមបកស្រាយជូនដូចតទៅ៖

អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបកស្រាយអំពីអនុភាព នៃវិធាន៨៧(៣) ថា ភស្តុតាងនោះត្រូវតែបំពេញបាននូវលក្ខខណ្ឌជាក់លាក់មួយចំនួននៃភាពពាក់ព័ន្ធ និងតម្លៃភវនីយភាព និងបទដ្ឋានអប្បបរមានៃភាពពាក់ព័ន្ធ និងការជឿទុកចិត្តបាន ដែលត្រូវទទួលយក។ ដើម្បីឲ្យគេពិចារណាថា ការពាក់ព័ន្ធភស្តុតាងដែលបានផ្តល់ជូននោះ ត្រូវតែឃើញមួយក្រឡេកភ្នែក ឲ្យគេសន្មតបានយ៉ាងជាក់ច្បាស់ទៅនឹងបញ្ហានោះ និងមានភាពទោរទន់ ពោលគឺមានទំនោរទៅរកការកំណត់បាននូវគោលជំហររបស់ភាគីនោះ។ ខ្ញុំកត់សម្គាល់ឃើញថា គ្មានចំណុចជាក់លាក់ណាមួយត្រូវបានគេលើកឡើងក្នុងការជំទាស់របស់មេធាវីការពារក្តីនោះទេ ដែលតវ៉ាអំពីភាពពាក់ព័ន្ធនៃឯកសារដែលមានក្នុងឧបសម្ព័ន្ធ៤ នោះទេ។ បើទោះបីជាការជំទាស់ទាំងនោះមានការអះអាងទៅនឹងភាពពាក់ព័ន្ធជាទូទៅក៏ដោយចុះ។ បើទោះជាបានបំពេញនូវលក្ខណៈវិនិច្ឆ័យទីមួយនេះក្តី ក៏ចោទជាសំណួរផ្សេងៗក៏នៅតែមានភាពជឿទុកចិត្តបាននៃភស្តុតាងដដែល។

[១៥:៣៦:០៤]

លោក លោកស្រីចៅក្រមជាទីគោរព! កត្តាជាក់ស្តែងទៅនឹងភាពអាចទទួលយកបានតាមឧទាហរណ៍នេះ គឺភាពទុកចិត្តបានចំពោះប្រភេទក្រុមឯកសារនេះ។ បទដ្ឋាននៃភាពជឿទុកចិត្តបានដែលជាលក្ខខណ្ឌតម្រូវនូវដំណាក់កាលទទួលយកគឺថា ភស្តុតាងនោះត្រូវតែឃើញមួយក្រឡេកភ្នែកឲ្យគេជឿជាក់បាន ហើយលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃដូច្នេះ គឺអាស្រ័យទៅលើកាលៈទេសៈពិសេសនៃករណីនីមួយៗ និងដោយរួមបញ្ចូលនៃវិសាលភាពនៃកត្តាផ្សេងៗទៀតផង។

គេគ្មានលក្ខខណ្ឌតម្រូវសម្រាប់យថាភូតនៃឯកសារណាមួយ ដែលត្រូវបានគេកំណត់និយមន័យច្បាស់លាស់ដូចដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងករណីនេះទេ។ នៅមុនពេលមានការទទួល

យកជាភស្តុតាងនោះទេ។ តឹកតាងស្តីពីភាពដើមនៃឯកសារ គឺវាពាក់ព័ន្ធទៅនឹងការពិចារណាថា តើឯកសារនោះមានសញ្ញាសម្គាល់គ្រប់គ្រាន់នៃភាពជឿទុកចិត្តបានដែរឬទេ? ប៉ុន្តែការណ៍នេះ មិនមែនជាបុរេលក្ខខណ្ឌសម្រាប់ឲ្យមានការទទួលយកនោះឡើយ។

លោក លោកស្រីចៅក្រម ចំពោះភាពអាចទទួលយកបានធៀបទៅនឹងទម្ងន់។ ខ្ញុំសូមធ្វើការឆ្លើយតបដូចតទៅនេះ៖ តម្លៃភវនីយភាពនៃចំណែកមួយនៃភស្តុតាងនៅដំណាក់កាលទទួលយក អាចនឹងត្រូវបានបំពេញតាមរយៈការបង្ហាញឲ្យឃើញនូវសញ្ញាសម្គាល់នៃភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបាន។ ម្យ៉ាងវិញទៀត តម្លៃភវនីយភាពពិតប្រាកដ ឬទម្ងន់ដែលមានសមល្មមចំពោះភស្តុតាងត្រូវបានវាយតម្លៃដោយអង្គជំនុំជម្រះ។ នៅពេលណាភស្តុតាងទាំងអស់ត្រូវបានស្តាប់នៅក្នុងសវនាការរួចហើយ។ បន្ទុករបស់ភាគីដែលស្វែងរកការដាក់ភស្តុតាង គឺត្រូវបង្ហាញឲ្យឃើញអំពីភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបាន ក្នុងកម្រិតអប្បបរមា។

[១៥:៣៨:១២]

ដូចដែលបានធ្វើកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង និងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតគឺថា ការវាយតម្លៃអំពីភវនីយភាពពិតប្រាកដ ឬទម្ងន់ត្រូវចាត់លើចំណែកណាមួយនៃភស្តុតាងគឺជាចំណោទពីរដាច់ពីគ្នាដែលនឹងត្រូវកើតឡើងនាក្រោយ ដើម្បីកំណត់ថាតើទំនងជាត្រូវបញ្ជាក់ ឬមិនបញ្ជាក់ការចោទប្រកាន់នៅក្នុងរឿងក្តីនោះដែរឬទេ? បទដ្ឋានអប្បបរមាសម្រាប់ការទទួលយកភស្តុតាងនោះគឺវាសមស្របទៅនឹងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ហើយ។ ដែលនៅទីនេះភស្តុតាងត្រូវបានប្រមូល ឬពិនិត្យដោយចៅក្រមស៊ើបសួរឯករាជ្យនិងមិនលម្អៀង ហើយចំណែកចៅក្រមដែលជាអ្នកកាត់សេចក្តីលើអង្គហេតុគឺជាចៅក្រមអាជីពដ៏មានបទពិសោធន៍មិនមែនជាក្រុមគណៈវិនិច្ឆ័យនៃបុគ្គលគ្មានអាជីពនោះឡើយ។

[១៥:៣៩:១៩]

លោកប្រធានជាទីគោរព ខ្ញុំសូមបន្តធ្វើការឆ្លើយតបទាក់ទិនទៅនឹងចម្លើយដែលបានមកពីការធ្វើទារុណកម្មដូចតទៅនេះ៖

បើទោះបីជាមានភាពទាក់ទងនឹងភាពអាចទុកចិត្តបាន ជាការពិចារណាចម្បងក្នុងការទទួលយកឯកសារក៏ដោយ ក៏វិធាន៨៧(៣) បានហាមឃាត់យ៉ាងជាក់ច្បាស់នៅចំពោះមុខភស្តុតាង ដែលច្បាប់មិនអនុញ្ញាតផងដែរ។ ភស្តុតាងមួយប្រភេទដែលស្ថិតនៅក្នុងការហាមឃាត់ដ៏ទូលំទូលាយនេះ គឺចម្លើយ

ដែលបានមកពីការធ្វើទារុណកម្ម។ ពិសោធន៍នៅមាត្រា១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ហៅកាត់ថា អនុសញ្ញា ខេត "CAT" និងមាត្រា៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា បានហាមឃាត់ចំពោះចម្លើយដែលបានធ្វើឡើងដោយការធ្វើទារុណកម្ម ឬដោយការគំរាមកំហែងលើរាងកាយបុគ្គល។

នៅក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការហាមឃាត់នេះមានន័យថា គេមិនអាចទទួលយកចម្លើយដែលបានមកពីការធ្វើទារុណកម្មមកបញ្ជាក់ថា សាច់រឿងនៅក្នុងនោះជាការពិតនោះទេ។ ក៏ប៉ុន្តែគេនៅតែអាចទទួលយកបានធ្វើជាភស្តុតាងបញ្ជាក់អង្គហេតុថា គេបានធ្វើចម្លើយនោះ ហើយចម្លើយនោះជាចម្លើយដែលបានមកពីការធ្វើទារុណកម្ម។

[១៥:៤០:៤៨]

ហើយដូច្នេះហើយ មុននឹងធ្វើសេចក្តីសម្រេចចិត្តអំពីភាពអាចទទួលយកបាននៃចម្លើយ ឬឯកសារបន្ទាប់បន្សំដែលអាចភ្ជាប់បានផ្សេងៗទៀត ប្រការសំខាន់គឺត្រូវកំណត់អំពីគោលបំណងដែលគេដាក់ឯក-សារ ហើយជំទាស់របស់មេធាវីការពារក្តីនឹងមានសុពលភាពទៅបានតែនៅពេលណាដែលឯកសារនោះបានបង្ហាញការពិតពីការធ្វើទារុណកម្មដែលនាំឱ្យបានទទួលព័ត៌មាននោះតែប៉ុណ្ណោះ។ ជាឧទាហរណ៍ការជំទាស់ជាទូទៅទាក់ទិននឹងឯកសារ ឬសម្ភារៈពាក់ព័ន្ធនឹងចម្លើយសារភាពនៅមន្ទីរស-២១ គឺមិនគ្រប់គ្រាន់ទេ។

អង្គជំនុំជម្រះជាទីគោរព វិធានស្តីពីការបដិសេធភស្តុតាងដែលមានចែងក្នុងមាត្រា១៥ នៃអនុសញ្ញាខេត "CAT" ទាក់ទិននឹងចម្លើយដែលបានមកពីការធ្វើទារុណកម្មតែប៉ុណ្ណោះ។ វាអនុញ្ញាតជាពិសេសឱ្យមានការប្រើប្រាស់នូវចម្លើយបែបដូច្នេះ ដែលប្រឆាំងនឹងជនដែលគេបានចោទថា បានធ្វើទារុណកម្មរួច*(ឮមិនច្បាស់)* ធ្វើជាភស្តុតាងដែលចម្លើយនោះ ត្រូវបានធ្វើឡើង។

[១៥:៤២:០០]

ដើម្បីអនុវត្តនូវការហាមឃាត់នេះចម្លើយនោះត្រូវតែៈ ទី១) បង្ហាញថាបានមកដោយសារការធ្វើទារុណកម្មមែន។ ទី២) ការប្រើប្រាស់ចម្លើយនោះត្រូវតែបានហាមឃាត់ដោយអនុសញ្ញា។

ប្រយោគដ៏ទូលំទូលាយ និងមិនច្បាស់លាស់ដោយសារការធ្វើទារុណកម្មដែលមេធាវីការពារក្តីបានប្រើប្រាស់នៅក្នុងការជំទាស់របស់ខ្លួន គឺមិនបានឆ្លុះបញ្ចាំងអំពីបទដ្ឋាននៃច្បាប់នេះឱ្យបានត្រឹមត្រូវនោះទេ។ ដោយសារតែការចងចាំអំពីធាតុផ្សំនៃបទដ្ឋានសម្រាប់ការទទួលយកបាននៅក្នុងអនុសញ្ញាខេត "CAT" ប្រការសំខាន់គឺត្រូវញែកឱ្យខុសគ្នារវាងឯកសារភស្តុតាងប្រភេទផ្សេងៗ ដែលជាបញ្ហានៅក្នុង

ករណីរឿងនេះ ហើយនិងការប្រើប្រាស់នានា ដែលភស្តុតាងប្រភេទផ្សេងៗទាំងនោះត្រូវបានគេដាក់បញ្ចូលធ្វើជាភស្តុតាង។

[១៥:៤២:៥៩]

ជាការបន្ថែមទៅលើចម្លើយសារភាពដែលអ្នកជាប់ឃុំបានចុះហត្ថលេខា។ បណ្តុំចម្លើយសារភាពដែលមាននៅក្នុងសំណុំរឿងជាទូទៅ មានរួមបញ្ចូលនូវសេចក្តីសង្ខេប និងរបាយការណ៍នានាដែលពួកអ្នកសួរចម្លើយបានធ្វើការកត់ត្រាទុកនូវអត្តសញ្ញាណរបស់អ្នកទោស កាលបរិច្ឆេទ និងទីកន្លែងចាប់ខ្លួន ហើយនិងការរៀបរាប់អំពីប្រភេទនៃការបង្ខិតបង្ខំ ឬទារុណកម្មដែលគេបានប្រើទៅលើអ្នកទោសរូបនោះ។ ឯកសារក្នុងឧបសម្ព័ន្ធ៤ បង្កើតបានជាអនុស្សរណៈផ្ទៃក្នុងនៃកម្ពុជាប្រជាធិបតេយ្យដែលមានផ្ទុកនូវព័ត៌មានដែលភាគីទីបីបានកត់ត្រាទុក មិនមែនជាប្រធានបទនៃការធ្វើទារុណកម្មនោះទេ។

[១៥:៤៣:៥៤]

ឯកសារនោះ បានផ្ទុកនូវព័ត៌មានផ្ញើជូនសមាជិកបក្ស ឬថ្នាក់លើផ្សេងៗ ហើយហេតុដូច្នេះឯកសារទាំងនោះគឺមិនស្ថិតនៅក្នុងវិធានស្តីពីការបដិសេធភស្តុតាងនោះទេ។ គេអាចប្រើប្រាស់ឯកសារទាំងនោះ ដើម្បីបង្ហាញសក្ខីកម្មអំពីអត្តសញ្ញាណរបស់បុគ្គលនានា ដែលត្រូវចាប់ខ្លួន ត្រូវជាប់ឃុំ និងត្រូវបានគេធ្វើទារុណកម្មព្រមទាំងសេចក្តីពិស្តារនៃការចាប់ខ្លួន ការជាប់ឃុំ និងអំពើទារុណកម្មដទៃទៀត។ ជាញឹកញាប់សេចក្តីសង្ខេប និងរបាយការណ៍ទាំងនោះមានរួមបញ្ចូលនូវបញ្ជីឈ្មោះកម្មាភិបាល ឬជនដទៃទៀតដែលអ្នកជាប់ឃុំបានធ្វើការឆ្លើយដាក់ថា មានជាប់ទាក់ទិនគ្នា។ គេអាចប្រើបញ្ជីឈ្មោះទាំងនេះដើម្បីបង្ហាញអំពីផែនការឧក្រិដ្ឋកម្មរួមក្នុងការកំណត់អត្តសញ្ញាណ និងកម្ទេចពួកអ្នកដែលគេយល់ឃើញថាជាអ្នកប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការប្រើប្រាស់ជាប្រព័ន្ធនូវការធ្វើទារុណកម្មដូចបានបញ្ជាក់ជូនខាងលើ។

[១៥:៤៥:០២]

ក្រៅពីព័ត៌មានរបស់ភាគីទីបីដែលមាននៅក្នុងឯកសារបែបនេះ ព័ត៌មានដែលបានមកដោយសារតែការធ្វើទារុណកម្ម ដែលអាចត្រូវបានកត់ត្រាទុកនៅក្នុងឯកសារ ក៏អាចត្រូវបានគេប្រើដើម្បីបង្ហាញសក្ខីកម្មអំពីអង្គហេតុ ដែលអំពើទារុណកម្មបានកើតឡើងផងដែរ។ អង្គហេតុទាំងអស់នោះរួមមានអត្តសញ្ញាណរបស់អ្នកទោស កាលបរិច្ឆេទនៃការចាប់ខ្លួននិងឃុំខ្លួន វិធីធ្វើទារុណកម្ម និងបញ្ហាដទៃទៀតដែលបានកើតមាន។ នៅក្នុងប្រភេទស្តីពីរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យដែលសហការី

របស់គេបានបរិយាយរួចហើយ មានឯកសារដែលមានផ្ទុកនូវរបាយការណ៍ស្តីពីការប្រើប្រាស់ទារុណកម្ម និងការទាញយកចម្លើយសារភាពផងដែរ។

[១៥:៤៥:៤៩]

លោក លោកស្រីចៅក្រម ជាមួយនឹងឯកសារផ្សេងៗទៀត ចម្លើយសារភាពអាចបង្ហាញថា ព័ត៌មានដែលបានមកពីការជាប់ឃុំត្រូវបានគេប្រើធ្វើជាមូលដ្ឋាននូវក្នុងការចាប់ខ្លួន និងបោសម្អាតនៅពេលក្រោយទៀត មិនមានសេចក្តីស្នើឡើងថា ព័ត៌មានដែលមានផ្ទុកនៅក្នុងចម្លើយសារភាពមួយត្រូវបានសហព្រះរាជអាជ្ញាយកធ្វើជាមូលដ្ឋានដើម្បីបង្កើតការពិតនៅក្នុងសាច់រឿងនោះទេ។ ជាឧទាហរណ៍ សេចក្តីដែលស្នើថា អ្នកទោសរូបនោះ ឬនរណាក៏ដោយដែលគេបានដាក់ឈ្មោះឲ្យនោះជាគិញ ឬជាខ្មាំងនោះទេ ឬមួយក៏ទៅតាមរបៀបណាមួយដែលហួសឆ្ងាយពីបទដ្ឋានដែលអង្គជំនុំជម្រះសាលាដំបូងបានចែងនៅក្នុងសំណុំរឿងលេខ០០១ ក៏ទេនោះដែរ-- ក៏មិនមែនដែរ បានន័យថា គឺមិនមែនដូចអ្វីដែលបានលើកឡើងនោះទេ។

[១៥:៤៦:៤៦]

ដើម្បីឲ្យឯកសារជាក់លាក់ណាមួយ ដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាអាចត្រូវទទួលយកបាន ដោយអាស្រ័យតាមខ្លឹមសារនៃមាត្រា១៥ នៃអនុសញ្ញាខេត (CAT) គឺគេចាំបាច់ត្រូវតែធ្វើការបង្ហាញថា ឯកសារនោះមានផ្ទុកចម្លើយនានាដែលបានមកពីការធ្វើទារុណកម្ម ហើយនិងការប្រើប្រាស់ដែលគេបានស្នើឡើងនោះ គឺស្ថិតនៅក្រៅការលើកលែងដែលគេបានទទួលស្គាល់។

ការជំទាស់ជាទូទៅរហូតមកដល់ពេលនេះ ដែលជនជាប់ចោទ ខៀវ សំផន និងជនជាប់ចោទ អៀង សារី បានលើស្នើឡើងនេះ គឺខកខានមិនបានត្រូវសមស្របទៅតាមបទដ្ឋាននេះទេ ឬសូម្បីតែមិនបានទាំងព្យាយាមធ្វើឲ្យត្រូវទៅតាមបទដ្ឋាននោះផងដែរ។

[១៥:៤៧:៣៩]

លោក លោកស្រីចៅក្រមជាទីគោរព ការជំទាស់ទីមួយ និងដែលជាការជំទាស់ទូទៅជាងគេបំផុតដែលបានលើកឡើងទាក់ទិននឹងឯកសារក្នុងឧបសម្ព័ន្ធទី៤ នោះ គឺថាឯកសារនានាគួរត្រូវបានដកចេញលុះត្រាតែការិយាល័យសហព្រះរាជអាជ្ញាអាចបង្ហាញឲ្យបានគ្រប់គ្រាន់អំពីយថាភូត ភាពគួរឲ្យទុកចិត្តបាន និងការជាប់ទាក់ទិននៃឯកសារនោះ ដោយបង្ហាញឲ្យឃើញថា តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះឯកសារនោះ? ការជំទាស់នោះ ត្រូវបានលើកឡើងក្នុងទម្រង់ដែលមានលក្ខណៈទូទៅ

ទាក់ទិននឹងសារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យចំនួន៨១។ កំណត់សម្គាល់របស់កម្ពុជាប្រធិបតេយ្យចំនួន៤ របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យចំនួន១០៥ និងលិខិតរបស់កម្ពុជាប្រជាធិបតេយ្យចំនួន៧។

មេធាវីការពារក្តីបានដាក់ឲ្យនៅដាច់ដោយឡែកពីគេនូវស្ទូចនាករនៃភាពគួរឲ្យជឿទុកចិត្តបាននេះ ហើយហាក់ដូចជាលើកឡើងអំពីការខកខានមិនបានបង្ហាញឲ្យឃើញ អំពីអ្នកណាជាអ្នកជាអ្នកនិពន្ធនៃឯកសារនេះ ដែលជាការធ្វើឲ្យមានអន្តរាយយ៉ាងធំដល់ភាពអាចទទួលយកបាននៃឯកសារទាំងអស់នេះ។ នៅក្នុងការជំទាស់នេះ មេធាវីការពារក្តីក៏បានលើកឡើងផងដែរថា ឯកសារបែបនេះ បើសិនជាត្រូវបានព្រមទទួលយកនោះ គួរតែទទួលយកក្នុងលក្ខណៈដែលមានទម្ងន់អប្បបរមាបានហើយ។ ប្រសិនបើមេធាវីការពារក្តីមិនត្រូវបានផ្តល់ឲ្យនូវឱកាស ដើម្បីធ្វើការតទល់គ្នាជាមួយនឹងអ្នកនិពន្ធនៃឯកសារទាំងអស់នេះបាន។ លុះត្រាតែខ្លឹមសារនៅក្នុងឯកសារនេះអាចត្រូវធ្វើការផ្ទៀងផ្ទាត់ ឬក៏ត្រូវបានគាំទ្រតាមរយៈសញ្ញាបង្ហាញណាមួយដែលមានភាពឯករាជ្យ។

[១៥:៤៩:៣៥]

ដូចដែលបានធ្វើការទាញហេតុផល និងបង្ហាញភស្តុតាងដោយការិយាល័យសហព្រះរាជអាជ្ញារួចមកហើយ នៅ អ.វ.ត.ក គឺមិនមានការតម្រូវថា ភស្តុតាងត្រូវតែបានបង្ហាញជូនតាមរយៈភស្តុតាងជាសាក្សីនោះទេ។ ហើយក៏មិនត្រូវឲ្យមានការបង្ហាញអ្នកនិពន្ធនៃឯកសារ ដែលជាតម្រូវមួយខុសពីធម្មតានៃការធ្វើតេស្តសាកល្បង ពិសោធអំពីភាពគួរឲ្យជឿទុកចិត្តបាន ឬអំពីយថាភូតនៅក្នុងដំណាក់កាលនៃការទទួលយកនេះដែរ។ កត្តាទាំងអស់នេះ អាចត្រូវបានយកចិត្តទុកដាក់រហូតមក ព្រមជាមួយនឹងសញ្ញាបង្ហាញនានាដ៏ច្រើនអនេក ដែលអាចអនុវត្តបាននៅក្នុងការសួរដេញដោលនេះ។

លោក លោកស្រីចៅក្រម ទម្ងន់ដែលត្រូវបានដាក់ឲ្យសម្រាប់ជាឯកសារ ជាពិសេសណាមួយក៏មិនមែនជាបញ្ហាដែលត្រូវធ្វើការពិចារណានៅក្នុងដំណាក់កាលនេះដែរ។ ក្នុងរឿងនេះ បញ្ហានានាដូចជា តើសារទូរលេខជាពិសេសណាមួយដែលបានផ្ញើជូន អៀង សារី? តាមការពិត តើគាត់បានទទួលឬដែរឬក៏អត់? មានការជំទាស់មួយត្រូវបានលើកឡើង ទាក់ទិននឹងសារទូរលេខចំនួន៤៤ និងរបាយការណ៍មួយចំនួនទៀតផង និងត្រូវបានធ្វើការពិចារណាដោយអង្គជំនុំជម្រះ នៅក្នុងបរិបទនៃភស្តុតាងទាំងអស់ ទាំងមូលតែម្តង។ ហើយតាមការពិត នៅក្នុងករណីណាក៏ដោយ ក៏មិនអាចជាបញ្ហាដែលទាក់ទិននឹងឯកសារ ដែលកំពុងតែត្រូវបានបង្កើតឡើងដោយឯកសារនោះដែរ។

[១៥:៥១:១៧]

ការជំទាស់ដ៏សំខាន់ទីពីរ ទាក់ទិននឹងឯកសារដែលបានមកដោយសារតែការធ្វើទារុណកម្ម។ ការជំទាស់ដែលបានលើកឡើងដោយមេធាវីការពារក្តីនេះ ក៏ជាការលើកឡើងដដែលជាដដែល នៅក្នុងលក្ខណៈជាទូទៅដែរ។ ដោយមិនមានចេតនា ដើម្បីញែកចេញឲ្យដាក់ពីគ្នានូវកត្តានានា ស្តីពីកង្វល់ជាក់លាក់ដែលទាក់ទងនឹងឯកសារដោយឡែកមួយចំនួននៅក្នុងឧបសម្ព័ន្ធទី៤ដែរ។

សាជាថ្មីម្តងទៀត មេធាវីការពារក្តីបានលើកឡើងដោយខុសអំពីការធ្វើតេស្តសាកល្បងពិសោធសម្រាប់ការបដិសេធនូវឯកសារដែលបានមកដោយសារតែការធ្វើទារុណកម្ម និងបានលើកឡើងនូវការបដិសេធនេះ ទាក់ទងនឹងការកំណត់សម្គាល់មួយ។ របាយការណ៍ចំនួនប្រាំពីរ និងបទបញ្ជាចំនួនបួនរបស់កម្ពុជាប្រជាធិបតេយ្យ។

[១៥:៥២:១៣]

ការប្រើប្រាស់សំណួរវោហារអំពីវិធាន ដែលបានពោលអះអាងនេះនៅក្នុងការជំទាស់របស់មេធាវីការពារក្តី គឺមានដូចតទៅនេះ៖

ឯកសារដែលបានមកដោយសារតែការធ្វើទារុណកម្ម គឺមានតាមគ្រប់ទម្រង់ទាំងអស់នៃការធ្វើទារុណកម្ម និងទៅតាមកាលៈទេសៈនីមួយៗ លើកលែងតែប្រឆាំងនឹងជនណាម្នាក់ដែលបានចោទប្រកាន់អំពីការធ្វើទារុណកម្មយកមកធ្វើជាភស្តុតាងថា បានឆ្លើយចម្លើយដូចនេះ។ គឺមិនអាចឲ្យទទួលយកបានទេ នៅក្នុងដំណើរការនីតិវិធីរបស់តុលាការ នៅចំពោះមុខ អ.វ.ត.ក។

ដូចដែលបានវែកញែកបង្ហាញជូនរួចហើយ វិធានស្តីពីការបដិសេធដែលបានមកដោយសារការធ្វើទារុណកម្ម គឺមានការអនុវត្តដ៏តឹងរ៉ឹង ជាងអ្វីដែលមេធាវីការពារក្តីបានលើកឡើងឆ្ងាយណាស់។ ព័ត៌មានដែលមាននៅក្នុងបទបញ្ជា របាយការណ៍ និងកំណត់សម្គាល់ទាំងឡាយដែលបានរៀបរាប់អំពីការធ្វើទារុណកម្ម និងអំពីកាលៈទេសៈអំពីការធ្វើទារុណកម្ម គឺច្បាស់ណាស់ថា មិនមែនជាលទ្ធផលដែលបានមកដោយសារតែការធ្វើទារុណកម្ម ឬការជំរុញឲ្យឆ្លើយដោយមានការគំរាមកំហែងថានឹងធ្វើឲ្យគ្រោះថ្នាក់រូបរាងកាយនោះទេ។

[១៥:៥៣:២៨]

បើសិនជានៅក្នុងរបាយការណ៍ទាំងនោះមានព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្ម បង្ខំឲ្យឆ្លើយសារភាពនោះ ការិយាល័យសហព្រះរាជអាជ្ញាមុខជាមិនខិតខំស្វែងរកតាមបែបណាមួយ

ដើម្បីពឹងផ្អែកទៅលើការពិតនៅក្នុងព័ត៌មាននោះឡើយ។

ទីបី មេធាវីការពារក្តីបានលើកសំអាងថា ឯកសារមួយចំនួននៅក្នុងឧបសម្ព័ន្ធទី៤ គឺសុទ្ធតែថ្មី ហើយមិនអាចឲ្យទទួលយកជាភស្តុតាងបានទេ លុះត្រាតែមានការបង្ហាញសក្ខីកម្មថា ឯកសារទាំងនោះមិនមានសម្រាប់អាចឲ្យងាយរកបានទេ នៅមុនពេលបើកសវនាការជម្រះក្តី អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

តាមពិតទៅ ឯកសារទាំងអស់នេះមិនស្ថិតនៅក្រោមបទប្បញ្ញត្តិនេះឡើយ ដោយសារតែឯកសារទាំងអស់ត្រូវបានដាក់តាមរយៈបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ ឯកសារលេខយោង E9/31 តាំងពីមុនពេលសវនាសការចាប់ផ្តើមមកម៉្លេះ។

[១៥:៥៤:៤០]

លោក លោកស្រីចៅក្រមជាទីគោរព ជាទីបញ្ចប់នេះ មេធាវីការពារក្តីបានជំទាស់ចំពោះការទទួលយកនូវឯកសារមួយចំនួន នៅក្នុងពេលកំពុងរង់ចាំការផ្តល់ការបកប្រែឯកសារទៅជាភាសាអង់គ្លេស។ ឯកសារទាំងអស់នេះ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ។ ហើយការខិតខំប្រឹងប្រែងដោយសុទ្ធចិត្តត្រូវបានធ្វើឡើងហើយដែរ ដើម្បីឲ្យទទួលបាននូវការបកប្រែដ៏ត្រឹមត្រូវមួយ។ ដោយសារតែពេលវេលា និងធនធានមានកម្រិត បានធ្វើឲ្យប៉ះពាល់ដល់ការបកប្រែនៃគ្រប់រាល់ឯកសារទាំងអស់ គឺបានន័យថា ឯកសារជាភាសាខ្មែរមួយចំនួន សរុបចំនួន១៦ ក្នុងចំណោមឯកសារ ៣៩៣ ឯកសារ ដែលនៅក្នុងផ្នែកនៃឧបសម្ព័ន្ធទី៤ សម្រាប់ដំណាក់កាលដំបូងនោះ នៅមិនទាន់បានបកប្រែជាភាសាអង់គ្លេស ដែលអាចឲ្យរកបាននៅឡើយទេ។

ទាំងអស់នេះគឺជាការឆ្លើយតបរបស់ខ្ញុំ ចំពោះអ្វីដែលលោកមេធាវីការពារក្តីបានលើកឡើង។ ខ្ញុំសូមអនុញ្ញាតលោកប្រធានបញ្ចប់ការបំភ្លឺរបស់ខ្ញុំតែប៉ុណ្ណេះ ហើយសូមអនុញ្ញាតឲ្យសហការីរបស់ខ្ញុំបន្តនូវអ្វីដែលគាត់ចង់បន្ថែមទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយសហព្រះរាជអាជ្ញារងអន្តរជាតិ តើត្រូវការពេលវេលាប្រហែលប៉ុន្មានទៅក្នុងការបន្ថែម ឆ្លើយតបបន្ថែមនេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំត្រូវមានពេលមួយម៉ោង។ ដូច្នេះ មានពេលនៅសល់ខ្លី ដូច្នេះខ្ញុំចង់ប្រើពេលឲ្យ

បានច្រើន ហើយខ្ញុំៗនឹងចាប់ផ្ដើមថ្ងៃស្អែកជាការល្អ អាស្រ័យទៅលើការសម្រេចរបស់អង្គជំនុំជម្រះ។ លោកប្រធាន សូមអរគុណ។

[១៥:៥៦:៣២]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ដោយសារលោកបានបង្ហាញជំហរច្បាស់លាស់ក្នុងការប្រើពេលវេលា ដែលបានបែងចែកទៅឲ្យក្រុមសហមេធាវីការពារក្ដី ហើយនៅក្នុងព្រះរាជអាជ្ញា-- សហព្រះរាជអាជ្ញា ហើយនៅក្នុងបរិបទនេះយើងបានកំណត់ពេលវេលាមួយម៉ោង ឥឡូវនេះទើបតែប្រើពេលអស់កន្លះម៉ោងទេ។ អ៊ីចឹងមិនអាចបន្តកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដើម្បីឲ្យចប់នូវការឆ្លើយតបរបស់ក្រុមសហព្រះរាជអាជ្ញាបានទេ។ ដូច្នេះ អង្គជំនុំជម្រះគិតថា ពេលវេលាក៏សមល្មមនឹងឈប់សម្រាកហើយសម្រាប់ថ្ងៃនេះ។

ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាក កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្ត នៅថ្ងៃនៅថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ក៏ប៉ុន្តែយើងគួរតែលើកឡើងចំណុចនេះកាលពីព្រឹកមិញ ដើម្បីយើងកំណត់ប្រតិចារឹក ខ្ញុំរីករាយណាស់ដែលថាចៅក្រម ហ្វេនស៍ គាត់អាចចូលរួមក្នុងជំនួសក្នុងនាមជាចៅក្រមពេញសិទ្ធិដូច្នេះ ប្រសិនបើអាចអ៊ីចឹងតទៅទៀតបាននោះ គឺវាជាការល្អ ដោយសារវាមិនមានការជ្រៀតជ្រែកពីរដ្ឋាភិបាល នៅក្នុងការងាររបស់តុលាការនេះ។

ដូច្នេះហើយ ខ្ញុំរីករាយប្រសិនបើចៅក្រម ហ្វេនស៍ អាចជំនួសធ្វើជាចៅក្រមពេញសិទ្ធិវិញបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មិនទំនងជារីករាយស្រេចតែការចង់របស់លោកមេធាវីទេ វាអាស្រ័យទៅលើច្បាប់ដែលប្រើប្រាស់នៅទីនេះ។ អង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនហើយថា ចៅក្រម ហ្វេនស៍ ជំនួសតំណែងចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ក្នុងអំឡុងពេលដែលគាត់មានធុរៈមិនអាចចូលសវនាការបាន។

ហើយការជំនួសនេះគឺ ចៅក្រម ហ្វេនស៍ ចូលរួមជំនួសចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ រហូតដល់

មានវត្តមានរបស់ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដែលអាចបន្តកិច្ចដំណើរការសវនាការបាន។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឱ្យនាំពួកគាត់ត្រឡប់មកកាន់ទីនេះនៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន ដោយជនជាប់ចោទពីរនាក់ គឺ លោក នួន ជា ហើយនិងលោក អៀង សារី គឺទុកគាត់នៅបន្ទប់ខាងក្រោម ដើម្បីឱ្យគាត់បន្តការតាមដាននូវកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធឧបករណ៍សោតទស្សន៍ ហើយចំណែកឯលោក ខៀវ សំផន គឺនាំមកកាន់សាលសវនាការនេះ។

សូមសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០០ នាទី)*